របាយការណ៍វាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ២០១៦-២០២០

គណៈកម្មាធិការដឹកនាំ
ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍វាយតម្លៃការអនុវត្ត
# ផែនការសកម្មភាពរួម ដំណាក់កាលទី៣ ឆ្នាំ២០១៦-២០២០
# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# មាតិកានុក្រម


ខ្លឹមសារសង្ខេបប្រតិបត្តិ....................i
១. សេចក្តីផ្តើម.................... ១
១.១. សាវតារ.................... ១
១.២. គោលបំណង.................... ២
១.៣. វិធីសាស្ត្រនៃការវាយតម្លៃ.................... ២
១.៤. បរិការណ៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងពេលអនុវត្ត CAP 3 .................... ២
២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣....................៤
២.១. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទ កសហវ....................៤
២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន....................៤
២.៣. សេចក្តីសម្រេចរបស់ គ.ហ.ស. ....................៥
៣. ការវាយតម្លៃលើការសម្រេចបានគោលបំណង....................៩
៣.១. ផ្នែកទី ១ ÷ ភាពជឿទុកចិត្តបាននៃថវិកា....................៩
៣.១.១. គោលបំណង ១១ ÷ បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល ....................៩
៣.១.២. គោលបំណង ១២ ÷ បន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ.................... ១១
៣.១.៣. គោលបំណង ១៣ ÷ ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី.................... ១២
៣.១.៤. គោលបំណង ១៤ ÷ កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ.................... ១៣
៣.១.៥. សេចក្តីសន្និដ្ឋានផ្នែកទី ១ .................... ១៤
៣.២. ផ្នែកទី ២ ÷ គណនេយ្យភាពហិរញ្ញវត្ថុ.................... ១៥
៣.២.១. គោលបំណង ២១ ÷ ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី.................... ១៥
៣.២.២. គោលបំណង ២២ ÷ ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី.................... ១៨
៣.២.៣. គោលបំណង ២៣ ÷ ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី.................... ១៩
និងប្រព័ន្ធរបាយការណ៍ថ្មី.................... ១៩
៣.២.៤. គោលបំណង ២៤ ÷ ពង្រឹងការអនុវត្តឧបករណ៍ និង យន្តការដើម្បីបង្កើនការទទួលខុសត្រូវ ....................២១
និងគណនេយ្យភាព....................២១
៣.២.៥. គោលបំណង ២៥ ÷ បង្កើនតម្លាភាពថវិកា....................២២

៣.២.៦. សេចក្តីសន្និដ្ឋានផ្នែកទី ២ ........ ២៤
៣.៣. ផ្នែកទី ៣ ÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ........ ២៥
៣.៣.១. គោលបំណង ៣១ ÷ ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកា ........ ២៦
៣.៣.២. គោលបំណង ៣២ ÷ រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា ..... ២៧
៣.៣.៣. គោលបំណង ៣៣ ÷ រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ, រវាង កសហវ និង ក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង ស្ថាប័ន) ........ ២៨
៣.៣.៤. គោលបំណង ៣៤ ÷ ពង្រឹងការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយ និងផែនការចំណូល និងចំណាយរយៈពេលមធ្យម) ........ ២៩
៣.៣.៥. គោលបំណង ៣៥ ÷ ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ........ ២៩
៣.៣.៦. សេចក្តីសន្និដ្ឋានផ្នែកទី ៣........ ៣២
៣.៤. ផ្នែកទី ៤ ÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់........ ៣២
៣.៤.១. គោលបំណង ៤១ ÷ បង្កើតក្របខណ្ឌថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម........ ៣២
៣.៤.២. គោលបំណង ៤២ ÷ រៀបចំ និងដាក់ឱ្យអនុវត្តប្រកខ័ណ្ឌគណនេយ្យសមិទ្ធកម្ម ........ ៣៤
៣.៤.៣. គោលបំណង ៤៣ ÷ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ........ ៣៥
៣.៤.៤. គោលបំណង ៤៤ ÷ រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ) ........ ៣៦
៣.៤.៥. សេចក្តីសន្និដ្ឋានផ្នែកទី ៤........ ៣៧
៣.៥. ផ្នែកទី ៥ ÷ ការគាំទ្រដល់ការអនុវត្តប្រកបដោយចីរភាព........ ៣៨
៣.៥.១. សេចក្តីសន្និដ្ឋានផ្នែកទី ៥........ ៤១
៣.៦. ចំណុចកង្វះចន្លោះនៃក្របខណ្ឌផែនការសកម្មភាពរួម- ដំណាក់កាលទី ៣........ ៤១
**៤. ការពិនិត្យមើលលទ្ធផលសង្ខេប PEFA**........ ៤៣
**៥. និសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**........ ៤៥
**៦. Implication សម្រាប់រៀបចំផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២**........ ៤៨
៦.១. សុពលភាពនៃខឿន........ ៤៨
៦.២. ផ្លាស់ប្តូរកម្រិតគោលបំណង........ ៤៨
**៧. សេចក្តីសន្និដ្ឋាន**........ ៥០
**ឧបសម្ព័ន្ធ**........ ៥១

ឧបសម្ព័ន្ធទី ១. របាយការណ៍ត្រួតពិនិត្យ CAP3 របស់ធនាគារអភិវឌ្ឍន៍អាស៊ី .................................... ៥២

ឧបសម្ព័ន្ធទី ២. របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៦-២០២០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣........................................................................................................ ៥២

ឧបសម្ព័ន្ធទី ៣. តារាងសង្ខេបការប្រៀបធៀបបម្រែបម្រួលពិន្ទុនៃការវាយតម្លៃ PEFA ឆ្នាំ ២០១៥ និងឆ្នាំ ២០២០ ដោយប្រើប្រាស់ក្របខណ្ឌវាយតម្លៃឆ្នាំ ២០១១ ........................................................................... ៥៣

ឧបសម្ព័ន្ធទី ៤. តារាងសង្ខេបការផ្លាស់ប្តូរកម្រិតគោលបំណង........................................................ ៥៩

# អក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BSP | Budget Strategic Plan | ផែនការយុទ្ធសាស្ត្រថវិកា (ផ.យ.ថ) |
| BSRS | Budget System Reform Strategy | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា |
| CAP | Consolidated Action Plan | ផែនការសកម្មភាពរួម |
| CoA | Chart of Accounts | ប្លង់គណនេយ្យ |
| DMFAS | Debt Management and Financial Analysis System | ប្រព័ន្ធវិភាគហិរញ្ញវត្ថុ និងគ្រប់គ្រងបំណុល |
| EFI | Economics and Finance Institute | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វ.ស.ហ.) |
| GDICDM | General Department of International Cooperation and Debt Management | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) |
| FMIS | Financial Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| FMWG | FMIS project Management Working Group | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា (អ.ថ.) |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អ.គ.រ.) |
| GDIA | General Department of Internal Audit | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (អ.ស.ក.) |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ (អ.រ.ជ.) |
| GDPP | General Department of Public Procurement | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ |
| GDSNAF | General Department of Sub-National Administration Finance | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ (អ.ហ.ថ.) |
| GDSPNR | General Department of State Property and Non-Tax Revenue | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) |
| GDP | General Department of Policy/ Gross Domestic Product | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| GFS | Government Financial Statistics | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល |
| GSC | General Secretariat of Public Financial Management Reform Steering Committee | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ) |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| LM | Line Ministry | ក្រសួង ស្ថាប័ន |
| LCs | Legal Council Secratariat | លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម (ល.ក.ន.) |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.) |
| MTBF | Medium-Term Budget Framework | ក្របខណ្ឌថវិការយៈពេលមធ្យម |

| | | |
|---|---|---|
| MTFF | Medium-Term Fiscal Framework | ក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម |
| NAA | National Audit Authority | អាជ្ញាធរសវនកម្មជាតិ (អ.ជ.ស.) |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| TOFE | Table of Fiscal and Economic Operations of the Government | តារាងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋាភិបាល |
| WB | World Bank | ធនាគារពិភពលោក |
| PFMRC | Public Financial Management Reform Commission | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ<br>សាធារណៈ (.ស.ហ.ក) |
| PFMSC | Public Financial Management Reform Steering Committee | គណៈកម្មាធិការដឹកនាំការងារកែទម្រង់<br>ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| MoEYS | Ministry of Edcation, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| EFMS | Education Financial Management System | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |
| PB | Program Budgeting | ថវិកាកម្មវិធី |
| NRMIS | Non-tax Reveue Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |
| SARMIS | State Asset Register Management Information System | ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ |

## ខ្លឹមសារសង្ខេបប្រតិបត្តិ

របាយការណ៍វាយតម្លៃនៃការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ (CAP3) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំឡើងដោយផ្អែកលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ដែលត្រូវបានរៀបចំជាប្រចាំត្រីមាស និងប្រចាំឆ្នាំ, និងលទ្ធផលនៃការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុដែលហៅកាត់ថា PEFA ឆ្នាំ២០២០ ទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង របាយការណ៍លទ្ធផលស្តីពីការត្រួតពិនិត្យមើលផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ ដែលរៀបចំដោយអ្នកជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ វិធីសាស្ត្រក្នុងការវាយតម្លៃ រួមមាន ÷ (១) ការពិនិត្យ និងវាយតម្លៃសូចនាករគន្លឹះកម្រិតគោលបំណង, (២) ការវាយតម្លៃជារួមសម្រាប់កម្រិតផ្នែក, និង (៣) ការពិនិត្យមើលសេចក្តីសម្រេចរបស់ **គ.ហ.ស.** ។

### *លទ្ធផលស្តីពីការវាយតម្លៃផែនការសកម្មភាពរួម-ដំណាក់កាលទី ៣*

ក្នុងចន្លោះឆ្នាំ ២០១៦-២០២០ អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគ្រោងសកម្មភាពក្នុងរង្វង់ ៤០០ សកម្មភាពនៃឆ្នាំនីមួយៗ ។ សកម្មភាពអនុវត្តសម្រេចមិនបានពេញលេញ បានធ្លាក់ចុះនៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយដែលបង្ហាញពីការយកចិត្តទុកដាក់របស់តួអង្គអនុវត្តពីមួយឆ្នាំទៅមួយឆ្នាំ ។ នៅក្នុងឆ្នាំ ២០២០ សកម្មភាពដែលពិនិត្យឃើញថាបានទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ មិនត្រូវបានយកធ្វើជាកម្មវត្ថុសម្រាប់ការវាយតម្លៃនោះទេ ម្យ៉ាងទៀត សកម្មភាពទាំងនោះ ភាគច្រើនជាសកម្មភាពគ្រោងនៅក្នុងផ្នែកទី ៥ ដែលពាក់ព័ន្ធនឹងការកសាងសមត្ថភាព ។ សកម្មភាពដែលបានគ្រោងក្នុងឆ្នាំនីមួយៗ នៅតែប្រមូលផ្តុំលើផ្នែកទី ១ ។

ការគ្រោងសកម្មភាពរបស់ក្រសួង ស្ថាប័ន មានអត្រាធ្លាក់ចុះជាបន្តបន្ទាប់ចាប់ពីឆ្នាំ ២០១៧ មក, ក៏ប៉ុន្តែ សកម្មភាពដែលអនុវត្តសម្រេចបានពេញលេញបានកើនឡើងនៅឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ ។ ការណ៍នេះ បង្ហាញពីគុណភាពក្នុងការរៀបចំគ្រោងសកម្មភាព និងអនុវត្តមានប្រសិទ្ធភាពល្អជាងមុនរបស់ក្រសួង ស្ថាប័ន ។ ដូចគ្នានឹងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, នៅក្នុងឆ្នាំ ២០២០ ចំនួនសកម្មភាពសម្រេចមិនបានពេញលេញរបស់ក្រសួង ស្ថាប័ន មានការកើនឡើងវិញប្រមាណជា ១២៥ ក្នុងនោះរួមមានទាំងសកម្មភាពមិនអាចអនុវត្តបានមួយចំនួនផងដែរ ដែលទទួលរងឥទ្ធិពលពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយភាគច្រើនគឺជាសកម្មភាពគ្រោងនៅក្នុងផ្នែកទី ៥ គឺជាសកម្មភាពបណ្តុះបណ្តាល និងសិក្ខាសាលា ។

***-ផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"*** *÷ មានគោលបំណងចំនួន ៤ រួមមាន (១) ពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល, (២) បន្តពង្រឹងការគ្រប់គ្រងបំណុល, (៣) ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី, និង (៤) កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ* ។ តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ និង យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល, ចំណូលមានស្ថានភាពរឹងមាំ និងបានបង្កើតឱ្យមានជាអតិរេកចរន្ត ។ ចំណូលកើន

ឡើងជាមធ្យម ១,៤ ពិន្ទុភាគរយនៃ ផសស (២០១៤-២០១៨) និងជាពិសេសបំផុតចំណូលបានកើនឡើងដល់ ៣,១៨[1] ពិន្ទុភាគរយនៃ ផសស ក្នុងឆ្នាំ២០១៩ ។ ការអនុវត្តចំណាយ ត្រូវបានបន្តការកែលម្អស្របតាមផែនការគួរឱ្យកត់សម្គាល់ និងស្ថិតក្នុងទិសដៅកំណត់ (+/-៥% ធៀបនឹងកម្មវិធីចំណូល-ចំណាយ) ។ ស្ថានភាពនៃការអនុវត្តចំណាយសរុបប្រចាំឆ្នាំសម្រេចបានជាអប្បបរមា ៩៦% ស្របតាមសូចនាករ និងផែនការដែលបានគ្រោង ។ សមតុល្យសាច់ប្រាក់ត្រូវបានតាមដានជាប្រចាំតាមរយៈរបាយការណ៍ធនាគារក្នុងគណនីទាំងឡាយ ដែលស្ថិតនៅក្រោមរចនាសម្ព័ន្ធគណនីទោល (TSA) មិនមានកង្វះខាតសាច់ប្រាក់ ។ ការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារត្រូវបានអនុវត្តទូទាំងប្រទេស និងមានលក្ខណៈទៀងទាត់ចំនួន ២ ដងក្នុងមួយខែ ។ ចាប់តាំងពីឆ្នាំ ២០១៦ មិនមានបញ្ហាចំណាយកកស្ទះនោះទេ[2] និងបំណុលសាធារណៈស្ថិតក្នុងស្ថានភាពអាចគ្រប់គ្រងបានដោយសូចនាករបំណុលគន្លឹះៗទាំង៥ ស្ថិតក្រោមពិតានកំណត់ទាំងអស់ ។ ជាមួយគ្នានេះ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ក៏ត្រូវបានដាក់ឱ្យអនុវត្តនៅតាមក្រសួង ស្ថាប័ន និងមន្ទីរជំនាញប្រមូលចំណូល ។ សម្រាប់រដ្ឋបាលរាជធានី-ខេត្តគ្រោងនឹងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២១ តទៅ ។ លើសពីនេះ, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ និងគោលការណ៍ណែនាំស្តីពីការភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើគ្រោងថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។ ការព្យាករសាច់ប្រាក់ដោយអគ្គនាយកដ្ឋានរតនាគារជាតិមានភាពប្រសើរឡើង តាមរយៈការដាក់ឱ្យអនុវត្តកម្មវិធី Web-Based Application ដោយក្រសួង ស្ថាប័នចំនួន ២០ ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ ២០១៨ និងចំនួន ១០ បន្ថែមទៀតនៅក្នុងឆ្នាំ ២០១៩ ។ រីឯក្រសួង ស្ថាប័ន នៅសល់នឹងត្រូវដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ ២០២០ ។

ទោះបីជាយ៉ាងនេះក្តី, មូលដ្ឋាននៃប្រភពចំណូលនៅជាកត្តាព្រួយបារម្ភសម្រាប់រក្សាចីរភាពនៃកំណើនសេដ្ឋកិច្ច ខណៈដែលការប្រមូលចំណូលធៀបនឹងផែនការដែលបានដាក់ចេញ នៅពុំទាន់ត្រូវបានធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពទាំងក្របខណ្ឌនៃការព្យាករ និងសក្តានុពល ឬ លទ្ធភាពនៃការកៀរគរចំណូល ។ មូលដ្ឋានពន្ធនៅមានភាពតូចចង្អៀតជាមួយនឹងការថមថយនៃពន្ធប្រយោល ព្រមទាំងពន្ធពាណិជ្ជកម្មអន្តរជាតិកំពុងរងសម្ពាធ នៅពេលដែលប្រទេសកម្ពុជាកំពុងពង្រីកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសជាច្រើន ។ ការកើនឡើងនៃពន្ធផ្ទាល់នៅមានចំនួនតិចតួច ។ ពន្ធលើប្រាក់ចំណូលដែលត្រូវការក្របខណ្ឌច្បាប់ច្បាស់លាស់ និងវប្បធម៌ល្អក្នុងការបង់ពន្ធនៅមិនទាន់ត្រូវបានរៀបចំពេញលេញនៅឡើយ ។ ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅមិនទាន់អនុម័ត ។ រីឯការអនុវត្តប្រព័ន្ធលទ្ធកម្មសាធារណៈ និងការគ្រប់គ្រងការវិនិយោគសាធារណៈ ទើបត្រូវបានរៀបចំជាយុទ្ធសាស្ត្រនៃការកែទម្រង់ ។ សារាចរណែនាំស្តីពីការផ្លាស់ប្តូរ ចែករំលែកទិន្នន័យ និងព័ត៌មាន រវាងអគ្គនាយកដ្ឋានពន្ធដារ, និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ដែលអគ្គនាយកដ្ឋានគោលនយោបាយទទួលបន្ទុកបូកសរុបត្រូវបានរៀបចំ ប៉ុន្តែការអនុវត្តនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ ។ ទន្ទឹមនឹងនេះ វិស័យមូលបត្ររដ្ឋ នៅមិនទាន់មានក្របខណ្ឌគោលនយោបាយ និងយន្តការ និងនីតិវិធីនៃការបោះផ្សាយមូលបត្រ ខណៈដែលយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ដែលបានគ្រោងរៀបចំចាប់តាំងពីឆ្នាំ ២០១៧ មក មិនទាន់ត្រូវបានរៀបចំបញ្ចប់នៅឡើយ តម្រូវឱ្យមានកិច្ចសហការបន្ថែម ។ ដោយឡែកបំណុលកកស្ទះគិតត្រឹមរយៈពេល ៦០ថ្ងៃ គឺមានវឌ្ឍនភាពល្អប្រសើរ ដោយគិតត្រឹមអាណត្តិចូលដល់អគ្គនាយកដ្ឋាន

[1] *លើសជាង ១០ ដង នៃគោលដៅដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩ ៣ ពិន្ទុភាគរយនៃ,២០២៣ ខណៈគោលដៅត្រឹម ០-៨.ស.ស.*

[2] *ការគិតរយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីពេលអាណត្តិបើកផ្តល់ប្រាក់ត្រូវបានបញ្ជូន និងចុះកាលបរិច្ឆេទលើអាណត្តិដែលចូលមកអគ្គនាយកដ្ឋានរតនាគារជាតិ*

រតនាគារជាតិ ក៏ប៉ុន្តែរយៈពេល ៦០ថ្ងៃនេះ គួរគិតរាប់ចាប់ពីពេលចេញអាណត្តិរបស់អ្នកផ្គត់ផ្គង់រហូតដល់ការទូទាត់ ប៉ុន្តែបើគិតតាមស្តង់ដារអន្តរជាតិ បំណុលកកស្ទះគឺមានរយៈពេលត្រឹមតែ ៣០ថ្ងៃ ។ រីឯ ការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័ន ហាក់ដូចជាមានភាពមមាញឹកនៅចុងត្រីមាសទី ៤ នៃឆ្នាំនីមួយៗ ។ ប៉ុន្តែកិច្ចការនេះត្រូវបានដោះស្រាយជាបណ្តើរៗ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានកិច្ចសហការពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

***-ផ្នែកទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"*** *÷ មានគោលបំណងចំនួន ៥ រួមមាន (១). ចំណាត់ថ្នាក់ថវិកា, (២). ការអនុវត្តប្រព័ន្ធ FMIS, (៣). ស្តង់ដារគណនេយ្យសាធារណៈ, (៤). ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, និង (៥). សន្ទស្សន៍នៃការបើកចំហព័ត៌មានថវិកា ។* ក្នុងនោះ ការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ថវិកា ប្លង់គណនី និងដំណើរការប្រព័ន្ធ FMIS ទាំងដំណាក់កាលទី ១ និងដំណាក់កាលទី ២ សម្រាប់ជាមូលដ្ឋាននៃការកត់ត្រា និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា សម្រេចបានវឌ្ឍនភាពល្អប្រសើរ និងស្របតាមស្តង់ដារអន្តរជាតិ ។ ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន, រតនាគាររាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ។ ចំណាត់ថ្នាក់ថវិកាទាំង ៧ ត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងប្រព័ន្ធ FMIS ។ ប៉ុន្តែចំណាត់ថ្នាក់ភូមិសាស្ត្រ និងចំណាត់ថ្នាក់មុខងារ មិនទាន់បានអនុវត្តពេញលេញនៅឡើយ ។ បន្ថែមពីលើនេះ ម៉ូឌុលស្នូលចំនួន ៦ ត្រូវបានដាក់ឱ្យអនុវត្តក្នុងប្រព័ន្ធ FMIS រួមមាន (១) ម៉ូឌុលវិភាជន៍ថវិកា, (២) ម៉ូឌុលគណនីត្រូវសង, (៣) ម៉ូឌុលគណនីត្រូវទារ, (៤). ម៉ូឌុលគ្រប់គ្រងសាច់ប្រាក់ (៥) ម៉ូឌុលការទិញ និង (៦) ម៉ូឌុលសៀវភៅធំ ទន្ទឹមនឹងការអភិវឌ្ឍម៉ូឌុលពីរបន្ថែមទៀតគឺម៉ូឌុលរៀបចំផែនការថវិកា និងម៉ូឌុលកិច្ចលទ្ធកម្មពេញលេញ ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ហៅកាត់ថា SARMIS គ្រោងដាក់ឱ្យអនុវត្តជាបណ្តើរៗនៅរដ្ឋបាលថ្នាក់ជាតិនៅឆ្នាំ២០២១ និងជាបន្តបន្ទាប់រហូតដល់គ្រប់រដ្ឋបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រឹមឆ្នាំ២០២១ ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំ ដោយមានអនុលោមភាពជាមួយនឹង IPSAS Cash Basis ។ ជាមួយគ្នានេះ ស្តង់ដារគណនេយ្យសាធារណៈកម្ពុជា ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាមួយនឹងផែនទីចង្អុលផ្លូវ សម្រាប់ឆ្ពោះទៅអនុវត្តគណនេយ្យបង្គរនៅឆ្នាំ ២០៣១ (IPSAS Accrual Basis) ។ វេទិកាសាធារណៈស្តីពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌគ្រប់គ្រងថវិកាត្រូវបានរៀបចំជារៀងរាល់ឆ្នាំ ដើម្បីបង្កើនការចូលរួមពីសាធារណជន ។ ការផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងព័ត៌មានថវិកាដល់សាធារណជន មានវឌ្ឍនភាពល្អពីមួយឆ្នាំទៅមួយឆ្នាំ និងធ្វើឱ្យពិន្ទុសន្ទស្សន៍នៃការបើកចំហថវិការបស់កម្ពុជាកើនឡើងជាលំដាប់នៅក្នុងការអង្កេតលើការបើកចំហព័ត៌មានថវិកាជាសកល ដែលត្រូវបានរៀបចំរៀងរាល់ ២ ឆ្នាំម្តង ក្នុងនោះឆ្នាំ ២០០៨ ទទួលបាន ១១ ពិន្ទុ, ឆ្នាំ ២០១០ ទទួលបាន ១៥ ពិន្ទុ, ឆ្នាំ ២០១២ ទទួលបាន ១៥ ពិន្ទុ, ឆ្នាំ ២០១៥ ទទួលបាន ៨ ពិន្ទុ, ឆ្នាំ ២០១៧ ទទួលបាន ២០ ពិន្ទុ និងឆ្នាំ ២០១៩ ទទួលបាន ៣២ ពិន្ទុ ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល (DMFAS) និងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA) ត្រូវបានធ្វើសន្ទានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ។

ទោះបីជាយ៉ាងនេះក្តី, ការអនុវត្តប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមិនទាន់បានដាក់ឱ្យអនុវត្តពេញលេញតាមក្រសួង ស្ថាប័ន នៅឡើយ ។ ការរៀបចំរបាយការណ៍អនុវត្តថវិកាតាមចំណាត់ថ្នាក់ថវិកាទាំង ៧ នៅមានកម្រិត ដោយសាររបាយការណ៍តាមចំណាត់ថ្នាក់នីមួយៗ មិនទាន់មានសង្គតិភាពនឹងគ្នា និងអនុវត្តបានពេញលេញតែ ៥ ចំណាត់ថ្នាក់ ទន្ទឹមនឹងចំណាត់ថ្នាក់ភូមិសាស្ត្រ និងចំណាត់ថ្នាក់មុខងារ កំពុងបន្តជំរុញការអនុវត្ត ។ ជាមួយគ្នានេះផងដែរ ទិន្នន័យ

ដកស្រង់ចេញពីប្រព័ន្ធ FMIS នៅមិនទាន់អាចប្រើប្រាស់ សម្រាប់រៀបចំរបាយការណ៍សម្រេចទូទាត់បាន ដោយតម្រូវឱ្យអគ្គនាយកដ្ឋានរតនាគារជាតិធ្វើការកែតម្រូវសិន ទើបអាចរៀបចំរបាយការណ៍ដែលអាចប្រើប្រាស់បាន ។ ការផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងព័ត៌មានថវិកាមានវឌ្ឍនភាពល្អ ក៏ប៉ុន្តែមិនទាន់មានអនុលោមភាពល្អជាមួយនឹងការអង្កេតរបស់ IBP និងផ្តល់ភាពសាមញ្ញសម្រាប់សាធារណជន ខណៈដែលការចូលរួមពីសាធារណជនក្នុងដំណើរការរៀបចំថវិកានៅមានវឌ្ឍនភាពតិចតួចនៅឡើយ ។ រីឯ គ្រឹះស្ថានសាធារណៈរដ្ឋបាលវិញ នៅពុំទាន់អាចរៀបចំរបាយការណ៍អនុវត្តតាមមាតិកាថវិការដ្ឋបាននៅឡើយ ។

***-ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"*** *÷ មានគោលបំណងចំនួន ៤ រួមមាន (១).ការអនុវត្តថវិកាកម្មវិធី, (២).ការរៀបចំថវិកាឱ្យមានភាពគ្រប់ជ្រុងជ្រោយ, (៣).ការរៀបចំក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម, និង (៤).ការរៀបចំក្របខណ្ឌវិមជ្ឈការហិរញ្ញវត្ថុ ។* ក្នុងនោះ លិខិតបទដ្ឋានគតិយុត្ត និងយុទ្ធសាស្ត្រគន្លឹះៗជាច្រើនត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តក្នុងដំណាក់កាលទី ៣ ដើម្បីពង្រឹងការអនុវត្តសកម្មភាពសម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។ ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ថ្មី) និងអនុក្រឹត្យពាក់ព័ន្ធដែលកំពុងរៀបចំ គឺជាគតិយុត្តដ៏សំខាន់ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធថវិកាថ្មី ។ គិតត្រឹមឆ្នាំ ២០១៨ គ្រប់ក្រសួង ស្ថាប័ន បានអនុវត្តថវិកាកម្មវិធី និងគិតត្រឹមឆ្នាំ ២០២០ រដ្ឋបាលខេត្តចំនួន ២៤ បានអនុវត្តថវិកាកម្មវិធី ដែលរដ្ឋបាលរាជធានីភ្នំពេញនឹងត្រូវអនុវត្តចុងក្រោយគេនៅឆ្នាំ ២០២១ ។ សរុបត្រឹមដំណាក់កាលទី ៣ អង្គភាពថវិកាមានចំនួន ៩៦២ ក្នុងនោះថ្នាក់កណ្តាលមានចំនួន ៣៥៩ និងថ្នាក់មូលដ្ឋានមានចំនួន ៦៦៤ ។ ទន្ទឹមនឹងនេះ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំដោយកំណត់នូវគោលបំណងគោលនយោបាយ និងកម្មវិធី និងរំលេចអំពីខ្លឹមសារនៃគោលបំណង និងសនិទានកម្ម, ប្រភេទហិរញ្ញប្បទាន, សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់តាមដានការអនុវត្ត និងការត្រួតពិនិត្យលទ្ធផល, គោលដៅសមិទ្ធកម្ម, ក្របខណ្ឌពេលវេលា និងតម្រូវការថវិកា ជាពិសេស ការរៀបចំត្រូវបានផ្អែកលើពិតានចំណាយដូចកំណត់នៅក្នុងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង និង ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ដោយសារការរៀបចំ MTFF ត្រូវបានពន្យារពេល ។ ចំពោះការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធនត្រូវបានរៀបចំជាសេចក្តីព្រាងឯកសារទស្សនាទាន ។ ការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុសម្រេចបានលទ្ធផលល្អ ដោយបានរៀបចំជាសកម្មភាពមួយឆ្នាំម្តងៗ និងជាដំណាក់ៗ សម្រាប់អនុវត្ត ។ បន្ថែមពីលើនេះ ការដាក់ឱ្យអនុវត្តយុទ្ធ-សាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ បានក្លាយជាផែនទីចង្អុលផ្លូវនៃការពង្រឹងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ។

ទោះបីជាយ៉ាងនេះក្តី, យន្តការតាមដានការវាយតម្លៃលើការអនុវត្តថវិកាកម្មវិធីនៅមិនទាន់បានពង្រឹងនៅឡើយ ។ អង្គភាពថវិកាថ្នាក់កណ្តាលចំនួន ៣៥៩ មានអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធមានត្រឹមចំនួន ៦១ និងមិនទាន់ផ្ទេរសិទ្ធិមានចំនួន ២៥០ ។ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ន នៅមានបញ្ហាលើការកំណត់គោលបំណងគោលនយោយបាយ, រចនាសម្ព័ន្ធកម្មវិធី និងស្ថាប័ន, និងសូចនាករគន្លឹះទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ កង្វះនូវការវិភាគហានិភ័យគោលនយោបាយហិរញ្ញវត្ថុ (Policy Risk) និងយន្តការ, ក្របខណ្ឌ ឬនីតិវិធីនៃការវិភាគហានិភ័យហិរញ្ញវត្ថុ អាចជាបញ្ហាប្រឈមសម្រាប់ការរៀបចំ MTFF ឱ្យកាន់តែមានប្រសិទ្ធភាព ។

ការដាក់ឱ្យអនុវត្តក្របខណ្ឌ MTFF និង MTBF ត្រូវបានពន្យារពេល ។ រីឯការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាពរវាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ, រវាងក្រសួងសេដ្ឋកិច្ច និងក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង ស្ថាប័ន នៅពុំទាន់មានយន្តការកំណត់ឱ្យបានល្អនៅឡើយ ។

***-ផ្នែកទី៤ "ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់"*** *÷ មានគោលបំណងចំនួន ៤ រួមមាន (១).ក្របខណ្ឌថវិកាព័តិមានសមិទ្ធកម្ម, (២).ក្របខណ្ឌការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម, (៣).ក្របខណ្ឌសវនកម្មពេញលេញ (សមិទ្ធកម្ម, ព័ត៌មានវិទ្យា, អនុលោមភាព និងហិរញ្ញវត្ថុ), និង (៤).ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤* ។ វឌ្ឍនភាពនៃផ្នែកទី ៤ នេះ មិនទាន់មានភាពល្អប្រសើរក្នុងរយៈពេលពីរឆ្នាំដំបូង ក៏ប៉ុន្តែបច្ចុប្បន្នមានវឌ្ឍនភាពល្អប្រសើរបន្ទាប់ពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ត្រូវបានដាក់ឱ្យអនុវត្តដោយកំណត់យកប្រព័ន្ធ "ថវិកាព័ត៌មានសមិទ្ធកម្ម" ជាទិសដៅជាក់លាក់នៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ។ ក្នុងន័យនេះ, គោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្មទាំងសវនកម្មផ្ទៃក្រៅ[3] និងសវនកម្មផ្ទៃក្នុង[4] និងគោលការណ៍ណែនាំសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។ គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្មត្រូវបានរៀបចំ ។ រីឯទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម, គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម និងក្របខណ្ឌទស្សនាទានស្តីពីការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម ក៏ត្រូវបានរៀបចំជាសេចក្តីព្រាងផងដែរ ។ ទន្ទឹមនឹងនេះ ផែនការយុទ្ធសាស្ត្រកសាងសមត្ថភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីកសាងធនធានមនុស្ស និងសមត្ថភាពរបស់ស្ថាប័ន ក្នុងការគាំទ្រដល់ការប្រែប្រួលនូវការអនុវត្តការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះវគ្គបណ្តុះបណ្តាលចំនួន ២១០វគ្គ ត្រូវបានរៀបចំជូនមន្ត្រីរាជការប្រមាណ ១៥,០៩២ នាក់ ។

ទោះបីជាយ៉ាងនេះក្តី, សវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៅតាមក្រសួង ស្ថាប័ន នៅតែជាការប្រឈមដែលត្រូវដោះស្រាយ ដោយសារកង្វះទស្សនាទានក្នុងបែងចែកតួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងយន្តការសម្របសម្រួល ។ ជាក់ស្តែង ការរៀបចំអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីអធិការកិច្ចហិរញ្ញវត្ថុត្រូវបានពន្យារពេលក្នុងការរៀបចំ ដែលតម្រូវឱ្យមានការសម្របសម្រួលរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឬការសម្រេចកម្រិតនយោបាយបន្ថែមទៀត ។ វគ្គបណ្តុះបណ្តាលជាច្រើនត្រូវបានរៀបចំឡើង ក៏ប៉ុន្តែការតាមដាន និងវាយតម្លៃលើលទ្ធផលរយៈពេលខ្លី មធ្យម និងវែង នៃវគ្គបណ្តុះបណ្តាលទាំងនោះនៅមិនទាន់បានគិតគូរនៅឡើយ ។ ជាមួយគ្នានេះ ការរៀបចំកសាងសមត្ថភាពសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ ក៏មិនទាន់ត្រូវបានអនុវត្តតាមការគ្រោង ដោយសារមានលក្ខណៈពុំសមស្របលើយន្តការស្ថាប័ន ។ រីឯការរៀបចំក្របខណ្ឌសម្រាប់អនុវត្ត និងត្រួតពិនិត្យថវិកាព័ត៌មានសមិទ្ធកម្មនៅមិនទាន់សម្រេចបានតាមផែនការដែលបានកំណត់ ។ ការរៀបចំច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យពាក់ព័ន្ធសម្រាប់ការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មមានការពន្យារពេល ។

---

[3] រៀបចំដោយ អាជ្ញាធរសវនកម្មជាតិ

[4] រៀបចំដោយ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃកសហវ

***-ផ្នែកទី៥ "ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ÷*** *មានគោលបំណងចំនួន ៥ រួមមាន (១).ភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រង, ឆន្ទៈ, ភាពជាម្ចាស់ និងការទទួលខុសត្រូវសមស្របនឹងកម្មវិធីកែទម្រង់, (២).ការបណ្តុះបណ្តាលសមស្រប និងប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព, (៣).ការផ្តល់ការលើកទឹកចិត្តសមស្រប និងប្រកបដោយផលិតភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព, (៤).គ្រប់ក្រសួង ស្ថាប័ន មានសមត្ថភាពសមស្របសម្រាប់ចូលរួមក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព, និង (៥). យន្តការ នីតិវិធីនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង ស្ថាប័នត្រូវបានអនុវត្ត* ។ ការវាយតម្លៃផ្នែកទី ៥ នេះ ត្រូវបានប្តូរមកផ្តោតលើការគ្រប់គ្រងយន្តការការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យន្តការលើកទឹកចិត្ត និងប្រភពហិរញ្ញវត្ថុ, និងយន្តការអន្តរការដ្ឋានកែទម្រង់ ។ ជាលទ្ធផលកិច្ចប្រជុំត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួមរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ត្រូវបានរៀបចំជាប្រចាំត្រីមាស និងប្រចាំឆ្នាំ ។ ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវបានបើកផ្តល់ប្រចាំខែជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន ។ ទន្ទឹមនេះ យន្តការអន្តរការដ្ឋានកម្មវិធីកែទម្រង់ទាំង ៣ របស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំ និងអនុវត្តចាប់ពីឆ្នាំ ២០១៦ និងបន្ទាប់មកមានការសម្រេចកម្រិតនយោបាយក្នុងការបញ្ចូលកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ទៅក្នុងយន្តការដែលមានស្រាប់ និងក្លាយជាយន្តការកម្មវិធីកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល ។ ការអនុវត្តសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង ស្ថាប័ន នៅតែជាបញ្ហាប្រឈមក្នុងការវាយតម្លៃ ។

ទោះបីជាយ៉ាងនេះក្តី, សមាសភាពទទួលបានប្រាក់ឧបត្ថម្ភកែទម្រង់នៅតាមក្រសួង ស្ថាប័ន សង្កេតឃើញថាមានការផ្លាស់ប្តូរញឹកញាប់ និងត្រូវបានរៀបចំតាមបែបផែនដឹកនាំដោយឡែកៗពីគ្នា ដែលសុទ្ធសឹងជាបច្ច័យលើវឌ្ឍនភាពការងារកែទម្រង់នៃស្ថាប័ន។ លើសពីនេះ សមិទ្ធកម្មនៃការអនុវត្តការងារកែទម្រង់ នៅពុំទាន់ក្លាយជាមូលដ្ឋានគ្រប់ជ្រុងជ្រោយសម្រាប់ផ្សារភ្ជាប់នឹងការបើកផ្តល់ប្រាក់ឧបត្ថម្ភការលើកទឹកចិត្តនៅឡើយ ។រីឯកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកែទម្រង់ផ្សេងៗរបស់រាជរដ្ឋាភិបាលនៅពុំទាន់មានចក្ខុវិស័យ ឬ យុទ្ធសាស្ត្រដើម្បីផ្សារភ្ជាប់គ្នានៅឡើយ ដែលធ្វើឱ្យដំណើរនៃការអនុវត្តការងារកែទម្រង់មានល្បឿនខុសៗគ្នា និងពុំទាន់បំពេញឱ្យគ្នាទៅវិញទៅមកបានគ្រប់ជ្រុងជ្រោយ ។ ហេតុដូច្នេះ ទើបនាំឱ្យមានការផ្តួចផ្តើម និងឯកភាពពីសំណាក់ថ្នាក់ដឹកនាំការដ្ឋានកែទម្រង់ទាំង ៤ ក្នុងការកសាងឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាលរយៈពេល ១០ឆ្នាំ ដែលអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងសម្របសម្រួលបញ្ចប់ការរៀបចំឯកសារទស្សនាទានលើកិច្ចការនេះត្រឹមឆ្នាំ ២០២១ និងឈានទៅរៀបចំ និងបញ្ចប់ឯកសារចក្ខុវិស័យ និងយុទ្ធសាស្ត្រមុនឆ្នាំ ២០២៣ ។

### *ហានិភ័យ និងបច្ច័យលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់*

***ការកើនឡើងនៃគម្លាតអនុវត្ត ÷*** យុទ្ធសាស្ត្រកែទម្រង់ដែលបានរៀបចំឡើងថ្មីៗ នៅក្នុងដំណាក់កាលទី ៣ នៃ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងធ្វើឱ្យ "គម្លាតអនុវត្តដែលមាននាពេលកន្លងមកកាន់តែមានគម្លាត

ធិបន្ថែមទៀត” ពីព្រោះការអនុវត្តអាចនឹងជួបនូវបញ្ហាកង្វះការគ្រប់គ្រង និងសមត្ថភាពជំនាញ ក្នុងការរៀបចំ និងអនុវត្តសកម្មភាពគន្លឹះៗ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រកែទម្រង់ថ្មីៗទាំងនោះ ។

***អាទិភាវូបនីយកម្មសកម្មភាពកែទម្រង់*** ÷ ការកំណត់ឱ្យបានហ្មត់ចត់លើសកម្មភាពអាទិភាពនៃកម្មវិធីកែទម្រង់ ដោយគិតគូរពីសកម្មភាពដែលត្រូវអនុវត្តមុន និងសកម្មភាពត្រូវអនុវត្តបន្តបន្ទាប់ ។ ទន្ទឹមនឹងនេះ ការអនុវត្តសកម្មភាពអាទិភាពនៅក្នុងដំណាក់កាលនីមួយៗ ត្រូវតែធានាថាបានសម្រេចនូវ “មូលដ្ឋានគ្រឹះ” ជាមុនសិន មុននឹងឈានទៅបន្តអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីកែទម្រង់ ។

***ភាពប្រទាក់ក្រឡាគ្នានៃសកម្មភាពកែទម្រង់គួរត្រូវធ្វើការត្រួតពិនិត្យឱ្យបានហ្មត់ចត់ ÷*** សកម្មភាពអាទិភាពនៃកម្មវិធីកែទម្រង់ជាច្រើនមានការផ្សារភ្ជាប់គ្នា ឬ លក្ខណៈជាសកម្មភាពបើកផ្លូវឱ្យសកម្មភាពដទៃទៀតអាចអនុវត្តបាន ។ ដូច្នេះ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការតាមដាន និងគ្រប់គ្រងហានិភ័យ, សកម្មភាពដែលមានភាពប្រទាក់ក្រឡាគ្នាទាំងនោះត្រូវពិនិត្យ និងវាយតម្លៃឱ្យបានហ្មត់ចត់ ។

***កត្តាខាងក្រៅ*** ÷ សមាសភាពសំខាន់ៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺបានជួយគាំទ្រដល់ការសម្រេចបាននូវវឌ្ឍនភាពនៅក្នុងកម្មវិធីកំណែទម្រង់ជាតិដទៃទៀត ។ ជាក់ស្តែង តាមរយៈការខិតខំពង្រឹងការអនុវត្តគណនេយ្យភាពសមិទ្ធកម្ម និងការរួមចំណែកគាំទ្រជាជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ បានរួមចំណែកគាំទ្រដល់វឌ្ឍនភាពនៃកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ។

## *បទពិសោធន៍នៃការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣*

មេរៀនបទពិសោធទទួលបានពីការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ត្រូវបានពិនិត្យមើលក្នុងទិដ្ឋភាពចំនួន ៤ ខាងក្រោម ÷

**១-សមាសធាតុមិនមែនបច្ចេកទេសនៃកំណែទម្រង់** ÷ ការផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន, និងការលើកទឹកចិត្ត នៅជាបញ្ហាប្រឈមដ៏ចម្បង ។ ជាក់ស្តែង ការអភិវឌ្ឍធនធានមនុស្សត្រូវបានធ្វើឡើងតាមទម្រង់ជាការបណ្តុះបណ្តាល និងសិក្ខាសាលា ក៏ប៉ុន្តែ ការអភិវឌ្ឍស្ថាប័ន និងការលើកទឹកចិត្ត ដូចជាមិនទាន់មានភាពរឹងមាំនៅឡើយ ។

**២-យន្តការសម្របសម្រួល** ÷ យន្តការសម្របសម្រួលនៅតែជាបញ្ហាប្រឈមចម្បង សម្រាប់អង្គភាពអនុវត្តការងារកែទម្រង់ ដោយហេតុថាអង្គភាពមួយចំនួនធំនៅតែទាមទារការជំរុញពីថ្នាក់ដឹកនាំជាន់ខ្ពស់ ។

**៣-ការតាមដាន និងវាយតម្លៃ ÷** ការត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្ត GDAP3 និង MAP3 ផ្តោតលើការអនុវត្តសកម្មភាព ។ ការអនុវត្តគួរបន្តពង្រឹងក្របខណ្ឌតាមដាន និងវាយតម្លៃ និងផ្តោតលើការរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ ដែលមានបច្ច័យលើសកម្មភាពដែលបានគ្រោង ក៏ដូចជាប្រសិទ្ធភាពនៃការតាមដានសមិទ្ធកម្មតាមរយៈកិច្ចប្រជុំគណៈកម្មការ/គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈ និង/ឬកិច្ចប្រជុំក្រុមការងារបច្ចេកទេសជាប្រចាំត្រីមាស និងប្រចាំឆ្នាំ ។ ការតាមដានគួរផ្តោតលើការពិនិត្យលើសូចនាករគន្លឹះដែលសម្រេចបានដោយផ្ទៀងផ្ទាត់ជាមួយឯកសារយោងបញ្ជាក់ ។

**៤-ភាពប្រទាក់ក្រឡាគ្នានៃការទម្រង់ផ្សេងទៀត** ÷ មិនទាន់មានក្របខណ្ឌប្រទាក់ក្រឡាមួយរវាងការដ្ឋាននៃការកែទម្រង់ផ្សេងទៀត ដើម្បីធានាការបោះជំហានស្របនឹងគ្នា ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃកំណែទម្រង់អភិបាលកិច្ចស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ។

## *Implication សម្រាប់ការរៀបចំផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២ ឆ្នាំ២០២១-២០២២*

ការវាយតម្លៃបង្ហាញថា ការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោល-នយោបាយ” សម្រេចបានវឌ្ឍនភាពល្អប្រសើរ បើទោះបីជានៅមានបញ្ហាលើគុណភាពសមិទ្ធកម្ម ក៏ប៉ុន្តែអាចបន្តកែលម្អជាបន្តបន្ទាប់ និងធ្វើការពន្យារពេលការអនុវត្តលើសកម្មភាពមួយចំនួនដែលរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ផ្អែកលើមូលដ្ឋាននៃលទ្ធផលវាយតម្លៃនេះ រាជរដ្ឋាភិបាលសម្រេចបន្តអនុវត្ត CAP3 រយៈពេល ២ឆ្នាំទៀត ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំងបីខាងដើម មុននឹងឈានទៅខឿនទី ៤ ចុងក្រោយ ។ ដំណាក់កាលអន្តរកាលឆ្ពោះទៅដំណាក់កាលទី ៤ មានគោលដៅសំខាន់ឆ្ពោះទៅកសាងនូវលក្ខខណ្ឌចាំបាច់ទាំងឡាយដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាងនូវ “វប្បធម៌សមិទ្ធកម្ម” នៅក្នុងក្របខណ្ឌរដ្ឋាភិបាលទាំងមូល និងបន្តការអនុវត្តអភិក្រមតាមខឿនដដែល ។ ជាមួយគ្នានេះ ការរៀបចំក្របខណ្ឌផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២ ឆ្នាំ២០២១-២០២២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយមិនរក្សាទម្រង់ CAP3 ទៀតទេ គឺរៀបចំកែសម្រួលជាថ្មី ដោយបែងចែកគោលបំណងច្បាស់លាស់ផ្នែក/ខឿនទីមួយៗ ។

**អ.គ.ហ.** នឹងកែសម្រួលដោយបង្រួមគោលបំណងមួយចំនួនដែលស្រដៀងគ្នា, បង្កើតថ្មី, និងផ្លាស់ប្តូរទៅផ្នែកផ្សេង ។ ការបង្កើតគោលបំណង ឬ ចង្កោមសកម្មភាពថ្មី នឹងត្រូវធ្វើឡើងដោយផ្អែកលើយុទ្ធសាស្ត្រគន្លឹះៗដែលបានរៀបចំ និងដាក់ឱ្យអនុវត្តនៅក្នុងដំណាក់កាលទី ៣ នេះ រួមមាន យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសារធារណៈ ២០១៩-២០២៥, និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ព្រមទាំងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ។ ទន្ទឹមនឹងនេះ, **អ.គ.ហ.** នឹងតម្រង់ការផ្លាស់ប្តូរពី “ជំហាន” មកជាការពង្រឹង និងកសាង “ខឿន” ទីមួយៗ ដែលជាសរសស្តម្ភនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយតម្រឹមទៅនឹងក្របខណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ។

ក្នុងន័យនេះ ការរៀបចំផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២ ឆ្ពោះទៅដំណាក់កាលទី ៤ នឹងត្រូវសម្រួចលើចំណុចសំខាន់ៗ ដូចខាងក្រោម ÷

❖ **<u>ខឿន/ផ្នែកទី ១ “ការបន្តពង្រឹងការជឿទុកចិត្តលើថវិកា”</u>** ÷ ផ្តោតយកចិត្តទុកដាក់លើ (ទី១) ការធ្វើពិពិធកម្មប្រភពចំណូល នៅក្នុងបរិការណ៍ជំងឺកូវីដ-១៩ ដែលមានបច្ច័យលើផ្នែកចំណូល, (ទី២) ការពន្លឿននីតិវិធីចំណាយ និងការទូទាត់ ដើម្បីឆ្លើយតបបានទាន់ពេលទៅនឹងអាទិភាពថ្មីៗ, (ទី៣) ការជំរុញការគ្រប់គ្រងវិនិយោគ សាធារណៈ, និង (ទី៤) ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ។

❖ **ខឿន/ផ្នែកទី ២ "ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"** ÷ ផ្តោតយកចិត្តទុកដាក់លើ (ទី១) អនុវត្តពេញលេញនូវចំណាត់ថ្នាក់នៃមាតិកាថវិកា និងពង្រីកការប្រើប្រាស់ប្លង់គណនេយ្យ, និង (ទី២) ការបន្តជំរុញការប្រើប្រាស់ប្រព័ន្ធ FMIS ក្នុងនោះមាន ការដោះស្រាយបញ្ហាបច្ចេកទេសក្នុងការអនុវត្តប្រព័ន្ធ FMIS ដែលមានស្រាប់, ការបន្តធ្វើសន្ធានកម្មជាមួយនឹងប្រព័ន្ធផ្សេងៗទៀត, ពង្រឹងមុខងារបន្ថែមនៃប្រព័ន្ធ រួមទាំងមុខងារធានាចំណាយ និងមុខងារផ្សេងៗទៀត, និងការជំរុញការប្រើប្រាស់ FMIS សម្រាប់ផលិតរបាយការណ៍តាមដាននៃអគ្គនាយកដ្ឋាន និងក្រសួងស្ថាប័ន ។

❖ **ខឿន/ផ្នែកទី៣ "ការពង្រឹងប្រសិទ្ធភាពផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** ÷ ផ្តោតយកចិត្តទុកដាក់លើ (ទី១) ដាក់ឱ្យអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងក្របខណ្ឌថវិការយៈពេលមធ្យម ជាពិសេសក្រោមបរិការណ៍កូវីដនៅពេលស្ថានភាពសេដ្ឋកិច្ចពុំមានភាពច្បាស់លាស់ និង ពុំអាចព្យាករណ៍បាន, (ទី២) ការពង្រឹងគុណភាពនៃថវិកាកម្មវិធី តាមរយៈការពង្រឹងគុណភាពសូចនាករ, ការពង្រឹងការគ្រប់គ្រងកម្មវិធី, ការរៀបចំអង្គភាពថវិកានៅថ្នាក់កណ្តាល, និងសមាហរណកម្មថវិកាចរន្ត និងវិនិយោគនៅក្រោមកម្មវិធីនីមួយៗ, និង (ទី៣) ការធ្វើសមាហរណកម្មនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាទៅនឹងការរៀបចំថវិកាកម្មវិធី ។

❖ **ខឿន/ផ្នែកទី ៤ "ការកសាងគណនេយ្យភាពសមិទ្ធកម្ម/ស្ថាប័នីយកម្មប្រព័ន្ធថវិកាពត៌មានសមិទ្ធកម្ម"** ÷ ផ្តោតយកចិត្តទុកដាក់លើ (ទី១) ដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម, ក្របខណ្ឌតាមដាន និងពិនិត្យការអនុវត្តថវិកា, ការរៀបចំទម្រង់របាយការណ៍អនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម, (ទី២) បញ្ចប់ការរៀបចំច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី និងអនុក្រឹត្យ ៨១ និង ៨២ សម្រាប់អនុវត្តប្រព័ន្ធថ្មី, (ទី៣) ការរៀបចំសេចក្តីព្រាងនៃគោលការណ៍សវនកម្មសមិទ្ធកម្ម និងការរៀបចំសាកល្បងធ្វើសវនកម្មផ្អែកលើសមិទ្ធកម្ម, និង (ទី៤) ការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ដំណាក់កាលទី ៤ ។

❖ **គាំទ្រ/ផ្នែកទី ៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត"** ÷ ផ្តោតយកចិត្តទុកដាក់លើ (ទី១) ការបន្តចីរភាពនៃការកែទម្រង់ តាមរយៈការកៀរគរធនធានដើម្បីអនុវត្តសកម្មភាពកែទម្រង់ ជំរុញការចូលរួម និងការតាមដានវឌ្ឍនភាពនៅក្នុងគ្រប់ស្ថានភាព, និង (ទី២) ការកំណត់ឱ្យបាននូវក្របខណ្ឌប្រទាក់ក្រឡាមួយរវាងការដ្ឋាននៃការកែទម្រង់ផ្សេងទៀត ដើម្បីធានាការបោះជំហានស្របជាបន្តបន្ទាប់នឹងគ្នាក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

ទន្ទឹមនេះ **អ.គ.ហ.** នឹងបន្តពង្រឹងការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ តាមរយៈ ÷

- រៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងប្រព័ន្ធតាមដានសមិទ្ធកម្ម
- តាមដានប្រចាំត្រីមាស និងត្រួតពិនិត្យប្រចាំឆ្នាំនៅកម្រិតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កិច្ចប្រជុំតាមដានវឌ្ឍនភាពប្រចាំឆ្នាំ ផ្តោតលើការវាយតម្លៃការសម្រេចបាននូវសូចនាករគន្លឹះនៅកម្រិតផ្នែក និងកម្រិតគោលបំណង
- វាយតម្លៃ PEFA, TADAT, PIMA និងការវាយតម្លៃពីភាគីខាងក្រៅ ។

## សេចក្តីសន្និដ្ឋាន

ជារួម ការអនុវត្តកម្មវិធីកែទម្រង់ដំណាក់កាលទី ៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” សម្រេចបានវឌ្ឍនភាពល្អប្រសើរ និងរក្សាបានចីរភាពនៃការងារកែទម្រង់ឆ្ពោះទៅកាន់គោលដៅដែលបានដាក់ចេញ បើទោះបីជាសកម្មភាពមួយចំនួនត្រូវបានពន្យារពេលអនុវត្តដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយ ។ បុរេលក្ខខណ្ឌនានាសម្រាប់ការអនុវត្តកម្មវិធី ដែលជាសមាសធាតុស្នូលនៃជំហានទី ៣ ត្រូវបានត្រៀមរៀបចំរួចរាល់ជាសារវ័ន្ត និងកំពុងមានវឌ្ឍនភាពក្នុងការធ្វើស្ថាប័ននីយកម្ម ។ ទន្ទឹមនឹងនេះ ក្រសួង ស្ថាប័នកាន់តែយល់ជ្រួតជ្រាប និងសម្របខ្លួនទៅនឹងទស្សនៈ និងគំនិតផ្តួចផ្តើម ជាពិសេស ទទួលស្គាល់ពីសារៈសំខាន់នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។ ទោះបីថានៅមានការងារមួយចំនួននៅសេសសល់មិនទាន់ចប់ និងការងារខ្លះត្រូវបានពន្យារពេល, ក៏ការងារទាំងនោះភាគច្រើននៅមានហានិភ័យទាប ។

ផ្អែកលើការវាយតម្លៃ រាជរដ្ឋាភិបាលសម្រេចបន្តអនុវត្ត CAP3 រយៈពេល ២ឆ្នាំទៀត ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំងបីខាងដើម មុននឹងឈានទៅខឿនទី ៤“គណនេយ្យភាពសមិទ្ធកម្ម” ។ ដំណាក់កាលអន្តរកាលឆ្ពោះទៅដំណាក់កាលទី ៤ មានគោលដៅសំខាន់ឆ្ពោះទៅកសាងនូវលក្ខខណ្ឌចាំបាច់ទាំងឡាយ ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាងនូវ “វប្បធម៌សមិទ្ធកម្ម” នៅក្នុងក្របខណ្ឌរដ្ឋាភិបាលទាំងមូល ។

សរុបសេចក្តីមក ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ សម្រេចបាននូវភាពជឿទុកចិត្តនៃថវិកាដែលរឹងមាំគ្រប់គ្រាន់, ឆ្អឹងខ្នងនៃគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានដាក់ឱ្យអនុវត្ត, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយសម្រេចបានជាសារវ័ន្ត និងមូលដ្ឋានសំខាន់នៃគណនេយ្យភាពសមិទ្ធកម្មត្រូវបានលេចចេញជារូបរាងជាបណ្តើរៗ ។

# ១. សេចក្តីផ្តើម

## ១.១. សាវតារ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តនៅខែធ្នូ ឆ្នាំ២០០៤ ក្នុងគោលដៅប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ដែលផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ និងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ។ ការងារនេះ ត្រូវបានរៀបចំសម្រាប់អនុវត្តដោយកសាងជាខឿនចំនួន ៤ ចែកជា ៤ ដំណាក់កាល ដូចខាងក្រោម ÷

- ខឿនទី ១ គឺ “**ភាពជឿទុកចិត្តបាននៃថវិកា**” ត្រូវបានអនុវត្តចាប់ពីចុងឆ្នាំ ២០០៤ ដល់ ឆ្នាំ ២០០៨ ។
- ខឿនទី ២ គឺ “**គណនេយ្យភាពហិរញ្ញវត្ថុ**” សម្រាប់ឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៥ ។
- ខឿនទី ៣ គឺ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ ។
- ខឿនទី ៤ គឺ “**គណនេយ្យភាពសមិទ្ធកម្ម**” ពីឆ្នាំ ២០២១ ដល់ ឆ្នាំ ២០២៥ ។

ក្រោមភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលទី ១ និងទី ២ សម្រេចបានវឌ្ឍនភាពល្អប្រសើរ ដោយកសាងបានខឿននៃ «ភាពជឿទុកចិត្តបាននៃថវិកា» និងខឿននៃ «គណនេយ្យភាពហិរញ្ញវត្ថុ» ។ បច្ចុប្បន្ននេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតនៅក្នុងដំណាក់កាលទី ៣ គឺការកសាងខឿនទី ៣ «ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ» ដោយគ្រោងនឹងបញ្ចប់នៅឆ្នាំ ២០២០ ។ ទន្ទឹមនឹងប្រទេសកម្ពុជាសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប កម្ពុជានៅបន្តប្រឈមនឹងបញ្ហាថ្មីៗបន្ថែមទៀត, ដែលការអនុវត្តដំណាក់កាលទី ៣ តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហការយ៉ាងជិតស្និទ្ធពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងអង្គភាពនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ។ នៅដំណាក់កាលទី ៣ នេះ, ការកសាងខឿនទី ៣ គឺផ្តោតលើការដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាកម្មវិធី, ការដាក់ឱ្យអនុវត្តអង្គភាពថវិកា, និងការរៀបចំក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខណ្ឌថវិការយៈពេលមធ្យម ។ ជាមួយគ្នានេះ ខឿនទី ១ ត្រូវបានពង្រឹងតាមរយៈការពង្រឹងការកៀរគរចំណូល និងការកែលម្អការគ្រប់គ្រងសាច់ប្រាក់ ។ រីឯ ខឿនទី ២ ត្រូវបានបន្តពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី ១ និងទី ២ ។

សកម្មភាពនៃការកែទម្រង់ទាំងអស់ត្រូវបានរៀបចំជា «ផែនការសកម្មភាពរួម» ដែលនឹងត្រូវបានអនុម័តដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាន ។ ផែនការសកម្មភាពរួមរំលេចពីគោលបំណង និងសូចនាករគន្លឹះនៃការកែទម្រង់តាមខឿននីមួយៗ ដែលអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន ត្រូវស្នើនូវសកម្មភាពកែទម្រង់ដែលខ្លួនគ្រោងនឹងអនុវត្ត ដើម្បីសម្រេចនូវគោលបំណងទាំងនោះ ។ យន្តការត្រួតពិនិត្យសមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំ ត្រូវបានរៀបចំដោយលេខាធិការដ្ឋាន ដោយផ្អែកលើសកម្មភាពដែលបានស្នើនៅក្នុងផែនការសកម្មភាពរួម ។

ផែនការសកម្មភាពរួម ដំណាក់កាលទី ៣ (CAP3) មានគោលបំណងកសាងខឿនទី ៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការត្រៀមខ្លួនសម្រាប់ខឿនទី ៤ ថវិកាព័ត៌មានសមិទ្ធកម្ម ក៏ដូចជាការពង្រឹងការអនុវត្តខឿនពីរ

ខាងដើម ។ ផែនការសកម្មភាពនេះត្រូវបានចាប់ផ្តើមអនុវត្តនៅឆ្នាំ ២០១៦ និងត្រូវបញ្ចប់នៅឆ្នាំ ២០២០ ។ នៅក្រោមផែនការសកម្មភាពនេះ, អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគ្រោងសកម្មភាពចំនួន ២ ០០០ ដែលក្នុងនោះ សកម្មភាពចំនួន ១ ៧៥០ ត្រូវបានបញ្ចប់ ។ សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ បានគ្រោងសកម្មភាពចំនួន ៤ ០០០ ដែលក្នុងនោះ សកម្មភាពចំនួន ៣ ៦០០ ត្រូវបានបញ្ចប់ ។ ទោះបីសកម្មភាពទាំងនោះត្រូវបានអនុវត្តរួចហើយក្តី ប៉ុន្តែសកម្មភាពមួយចំនួនត្រូវបានកែសម្រួលជាបន្តបន្ទាប់ ដើម្បីឆ្លុះបញ្ចាំងពីបញ្ហាប្រឈមក្នុងការអនុវត្ត ។ ជាក់ស្តែង គោលបំណងតាមផ្នែកខ្លះក៏ត្រូវបានកែសម្រួលជាបន្តបន្ទាប់ ។ ទោះបីជាការត្រួតពិនិត្យវឌ្ឍនភាពនៃកម្មវិធីកែទម្រង់ត្រូវបានធ្វើឡើងជាទៀងរាល់ឆ្នាំ, ការពិនិត្យឡើងវិញក្នុងក្របខណ្ឌផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ គឺដើម្បីប្រមូលផ្តុំនូវបទពិសោធន៍នៃការអនុវត្ត និងកែសម្រួលការយកចិត្តទុកដាក់បន្ថែម ក៏ដូចជាទិសដៅនៃការកែទម្រង់ជារួម ។

## ១.២. គោលបំណង

របាយការណ៍វាយតម្លៃការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ ត្រូវបានរៀបចំក្នុងគោលបំណងដើម្បីផ្តល់ព័ត៌មានជាមូលដ្ឋានដាក់ជូនគណៈកម្មាធិការដឹកនាំកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ធ្វើសេចក្តីសម្រេចចិត្តលើការឈានទៅអនុវត្តដំណាក់កាលទី ៤ គឺ «គណនេយ្យភាពសមិទ្ធកម្ម» ឬពន្យារពេលអនុវត្តដំណាក់កាលទី ៣ ដោយផ្តោតលើសកម្មភាពដែលនៅសេសសល់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ របាយការណ៍វាយតម្លៃនេះ ក៏ផ្តល់ជូនអ្នកពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនូវព័ត៌មានសំខាន់ៗនៃការងារដែលនៅសេសសល់ សម្រាប់ចាត់វិធានការជាក់ស្តែង ដើម្បីជំរុញការអនុវត្ត ។

## ១.៣. វិធីសាស្ត្រនៃការវាយតម្លៃ

វិធីសាស្ត្រវាយតម្លៃលើការអនុវត្តផែនការសកម្មភាពរួមនេះ គឺពឹងផ្អែកលើការរាយការណ៍ប្រចាំឆ្នាំពីគ្រប់អង្គភាពនៃ កសហវ លើការអនុវត្ត GDAP3 របស់ខ្លួន តាមរយៈការពិនិត្យមើលវឌ្ឍនភាពសំខាន់ៗនៃជំហាននីមួយៗ និង MAP3 របស់ក្រសួង ស្ថាប័ន ។ វិធីសាស្ត្រក្នុងការវាយតម្លៃ ១)-ពិនិត្យមើលការសម្រេចបាននូវគោលបំណងតាមថ្នាល និងគោលបំណងនីមួយៗ និង ២)-ពិនិត្យមើលការសម្រេចបានទាំងនោះបានក្លាយជាការងារប្រចាំ ដោយយកចិត្តទុកដាក់លើការរៀបចំយន្តការ, ប្រព័ន្ធការងារ, និងធនធាន ។

## ១.៤. បរិការណ៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងពេលអនុវត្ត CAP 3

ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី ២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រេចបានវឌ្ឍនភាពនៅផុយស្រួយនៅឡើយ ។ ជាក់ស្តែង ការអនុវត្តដំណាក់កាលទី ២នេះ បានពន្យារពេលអនុវត្តរយៈពេល ២ឆ្នាំ មុននឹងបន្តទៅអនុវត្តដំណាក់កាលទី ៣ ។ បញ្ហាប្រឈមនៅក្នុងការអនុវត្ត រួមមាន ÷ (១) កង្វះថវិកាដើម្បីគាំទ្រដល់ប្រតិបត្តិការប្រព័ន្ធ FMIS ដែលនឹងកែប្រែរបៀបប្រតិបត្តិការការងារ, រចនាសម្ព័ន្ធស្ថាប័ន, ការផ្លាស់ប្តូរការគ្រប់គ្រង, និងការអភិវឌ្ឍធនធានមនុស្សសម្រាប់ប្រព័ន្ធថ្មីនេះ, និង (២) វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកល បានផ្តល់នូវបច្ច័យអវិជ្ជមានដល់ការអនុវត្តចំណូល-ចំណាយ និងគោលនយោបាយថវិការបស់កម្ពុជា ជាពិសេសបានប៉ះពាល់ដល់ភាពជឿទុកចិត្តនៃថវិកា ។ បន្ថែមពីលើនេះ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈនៅទន់ ប្រឈមនឹងការកើនឡើងនូវតម្រូវការចំណាយ ដោយសារវិបត្តិព្រំដែនកម្ពុជា-ថៃ និងគ្រោះទឹកជំនន់ បានផ្តល់នូវបច្ច័យអវិជ្ជមានដល់គោលនយោបាយ

ចំណាយ និងប៉ះពាល់ស្ទូចនាករចំណាយសំខាន់ៗមួយចំនួន រួមមាន ភាពរលូននៃការអនុវត្តចំណាយក្នុងឆ្នាំដែលឆ្លុះបញ្ចាំងអំពីលទ្ធភាពដែលអាណាប័កអាចអនុវត្តចំណាយបានតាមកម្មវិធីចំណាយ និងការអនុវត្តចំណាយតាមប្រភេទ ។

ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ខាងលើនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាមទារនូវការកែទម្រង់ក្នុងសន្ទុះមួយថ្មី តាមរយៈការបន្តទៅរៀបចំផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ដោយបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុ ។

# ២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣

## ២.១. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទ កសហវ

*តារាងចំនួនសកម្មភាពដែលអង្គភាពក្រោមឱវាទ កសហវ បានគ្រោងអនុវត្តពីឆ្នាំ ២០១៦-២០២០*

| ផ្នែក | ឆ្នាំ២០១៦ | | | ឆ្នាំ២០១៧ | | | ឆ្នាំ២០១៨ | | | ឆ្នាំ២០១៩ | | | ឆ្នាំ២០២០ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គ្រោង | សម្រេច | ម/ពល | គ្រោង | សម្រេច | ម/ពល | គ្រោង | សម្រេច | ម/ពល | គ្រោង | សម្រេច | ម/ពល | គ្រោង | សម្រេច | ម/ពល |
| ផ្នែកទី ១ | ១០៣ | មម | មម | ១១០ | ៧០ | ៤០ | ១៣២ | ៩០ | ៤២ | ១២៣ | ៩៦ | ២៦ | ១៤១ | ១១០ | ៣១ |
| ផ្នែកទី ២ | ៨៧ | មម | មម | ៨៧ | ៧៥ | ១២ | ៧៤ | ៦០ | ១៤ | ៩៨ | ៨៧ | ១១ | ៩២ | ៨២ | ១០ |
| ផ្នែកទី ៣ | ៩៨ | មម | មម | ១២៩ | ១០៤ | ២៥ | ៧២ | ៦៤ | ៨ | ៧៧ | ៦២ | ១៥ | ៨០ | ៦៣ | ១៧ |
| ផ្នែកទី ៤ | ២០ | មម | មម | ១៥ | ៩ | ៦ | ៤០ | ៣៤ | ៦ | ៨៥ | ៧៨ | ៧ | ៦១ | ៤៣ | ១៨ |
| ផ្នែកទី ៥ | ៧៥ | មម | មម | ១០៥ | ៧៨ | ២៧ | ៩១ | ៧៧ | ១៤ | ៦២ | ៥៦ | ៦ | ៦១ | ៣៥ | ២៦ |
| សរុប | ៣៨៣ | ២៩៤ | ៨៩ | ៤៤៦ | ៣៣៦ | ១១០ | ៤០៩ | ៣២៥ | ៨៤ | ៤៤៥ | ៣៨០ | ៦៥ | ៤៣៥ | ៣៣៣ | ១០២ |

*ម/ពល = វឌ្ឍនភាពសម្រេចមិនពេញលេញ




ក្នុងចន្លោះឆ្នាំ ២០១៦-២០២០ អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគ្រោងសកម្មភាពក្នុងរង្វង់ ៤០០ នៃឆ្នាំនីមួយៗ ។ សកម្មភាពអនុវត្តសម្រេចមិនបានពេញលេញ បានធ្លាក់ចុះនៅក្នុងរយៈពេល ០២ ឆ្នាំចុងក្រោយគឺ ឆ្នាំ២០១៨-២០១៩ ដែលបង្ហាញពីការយកចិត្តទុកដាក់របស់តួអង្គអនុវត្តពីមួយឆ្នាំទៅមួយឆ្នាំ ។ នៅក្នុងឆ្នាំ២០២០ ខ្សែបន្ទាត់គ្រោងសកម្មភាព និងសកម្មភាពសម្រេចបានមានការងៀកចេញពីគ្នាបន្តិច ដោយសារសកម្មភាពដែលបានគ្រោង នៅក្នុងផ្នែកទី ៥ លើការបណ្តុះបណ្តាល និងសកម្មភាពនៅក្នុងផ្នែកផ្សេងទៀតមិនអាចអនុវត្តបាន ដោយសាររងផលប៉ះពាល់ពីការរីករាលនៃជំងឺកូវីដ-១៩ ។ ជារួម សកម្មភាពដែលបានគ្រោងក្នុងឆ្នាំនីមួយៗ នៅតែប្រមូលផ្តុំលើផ្នែកទី ១ ។

## ២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន

*តារាងចំនួនសកម្មភាពដែលក្រសួង ស្ថាប័ន បានគ្រោងអនុវត្តក្នុងពីឆ្នាំ ២០១៦-២០២០*

| ផ្នែក | ឆ្នាំ២០១៦ | | | ឆ្នាំ២០១៧ | | | ឆ្នាំ២០១៨ | | | ឆ្នាំ២០១៩ | | | ឆ្នាំ២០២០ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គ្រោង | សម្រេច | ម/ពល | គ្រោង | សម្រេច | ម/ពល | គ្រោង | សម្រេច | ម/ពល | គ្រោង | សម្រេច | ម/ពល | គ្រោង | សម្រេច | ម/ពល |
| ផ្នែកទី ១ | ២១០ | មម | មម | ១៧៣ | ១២០ | ៥៣ | ១៥៥ | ១៣១ | ២៤ | ១៥៥ | ១៣៥ | ២០ | | | |
| ផ្នែកទី ២ | ២៦៤ | មម | មម | ១៩២ | ១២៩ | ៦៣ | ១៨៣ | ១៦០ | ២៣ | ១៨៥ | ១៥៧ | ២៨ | | | |
| ផ្នែកទី ៣ | ២៨៣ | មម | មម | ៣១៤ | ២២៧ | ៨៧ | ១៦២ | ១៤២ | ២០ | ១៣១ | ១២០ | ១១ | | | |
| ផ្នែកទី ៤ | ១៩ | មម | មម | ៧ | ៦ | ១ | ១៣៩ | ១២២ | ១៧ | ១៤២ | ១២៨ | ១៤ | | | |
| ផ្នែកទី ៥ | ២៤៤ | មម | មម | ១៩៥ | ១៥០ | ៤៥ | ១៨៥ | ១៦១ | ២៤ | ១៤០ | ១២៩ | ១១ | | | |
| សរុប | ១០២០ | ៧៣៦ | ២៨៤ | ៨៨១ | ៦៣២ | ២៤៩ | ៨២៤ | ៧១៦ | ១០៨ | ៧៥៣ | ៦៦៩ | ៨៤ | ៩១៨ | ៧០៩ | ២០៩ |

*ម/ពល = វឌ្ឍនភាពសម្រេចមិនពេញលេញ




ការគ្រោងសកម្មភាពរបស់ក្រសួង ស្ថាប័ន មានអត្រាធ្លាក់ចុះជាបន្តបន្ទាប់ចាប់ពីឆ្នាំ ២០១៧ រហូតដល់ឆ្នាំ ២០១៩, ក៏ប៉ុន្តែ សកម្មភាពដែលអនុវត្តសម្រេចបានពេញលេញបានកើនឡើងនៅឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ ដែលបង្ហាញពីគុណភាពក្នុងរៀបចំគ្រោងសកម្មភាព និងអនុវត្តមានប្រសិទ្ធភាពល្អជាងមុន ។ រីឯក្នុងឆ្នាំ ២០២០ ការគ្រោងសកម្មភាពរបស់ក្រសួង ស្ថាប័ន មានការកើនឡើងប្រមាណជា ២០៩ ធៀបនឹងឆ្នាំ ២០១៩ ហើយសកម្មភាពសម្រេចមិនបានពេញលេញក៏មានការកើនឡើងវិញប្រមាណជា ១២៥ ក្នុងនោះរួមមានទាំងសកម្មភាពមិនអាចអនុវត្តបាន ដែលទទួលរងទង្គិចពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយភាគច្រើនគឺជាសកម្មភាពគ្រោងនៅក្នុងផ្នែកទី ៥ គឺជាសកម្មភាពបណ្តុះបណ្តាល និងសិក្ខាសាលា ។

## ២.៣. សេចក្តីសម្រេចរបស់ គ.ហ.ស.

### ❖ សេចក្តីសម្រេចនៅក្នុងឆ្នាំ ២០១៧

- រៀបចំមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ត្រួតពិនិត្យនិងកែលម្អលើប្រព័ន្ធវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ សម្រាប់ឆ្នាំ២០១៧
- រៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សិក្សាអំពីទម្រង់សំណើថវិកាសង្ខេបថវិកាជាតិប្រចាំឆ្នាំសម្រាប់ធ្វើការផ្សព្វផ្សាយជាសាធារណៈ បន្ទាប់ពីគណៈរដ្ឋមន្ត្រីអនុម័តសំណើកញ្ចប់ថវិកា
- ការរៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥
- រៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល
- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ
- បញ្ចប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ IPSAS-Cash Basis លើមូលដ្ឋានចេញពីប្រព័ន្ធ FMIS
- រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥
- រៀបចំលិខិតបញ្ចប់ការរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងអនុក្រឹត្យ និងប្រកាសពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ ។

## ❖ សេចក្តីសម្រេចនៅក្នុងឆ្នាំ ២០១៨

- រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥
- រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥
- រៀបចំប្រកាសចំនួន ៣ សម្រាប់ដាក់ឱ្យអនុវត្តច្បាប់ស្តីពីលទ្ធកម្មសាធារណៈឆ្នាំ ២០១២
- រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥
- រៀបចំយុទ្ធសាស្ត្រគៀរគរចំណូលឆ្នាំ ២០១៩-២០២៣
- រៀបចំយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម
- រៀបចំក្របខណ្ឌឯកសារទស្សនាទានស្តីពីប្រព័ន្ធគណនេយ្យសាធារណៈ ដើម្បីឈានទៅអនុវត្តប្រព័ន្ធគណនេយ្យបង្គរ
- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំត្រួតពិនិត្យឡើងវិញនូវប្រកាសអន្តរក្រសួងពាក់ព័ន្ធនឹងការធ្វើបំណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ
- រៀបចំមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំប្រព័ន្ធត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

## ❖ សេចក្តីសម្រេចនៅក្នុងឆ្នាំ ២០១៩

- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ
- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- សេចក្តីព្រាងច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន
- យុទ្ធសាស្ត្រនៃការកែទម្រង់គណនេយ្យសាធារណៈកម្ពុជា ឆ្នាំ ២០១៩-២០៣១
- ផែនការយុទ្ធសាស្ត្រការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី ៤
- ក្របខណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- រៀបចំ និងចាត់ចំណាត់ថ្នាក់ និងការគ្រប់គ្រងទិន្នន័យបំណុលសារពើពន្ធ និងមិនមែនសារពើពន្ធឱ្យបានច្បាស់លាស់ ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុល
- គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល (PFMM)
- របាយការណ៍វាយតម្លៃ PEFA ថ្នាក់ជាតិ ឆ្នាំ ២០២០
- របាយការណ៍វាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ ឆ្នាំ ២០២០
- មូលនិធិ PFMRP គ្រប់ជ្រុងជ្រោយ
- ត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ (CAP3) និងរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4)
- ការពិនិត្យ និងកែសម្រួលកិច្ចសន្យាជួល និងដីសម្បទានសេដ្ឋកិច្ច ។

## ❖ សេចក្តីសម្រេចនៅក្នុងឆ្នាំ ២០២០

- ក្របខណ្ឌទស្សនទានសម្រាប់ការរាយការណ៍ហិរញ្ញវត្ថុសាធារណៈកម្ពុជា
- ស្តង់ដាគណនេយ្យសាធារណៈស្តីពីផលរបរពីប្រតិបត្តិការដោះដូរ
- ស្តង់ដាគណនេយ្យសាធារណៈស្តីពីទ្រព្យ រោងចក្រ និងបរិក្ខារ
- ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- ច្បាប់ស្តីពីមូលបត្ររដ្ឋ
- ការតម្រង់ទិសនីតិវិធីអនុវត្តការងារថ្មីតាម FMIS សម្រាប់ក្រសួង ស្ថាប័ន ៧
- ការធ្វើសន្ទានកម្មរវាង FMIS និងប្រព័ន្ធពន្ធដារ
- ការធ្វើសន្ទានកម្មរវាង ASYCUDA និង ប្រព័ន្ធពន្ធដារ
- ការចាត់ចំណាត់ថ្នាក់ និង ការគ្រប់គ្រងទិន្នន័យបំណុលសារពើពន្ធ
- ការកាត់បន្ថយបំណុលមិនមែនសារពើពន្ធ
- ផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី៣ ឆ្នាំ២០២១-២០២៥
- ការកត់ត្រាចំណូលពីការជួលដីសម្បទានសេដ្ឋកិច្ច និងសម្បទានរ៉ែក្នុង NRMIS
- ផែនការសកម្មភាពរួមដំណាក់កាលទី ៣ បូក ២ ឆ្នាំ ២០២១-២០២២

- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុសាធារណៈ (ថ្មី)
- សេចក្តីព្រាងច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន
- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ
- គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល
- មូលនិធិ PFMRP គ្រប់ជ្រុងជ្រោយ
- ផែនការយុទ្ធសាស្រ្តស្តីពី ការកសាង និងអភិវឌ្ឍសមត្ថភាព ក្របខណ្ឌ PFMRP ដំណាក់កាល ទី៤
- យុទ្ធសាស្រ្តនៃការកែទម្រង់គណនេយ្យសាធារណៈកម្ពុជា ឆ្នាំ២០១៩-២០៣១
- ឯកសារទស្សនាទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្រ្តនៃការងារកែទម្រង់ ៣ បូក ១ (រយៈពេល ១០ ឆ្នាំ)
- សន្ទានកម្មរវាង FMIS និង EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា
- សន្ទានកម្មរវាង FMIS និងប្រព័ន្ធបៀវត្សរបស់ក្រសួងមុខងារសាធារណៈ
- របាយការណ៍ PEFA ថ្នាក់ជាតិ ឆ្នាំ២០២០
- របាយការណ៍ PEFA ថ្នាក់ក្រោមជាតិ ឆ្នាំ២០២០
- ផែនការធ្វើបណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ
- ក្របខណ្ឌរួមផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ
- កម្មវិធីសិក្សាភ្ជាប់វិញ្ញាបនបត្រ (Certificate Program) ដោយផ្សារភ្ជាប់ជាមួយមុខដំណែងឱ្យបានគ្រប់ជ្រុងជ្រោយ
- ការវាយតម្លៃលើបច្ច័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Impact Assessment)

# ៣. ការវាយតម្លៃលើការសម្រេចបានគោលបំណង

## ៣.១. ផ្នែកទី ១ ÷ ភាពជឿទុកចិត្តបាននៃថវិកា

នៅក្នុងផ្នែកទី ១ នេះ មានគោលបំណងចម្បងពីរ គឺ (១)ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាស មានភាពរលូន និងអាចប៉ាន់ស្មានបាន (+/-៥% ធៀបនឹងកម្មវិធីចំណូលចំណាយ) និង (២)ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព ។ ដើម្បីវាស់វែងការសម្រេចបាននូវគោលបំណងទាំងនេះ មានសូចនាករលទ្ធផល និងគោលដៅចំនួន ៨ ត្រូវបានបន្ថែមជាបន្តបន្ទាប់ ។ ក្នុងចំណោមសូចនាករលទ្ធផលទាំងនោះ, លទ្ធផលចំនួនពីរសម្រេចបានពេញលេញ គឺការកៀរគរចំណូលប្រចាំឆ្នាំសម្រេចបានកំណើនយ៉ាងហោចណាស់ 0,៣% នៃ ផ.ស.ស និងមិនមានចំណាយកកស្ទះនោះទេ ។ ភាគរយនៃការអនុវត្តចំណាយថវិកាធៀបនឹងច្បាប់, ក្របខណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈ និង ការគ្រប់គ្រងប្រព័ន្ធគណនីទោលរតនាគារជាតិ ត្រូវបានកែលម្អជាបន្តបន្ទាប់ផងដែរ ។ គោលដៅផ្សេងទៀតសម្រេចបាន ប៉ុន្តែមិនគ្រប់ជ្រុងជ្រោយ រួមមាន ការព្យាករផ្នែកចំណូល, និងបំណុលសារពើពន្ធ និងមិនមែនសារពើពន្ធត្រូវបានចាត់វិធានការតឹងទារ ។ ទោះបីជានៅមានការងារកែទម្រង់មួយចំនួននៅក្នុងផ្នែកនេះ ដែលមិនទាន់សម្រេចបានល្អ រួមមាន ប្រព័ន្ធលទ្ធកម្មសាធារណៈ, ការគ្រប់គ្រងវិនិយោគសាធារណៈ, និងបំណុលកកស្ទះ (Arrears) ផ្នែកចំណូល/ត្រូវទារ និងចំណាយ/ត្រូវសង រួមបញ្ចូលទាំងនីតិវិធីនៃការអនុវត្ត ។ ទន្ទឹមនឹងនេះ, មូលដ្ឋាននៃការកៀរគរចំណូលនៅមិនទាន់រឹងមាំនៅឡើយ, ផ្នែកភាពជឿទុកចិត្តបាននៃថវិកា ត្រូវបានពង្រឹងខ្លាំងគួរឱ្យកត់សម្គាល់ក្នុងពេលអនុវត្តផែនការរួមដំណាក់កាលទី ៣ ។

នៅក្នុងផ្នែកទី ១ នេះ មានគោលបំណង ៤ រួមមាន ÷ (១)ការបន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល, (២) ការបន្តពង្រឹងការគ្រប់គ្រងបំណុល, (៣)ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី, និង (៤) ការកែលម្អការអនុវត្តថវិកា និងការពង្រឹងការអនុវត្តផែនការចំណាយ ។ ផ្នែកខាងក្រោម នឹងធ្វើការវាយតម្លៃការសម្រេចបាននូវផ្នែកនេះ តាមកម្រិតគោលបំណងនីមួយៗ ។

### ៣.១.១. គោលបំណង ១១ ÷ បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល

របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ បង្ហាញថា ចំណូលចរន្តបានកើនឡើងពី ១៤,៩% នៃ ផ.ស.ស. នៅឆ្នាំ២០១៣ ដល់ ១៩,៦% នៃ ផ.ស.ស. នៅឆ្នាំ២០១៧ ដែលកំណើនជាមធ្យមក្នុងមួយឆ្នាំប្រមាណ ១.៤% ពិន្ទុភាគរយនៃ ផ.ស.ស. លើសគោលដៅ RMS (0,៥ ពិន្ទុភាគរយនៃ ផ.ស.ស.) ។ ក្នុងនោះ ចំណូលពន្ធគយបានកើនពី ៦,៤% នៃ ផ.ស.ស. នៅឆ្នាំ២០១៣ ដល់ ៨,៥% ផ.ស.ស. នៅឆ្នាំ២០១៧, ចំណូលពន្ធដារបានកើនពី ៥,៩% នៃ ផ.ស.ស. នៅឆ្នាំ២០១៣ ដល់ ៨,៥% នៃ ផ.ស.ស. នៅឆ្នាំ២០១៧ ។

យុទ្ធសាស្ត្រកៀរគរចំណូលបានដើរតួនាទីសំខាន់ក្នុងប្រមូលចំណូលក្នុងការស្រុក រួមជាមួយនឹងវិធានការគត់មត់ដើម្បីកែលម្អគោលនយោបាយ និងពង្រឹងប្រសិទ្ធភាពទាំងរដ្ឋបាលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។ ការបន្តកើនឡើងចំណូលចរន្តធៀបនឹង ផ.ស.ស. ពី ២២,0% ក្នុងឆ្នាំ២០១៨ រហូតដល់ ២៥.១២% ក្នុងឆ្នាំ២០១៩ ។ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA) ត្រូវបានធ្វើសន្ទានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង

ហិរញ្ញវត្ថុសាធារណៈ (FMIS) ។ ទន្ទឹមនេះ ការធ្វើសមាហរណកម្មរវាងប្រព័ន្ធពន្ធដារជាមួយនឹងប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅចុងឆ្នាំ ២០២០ ។ ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ក៏ត្រូវបានដាក់ឱ្យអនុវត្ត និងបណ្ដុះបណ្ដាលដល់ក្រសួង ស្ថាប័ន, រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពប្រហាក់ប្រហែលផ្សេងៗទៀតផងដែរ ។ ដោយឡែក ក្នុងឆ្នាំ២០២០ កំណើនចំណូលចរន្តមានការធ្លាក់ចុះមក -៣,៦៩% នៃ ផ.ស.ស. ដោយសារផលប៉ះពាល់ខ្លាំងនៃការរីករាលដាលនៃជំងឺកូវីត-១៩ ក្នុងនោះចំណូលពន្ធគយអនុវត្តបានទាបជាងផែនការ ដោយសារការធ្លាក់ចុះលំហូរពាណិជ្ជកម្ម ជាពិសេសទំនិញនាំចូលដែលមានលក្ខណៈប្រណិត ការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ច និងការអនុវត្តនូវវិធានការអនុគ្រោះពន្ធសំដៅជួយដល់អាជីវកម្មដែលរងផលប៉ះពាល់ ។ ការអនុវត្តចំណូលពន្ធដារសម្រេចបានតាមគោលដៅ ដោយសារការគាំទ្រនៃពន្ធលើប្រាក់ចំណូលដែលជាលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចនៃឆ្នាំ ២០១៩ ក្រៅពីនេះចំណូលពន្ធផ្សេងៗ មានការថមថយតាមរយៈការធ្លាក់ចុះនៃតម្រូវការប្រើប្រាស់ និងការធ្លាក់ចុះនៃចំណូលរបស់ប្រជាជនដោយសារជំងឺកូវីត-១៩ ។ ចំណែកចំណូលមិនមែនពន្ធសម្រេចបានទាបជាងផែនការ ដោយសារការរីករាលដាលនៃជំងឺកូវីត-១៩ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រភពចំណូលក្នុងវិស័យទេសចរណ៍ ។

សម្រាប់ការគ្រប់គ្រងបំណុលត្រូវទារក្នុងឆ្នាំ, អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសំណុំឯកសារសហគ្រាសជំពាក់បំណុលពន្ធទូទាំងប្រទេស និងការចាត់ថ្នាក់បំណុលពន្ធជា "បំណុលពន្ធអាចប្រមូលបាន" និង "បំណុលពន្ធមិនអាចប្រមូលបាន" ត្រូវបានរៀបចំរួចរាល់សម្រាប់ដាក់បញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រង និងប្រមូលបំណុលពន្ធដារថ្មី ។ យន្តការការងារ និងប្រព័ន្ធគ្រប់គ្រងនិងប្រមូលបំណុលពន្ធដារថ្មីសម្រាប់អគ្គនាយកដ្ឋានពន្ធដារត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។ ជាមួយគ្នានេះ ប្រកាសស្ដីពីការគ្រប់គ្រងបំណុលពន្ធដារ និងប្រកាសស្ដីពីវិធាន និងនីតិវិធីនៃការតាមដានការតឹងទារ និងការជម្រះបញ្ជីនៃបំណុលមិនមែនសារពើពន្ធ ត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ។ ប្រកាសស្ដីពីវិធាន និងនីតិវិធីនៃការតាមដាន ការតឹងទារ និងជម្រះបញ្ជីបំណុលមិនមែនសារពើពន្ធត្រូវបានអនុម័តថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២០ ។ ដោយឡែកលិខិតបទដ្ឋានគតិយុត្តត្រូវបានរៀបចំ ដើម្បីជាយន្តការតាមដានការអនុវត្តការប្រមូលចំណូលផ្ទាល់ចំណូលចែករំលែក/របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

បើទោះបីជាយ៉ាងនេះក្ដី ចំណូលក្នុងស្រុកមានកំណើនគួរឱ្យកត់សំគាល់ ខណៈប្រសិទ្ធភាពនៃវាយតម្លៃនៃសក្ដានុពលនៃប្រភពចំណូល និងក្របខណ្ឌនៃការព្យាកចំណូលក៏ត្រូវបានបន្តពង្រឹង ។ ច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅមិនទាន់អនុម័តនៅឡើយ ដោយបច្ចុប្បន្នច្បាប់នេះត្រូវបានពិនិត្យ និងកែសម្រួលកម្រិតបច្ចេកទេសដែលគ្រោងនឹងដាក់ឆ្លងថ្នាក់ដឹកនាំ កសហវ ត្រឹមត្រីមាសទី៣ ឆ្នាំ២០២១ ។ ដោយឡែក ការគ្រប់គ្រងបំណុលត្រូវទារទាំងបំណុលពន្ធ និងមិនមែនពន្ធស្ថិតនៅក្នុងការព្រួយបារម្ភ និងទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតជាពិសេស ការចាត់ថ្នាក់បំណុល, ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រង និង យន្តការការងារតឹងទារ ។

ជារួម គោលបំណងនេះសម្រេចបានវឌ្ឍនភាពបានល្អច្រើនជុំវិញការគ្រប់គ្រងចំណូល និងការពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, ការបន្តកែលម្អគោលនយោបាយ និងរដ្ឋបាលគយ ពន្ធដារ និងចំណូលមិនមែនសារពើពន្ធ, ពង្រឹងការវិភាគ និងការព្យាករចំណូល, ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលក្នុងឆ្នាំ, និងការអនុវត្តការប្រមូលចំណូលផ្ទាល់/ចំណូលចែករំលែករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ១១ រួមមាន ÷*

- *ធានាប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការវិភាគ និងការវាយតម្លៃ*
- *ពន្លឿនការអនុវត្តវិធានការដែលនៅសេសសល់ និងមានវឌ្ឍនភាពទាប*
- *ពង្រឹងគុណភាពនៃការវាយតម្លៃដោយបន្តពង្រឹងសមត្ថភាពមន្ត្រី*
- *ពិនិត្យតាមដាន និងបង្កើនចំនួនសូចនាករគន្លឹះ ។*

### ៣.១.២. គោលបំណង ១២ ÷ បន្តពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ

វឌ្ឍនភាពនៃសូចនាករគន្លឹះរបស់គោលបំណងនេះ ត្រូវបានឆ្លើយតបច្រើនតាមរយៈការរក្សាបន្ទុកបំណុលឱ្យស្ថិតក្នុងកម្រិតអប្បបរមា ដោយសូចនាករបំណុលគន្លឹះៗទាំង៥ គឺសុទ្ធតែស្ថិតក្រោមពិតានកំណត់ទាំងអស់ ។ រាល់ទិន្នន័យបំណុលពាក់ព័ន្ធទាំងអស់ត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុល (Debt Management and Financial Analysis System- DMFAS) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមសម្រាប់គ្រប់គ្រងបំណុលសាធារណៈ (In-house Database for PDM) ដែលត្រូវបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ១៦២០ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៨ ។ នៅចន្លោះឆ្នាំ ២០១៦-២០១៨ គឺជារយៈពេលរៀបចំសេចក្តីព្រាងនៃឯកសារគោលនយោបាយ, យុទ្ធសាស្ត្រ និងយន្តការផ្សេងៗ ត្រូវបានឱ្យអនុម័ត និងដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០១៨-២០២០ ដូចខាងក្រោម ÷

- នីតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្តដោយប្រកាសលេខ ៥៤៦ សហវប្រក ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៨.
- យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុល ២០១៩២០២-៣ ត្រូវបានរៀបចំជាសេចក្តីព្រាងនៅឆ្នាំ២០១៧ និងអនុម័តនៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៩
- ច្បាប់ស្តីពីមូលបត្ររដ្ឋ ត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ។

នៅឆ្នាំ ២០១៦ ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា ត្រូវបានបោះផ្សាយ ២ ដង (លេខ ១ និង ២) និងក្នុងឆ្នាំបន្ទាប់បោះផ្សាយ ២ដង (លេខ ៣ និង ៤ ឆ្នាំ២០១៧, លេខ ៥ និង ៦ ឆ្នាំ២០១៨, និងលេខ ៧ និង ៨ ឆ្នាំ២០១៩, និងលេខ ៩ និង ១០ ឆ្នាំ២០២០) សរុបមានចំនួន ១០ លេខ[5] ។ របាយការណ៍ស្តីពីការវាយតម្លៃប្រតិបត្តិការនៃការគ្រប់គ្រងបំណុលសាធារណៈ (DeMPA) ចាប់ផ្តើមរៀបចំក្នុងឆ្នាំ ២០១៧ រហូតដល់បច្ចុប្បន្ន ។

ទន្ទឹមនឹងនេះ ដើម្បីជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ (ក.ម.រ) តាមរយៈសេចក្តីសម្រេចលេខ ០៧១ សហវ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលភារកិច្ចចម្បង របស់ ក.ម.រ គឺ សិក្សា ស្រាវជ្រាវ និងរៀបចំក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ (PFDGS) ។ ជាវឌ្ឍនភាព, ក.ម.រ. បានរៀបចំផែនការការងារសម្រាប់រៀបចំ PFDGS និង Outline នៃសេចក្តីព្រាង PFDGS ដោយរួមបញ្ចូលទាំងផែនការសកម្មភាពរួម ផងដែរ ។ PFDGS នេះគ្រោងនឹងអនុម័ត និងដាក់ឱ្យអនុវត្តនៅមុនដំណាច់ឆ្នាំ២០២១ ។

---

[5] ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា https://gdicdm.mef.gov.kh/cat/documents-and-publications/bulletins

ជារួម គោលបំណងនេះ សម្រេចបានវឌ្ឍនភាពបានល្អច្រើនជុំវិញការគ្រប់គ្រងបំណុលសាធារណៈ ពោលគឺស្ថានភាពបំណុលសាធារណៈនៅកម្ពុជាមានចីរភាព និងហានិភ័យកម្រិតទាប ។

*សកម្មភាពបន្តអនុវត្តក្នុងដំណាក់កាលបន្ទាប់សម្រាប់គោលបំណង ១២ រួមមាន ៖*

- *បន្តពង្រឹងការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣*
- *បន្តជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ ។*

### ៣.១.៣. គោលបំណង ១៣ ៖ ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី

សមតុល្យសាច់ប្រាក់ត្រូវបានតាមដានជាប្រចាំតាមរយៈរបាយការណ៍ធនាគារក្នុងគណនីទាំងឡាយ ដែលស្ថិតនៅក្រោមរចនាសម្ព័ន្ធ ។ ការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ ត្រូវបានអនុវត្តទូទាំងប្រទេស ជាទៀតទាត់ដោយធ្វើការបើកផ្តល់ ២ ដងក្នុង ១ខែ ។ គោលការណ៍ដាក់ឱ្យអនុវត្តការទូទាត់តាមប្រព័ន្ធ EFT ក្នុងប្រព័ន្ធ FMIS ត្រូវបានអនុវត្តជាផ្លូវការ ។ ទន្ទឹមនឹងនេះ គណនីធនាគារដែលបើកនៅ NBC និង Commercial Bank នៅថ្នាក់កណ្តាល និងថ្នាក់រាជធានីត្រូវបានតាមដានជាប្រចាំ និងមានការរៀបចំទម្រង់របាយការណ៍អនុវត្តថវិកាគម្រោងដៃគូអភិវឌ្ឍន៍ ។ ចាប់តាំងពីឆ្នាំ ២០១៦ ការគិតរយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីពេលអាណត្តិបើកផ្តល់ប្រាក់ត្រូវបានបញ្ជូន និងចុះកាលបរិច្ឆេទលើអាណត្តិដែលចូលមកអគ្គនាយកដ្ឋានរតនាគារជាតិ គឺពុំមានបំណុលកកស្ទះនោះឡើយ ។ រីឯ ប្លង់គណនេយ្យសាធារណៈបានដាក់ឱ្យអនុវត្តសាកល្បងនៅអង្គភាពមួយចំនួន ដែលអនុវត្តថវិកាដៃគូអភិវឌ្ឍន៍ ។

ទោះបីជាយ៉ាងនេះក្តី អង្គភាពពាក់ព័ន្ធហាក់ដូចពុំទាន់កំណត់យន្តការច្បាស់លាស់លើការគ្រប់គ្រងប្រព័ន្ធផែនការសាច់ប្រាក់នៅតាមក្រសួង ស្ថាប័ន,ពង្រឹងការទូទាត់ថវិកាបុរេប្រទានឱ្យបានទាន់ពេល និងការសិក្សាឡើងវិញពីការកំណត់និយមន័យបំណុលកកស្ទះ នៅឡើយ ។

ជារួម គោលបំណង ១៣ សម្រេចបានក្នុងរង្វង់ល្អ ទៅតាមផែនការដែលបានដាក់ចេញសម្រាប់ដំណាក់កាលទី៣ នេះ ។ សម្រាប់ដំណាក់កាលបន្ទាប់, អង្គភាពពាក់ព័ន្ធ គួរយកចិត្តទុកដាក់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងគួរកំណត់សូចនាករសមិទ្ធកម្មគន្លឹះ និងចង្អោមសកម្មភាព ឱ្យមានភាពប្រទាក់ក្រឡាគ្នា និងអាចវាស់វែងបាន ។

*សកម្មភាពបន្តអនុវត្តក្នុងដំណាក់កាលបន្ទាប់សម្រាប់គោលបំណង ១៣ រួមមាន ៖*

- *ពង្រឹងយន្តការគ្រប់គ្រងប្រព័ន្ធផែនការសាច់ប្រាក់នៅតាមក្រសួង ស្ថាប័ន (គួរសាកល្បងអនុវត្ត និងតាមដានជាប្រចាំលើការអនុវត្តរបស់ កសហវ ជាគំរូ)*
- *ពុំមានបំណុលកកស្ទះ (រយៈពេល ៦០ថ្ងៃ) ប៉ុន្តែ និយមន័យ ដែលអគ្គនាយកដ្ឋានរតនាគារជាតិបានប្រើ គឺពុំបានចាប់យករយៈពេលពេញលេញពីការចេញវិក័យប័ត្ររបស់អ្នកផ្គត់ផ្គង់ រហូតដល់ការទូទាត់នោះទេ ។ និយមន័យ "បំណុលកកស្ទះ" ដែលកំណត់នោះគឺ គិតលើមូលដ្ឋានឯកសារដែលចូលដល់អគ្គនាយកដ្ឋានរតនាគារជាតិ ប៉ុណ្ណោះ ។*
- *ពង្រឹងការទូទាត់ថវិកាបុរេប្រទានឱ្យបានទាន់ពេល*
- *ពង្រឹងការអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថ្មី (CoA) សម្រាប់គម្រោង ឬ កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ។*

### ៣.១.៤. គោលបំណង ១៤ ÷ កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ

ស្ថានភាពនៃការអនុវត្តចំណាយប្រចាំឆ្នាំសម្រេចបានក្នុងរង្វង់ប្រមាណ ៩៤,២៩% នៅឆ្នាំ២០១៦, ៩៤,៤៧% នៅឆ្នាំ២០១៧, ៩៩% នៅឆ្នាំ២០១៨, និង ៩៥,៤៣% នៅឆ្នាំ២០១៩ ។ នៅក្នុងឆ្នាំ ២០២០ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ រដ្ឋាភិបាលបានធ្វើវិចារណកម្មថវិកាចំណាយចំនួន ២ លើក ដោយកាត់សន្សំចំណាយមិនចាំបាច់ មិនសូវចាំបាច់ និងលែងចាំបាច់ ដែលធ្វើឱ្យចំណាយថវិកាថ្នាក់ជាតិសម្រេចបាន ៩១,៨៤% ធៀបនឹងច្បាប់ថវិកា ឬ ៩៣,៧៨% នៃវិចារណកម្មថវិកា ។ ក្រសួង ស្ថាប័ន បានរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស និងផ្សព្វផ្សាយនៅលើគេហទំព័រ ។ យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានដាក់ឱ្យអនុវត្ត ។ អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្ត ។

ក្នុងពេលជាមួយគ្នានេះ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីពង្រឹងការអនុវត្តផែនការចំណាយឱ្យមានប្រសិទ្ធភាពកាន់តែល្អប្រសើរ ។ អនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្តជាមួយនឹងប្រកាស ដូចជា ÷

- ប្រកាសស្តីពីការចុះ ការជម្រុះ និងការផ្សព្វផ្សាយបញ្ជីខ្មៅអ្នកដេញថ្លៃ ត្រូវបានដាក់ឱ្យអនុវត្ត
- ប្រកាសស្តីពីការគ្រប់គ្រងការអនុវត្តកិច្ចសន្យាលទ្ធកម្មសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្ត
- ប្រកាសស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្ត
- ប្រកាសស្តីពីការបុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ត្រូវបានដាក់ឱ្យអនុវត្ត
- គោលការណ៍ណែនាំ ស្តីពីការភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើសុំថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំ និងអនុម័ត
- គោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ត្រូវបានអនុម័ត នាខែមិថុនា ឆ្នាំ២០១៦ ។

ទោះបីជាយ៉ាងនេះក្តី, នៅត្រីមាសទី ៤ នៃឆ្នាំថវិកា ការអនុវត្តចំណាយហាក់ដូចជាមានការមមាញឹកលើការទូទាត់ចំណាយត្រូវបានគរនៅចុងត្រីមាសនៃឆ្នាំ) និងកង្វះយន្តការតាមដានវាយតម្លៃ ។ សកម្មភាពគ្រោងឡើងមានសង្គតិភាពជាមួយនឹងសូចនាករគោលបំណង ក៏ប៉ុន្តែសកម្មភាពខ្លះទៀត ហាក់ដូចជាមិនទាន់មានភាពប្រទាក់ក្រឡាគ្នានៅឡើយ ។

ផ្អែកតាមផែនការដែលបានគ្រោងទុកក្នុងឆ្នាំ២០២០, សេចក្តីព្រាងច្បាប់ស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP) ត្រូវបានអនុម័ត និងប្រកាសដាក់ឱ្យប្រើប្រាស់ ក៏ប៉ុន្តែសេចក្តីព្រាងច្បាប់នេះ ត្រូវបានពន្យារពេលរហូតដល់ឆ្នាំ២០២១ ដោយសារតែការរៀបចំសេចក្តីព្រាងច្បាប់នេះមានលក្ខណៈបច្ចេកទេសខ្ពស់ និងស្មុគស្មាញ, ទាមទារឱ្យមានការយល់ដឹងច្បាស់លាស់ពីទស្សនាទាន និងការអនុវត្តគម្រោង PPP, ត្រូវការប្រឹក្សាយោបល់ និងកិច្ចប្រជុំច្រើនដងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ, និងត្រូវការចំណាយពេលយូរ ។ ម៉្យាងវិញទៀត ភាពប្រទាក់ក្រឡាគ្នារវាងគម្រោងវិនិយោគសាធារណៈ និងគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ធ្វើឱ្យពិបាកក្នុងការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ឱ្យមានប្រសិទ្ធភាព និងចំពោះកិច្ច ។

ជារួម គោលបំណង ១៤ សម្រេចបានក្នុងរង្វង់ល្អ ទៅតាមផែនការដែលបានដាក់ចេញ ។ បញ្ហាប្រឈមនៃគោលបំណងនេះ ត្រូវបានដោះស្រាយក្នុងឆ្នាំ ២០២០ ដោយផែនការសកម្មភាពលម្អិតសម្រាប់គាំទ្រយុទ្ធសាស្ត្រទាំង ២ ខាងលើ ត្រូវបានដាក់ឱ្យអនុវត្ត ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ១៤ រួមមាន ÷*

- *បន្តពង្រឹងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស របស់ក្រសួង ស្ថាប័ន*
- *អនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឱ្យបានពេញលេញ*
- *អនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ឱ្យបានពេញលេញ ។*

### ៣.១.៥. សេចក្ដីសន្និដ្ឋានផ្នែកទី ១

ជារួម ការពង្រឹង និងការគ្រប់គ្រងចំណូល មានស្ថានភាពល្អប្រសើរ និងបង្កើតឱ្យមានអតិរេកចរន្ត ។ ការអនុវត្តចំណាយ ត្រូវបានបន្តកែលម្អគួរឱ្យកត់សម្គាល់ និងស្ថិតក្នុងទិសដៅកំណត់ ។ រីឯបំណុលសាធារណៈ ស្ថិតក្នុងស្ថានភាពអាចគ្រប់គ្រងបាន ។

ប៉ុន្តែ មូលដ្ឋាននៃប្រភពចំណូល នៅជាកត្តាបារម្ភសម្រាប់រក្សាចីរភាពនៃកំណើនសេដ្ឋកិច្ច ។ រីឯការអនុវត្តធៀបនឹងផែនការ នៅមិនទាន់ត្រូវបានវាយតម្លៃអំពីប្រសិទ្ធភាពទាំងក្របខណ្ឌនៃការព្យាករ និងសក្ដានុពល ឬ លទ្ធភាពនៃការកៀរគរចំណូល ។

ជាទិសដៅសម្រាប់ដំណាក់កាលបន្ទាប់, គួរបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ដោយផ្ដោតសំខាន់លើយន្តការ និងយុទ្ធសាស្ត្រដែលអាចធានាពិពិធកម្មចំណូល, ប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តកិច្ចលទ្ធកម្ម, យន្តការវាយតម្លៃលើការពង្រឹងគុណភាពព្យាករណ៍ និងការអនុវត្ត ជាពិសេសយន្តការ យុទ្ធសាស្ត្រ និងវិធានការផ្សេងៗទៀត ដែលអាចធានាចីរភាពនៃអតិរេក និងកំណើនសេដ្ឋកិច្ច ដែលស្របនឹងយុទ្ធសាស្ត្រគន្លឹះៗដែលបានដាក់ឱ្យអនុវត្ត ។

*ជារួម សកម្មភាពបន្តក្នុងជំហានបន្ទាប់សម្រាប់ផ្នែកទី ១ រួមមាន ÷*

- *បន្តពង្រឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០២០-២០២៣ តាមរយៈការពង្រឹងការអនុវត្តផែនការសកម្មភាពប្រមូលចំណូល និងពង្រឹងគុណភាពនៃការព្យាករ*
- *បន្តពង្រីកយុទ្ធសាស្ត្រនៃការប្រមូលចំណូល តាមរយៈការធ្វើពិពិធកម្មចំណូលដើម្បីធានាចីរភាពនៃកំណើនសេដ្ឋកិច្ច*
- *រៀបចំយន្តការតាមដានលើការគ្រប់គ្រងការប្រមូលចំណូលជាប្រចាំត្រីមាស និងបំពាក់គុណវុឌ្ឍដល់អ្នកគ្រប់គ្រង អ្នកអនុវត្ត និងអ្នកវិភាគ ដើម្បីធានាបាននូវសុក្រឹត្យភាពនៃការរៀបចំរបាយការណ៍ និងទិន្នន័យសម្រាប់ជាមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចចិត្ត លើការរៀបចំសកម្មភាពជាយុទ្ធសាស្ត្រនៃការប្រមូលចំណូល*
- *បន្តពង្រឹងគុណភាពនៃការរៀបចំ និងអនុវត្តផែនការចំណាយប្រចាំត្រីមាសជាមួយនឹងសង្គតិភាពនៃផែនការលទ្ធកម្ម*

- *បន្តពង្រឹងការអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣*
- *បន្តជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ ។*

## ៣.២. ផ្នែកទី ២ ÷ គណនេយ្យភាពហិរញ្ញវត្ថុ

គណនេយ្យភាពហិរញ្ញវត្ថុ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តតាំងពីឆ្នាំ ២០០៨ មកម្ល៉េះ ជាមួយនឹងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ។ នៅដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៦-២០២០, ផ្នែកទី ២ នៃការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុមានគោលដៅចម្បងលើការអនុវត្តប្រព័ន្ធ FMIS និងការពង្រីកវិសាលភាពនៃប្រព័ន្ធនេះ ។ ទន្ទឹមនឹងការមានប្រព័ន្ធកត់ត្រានេះ, ការរៀបចំរបាយការណ៍ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងស្របតាមស្តង់ដារជាអន្តរជាតិ ក៏ត្រូវបានពង្រឹងផងដែរតាមរយៈការរៀបចំឱ្យមានចំណាត់ថ្នាក់ថវិកាទាំង ៧ នៅក្នុងប្រព័ន្ធ FMIS និងអនុវត្តឱ្យបានពេញលេញ, ការរៀបចំស្តង់ដារគណនេយ្យសាធារណៈកម្ពុជា, និងការពង្រឹងលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។ បន្ថែមពីលើសនេះ, ការបើកចំហព័ត៌មានថវិកាជូនសាធារណជន ដើម្បីបង្កើនតម្លាភាពថវិកា ក៏ត្រូវបានតាមដាននៅក្នុងផ្នែកទី ២ នេះ ផងដែរ ដោយត្រូវធានាថាសន្ទស្សន៍នៃការបើកចំហថវិកាមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ស្របតាមបរិការណ៍កម្ពុជា ។

នៅក្នុងផ្នែកទី ២ នេះ មានគោលបំណងចំនួន ៥ រួមមាន ÷ (១) ចំណាត់ថ្នាក់ថវិកា (សេដ្ឋកិច្ច, កម្មវិធី, រដ្ឋបាល, មុខងារ, ភូមិសាស្ត្រ, គម្រោង, មូលនិធិ), (២) ការអនុវត្តប្រព័ន្ធ FMIS, (៣) ស្តង់ដារគណនេយ្យសាធារណៈ, (៤) ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS), និង (៥) សន្ទស្សន៍ការស្ទង់មតិតម្លាភាពថវិកា ។

### ៣.២.១. គោលបំណង ២១ ÷ ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី

គោលដៅចម្បងនៃការអនុវត្តគោលបំណងនេះ គឺការធានាឱ្យមានទិន្នន័យក្នុងទម្រង់សមស្របដែលអាចវិភាគមានសង្គតិភាព និងសុក្រិតភាព ដែលជាមូលដ្ឋាននៃគណនេយ្យភាពហិរញ្ញវត្ថុ និងសម្រាប់រៀបចំក្របខណ្ឌថវិកា ។ ដើម្បីធានាថាគោលបំណងនេះសម្រេចបានពេញលេញ, តម្រូវឱ្យមានការរៀបចំរបាយការណ៍ថវិកាតាមចំណាត់ថ្នាក់ទាំង ៧ (ដូចបង្ហាញនៅក្នុងតារាងខាងក្រោម) ឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងអាចវិភាគបាន ។ ក្រៅពីនេះ, ការពង្រីកការរាយការណ៍នៃការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ក៏ត្រូវយកចិត្តទុកដាក់ ដើម្បីធានាបាននូវភាពគ្រប់ជ្រុងជ្រោយនៃរបាយការណ៍សម្រេចទូទាត់របស់ជាតិ ។ ជាមួយគ្នានេះ, ការរៀបចំរបាយការណ៍ GFS តាមស្តង់ដារអន្តរជាតិ (GFSM2014) គួរត្រូវបានផ្តល់អាទិភាព ដើម្បីបង្ហាញព័ត៌មានហិរញ្ញវត្ថុតាមស្តង់ដារជូនសាធារណៈ ក្នុងការប្រើប្រាស់តាមគោលបំណងរៀងៗខ្លួន។ ដើម្បីអនុវត្តនូវសូចនាករគន្លឹះទាំងនេះប្រកបដោយជោគជ័យ ចាំបាច់ត្រូវមានការបែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់អង្គភាពពាក់ព័ន្ធទៅតាមសមត្ថកិច្ចរៀងៗខ្លួន (អង្គភាពទទួលខុសត្រូវរៀបចំ, អង្គភាពសម្របសម្រួលអនុវត្ត, អង្គភាពអនុវត្ត) ។ ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមជាមួយនឹងវឌ្ឍនភាព ÷

| សូចនាករសមិទ្ធកម្មគន្លឹះ | សេចក្តីពន្យល់ | វឌ្ឍនភាព | អង្គភាពទទួលខុសត្រូវ | អង្គភាពសម្របសម្រួល | អង្គភាពអនុវត្ត |
| --- | --- | --- | --- | --- | --- |
| **ចំណាត់ថ្នាក់ថវិកាទាំង ៧** | មានប្រកាសនៃចំណាត់ថ្នាក់ទាំង ៧ ។ ចំណាត់ថ្នាក់នីមួយៗ ត្រូវបានរៀបចំរចនាសម្ព័ន្ធ ដូចខាងក្រោម÷ | - មានប្រកាស សម្រាប់ដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ទាំង ៧<br>- ក្នុងចំណោមចំណាត់ថ្នាក់ថវិកាចំនួន ៧ ដែលបានដាក់ឱ្យអនុវត្តក្នុងប្រព័ន្ធ FMIS មានចំណាត់ថ្នាក់ចំនួន ២ គឺចំណាត់ថ្នាក់ភូមិសាស្ត្រ និងចំណាត់ថ្នាក់មុខងារ ដែលគុណភាពទិន្នន័យនៅពុំទាន់អាចប្រើប្រាស់បានទាំងស្រុងនៅឡើយ។ ។ | | | |
| **ចំណាត់ថ្នាក់សេដ្ឋកិច្ច** | ចំណាត់ថ្នាក់នេះចែកជាជំពូក (២ខ្ទង់), គណនី (៤ខ្ទង់) និងអនុគណនី (៦ខ្ទង់) និងភាគច្រើនមានសង្គតិភាពជាមួយ GSF | បានប្រើប្រាស់កម្រិតជំពូក គណនី និងអនុគណនី នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ (ក១ និង ក២) និងច្បាប់ទូទាត់ថវិកា (ខ១, ខ២, ខ៣, ខ៤) និងអាណត្តិបើកប្រាក់ ។ | GDNT<br>GDB | GDNT | LMs |
| **ចំណាត់ថ្នាក់មុខងារ** | ចំណាត់ថ្នាក់នេះចែកជាកូដមុខងារ (៣ខ្ទង់), អនុមុខងារ (៤ខ្ទង់) និង អនុ-អនុមុខងារ (៥ខ្ទង់) ស្របតាម COFOG | ចំណាត់ថ្នាក់នេះត្រូវបានប្រើប្រាស់នៅកម្រិតកូដមុខងារប៉ុណ្ណោះ តែមិនទាន់សមស្របតាមប្រកាស និងស្តង់ដារ COFOG នៅឡើយទេ។ ជាក់ស្តែងការប្រើប្រាស់ដែលបានបង្ហាញនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ (ខ១) កូដមុខងារបានបែងចែកជា ៤ វិស័យធំៗ ខណៈដែលស្តង់ដារ COFOG និង ប្រកាសចំណាត់ថ្នាក់មុខងារបានបែងចែកកូដមុខងារជា ១០ វិស័យ ។ | GDB | ពុំទាន់កំណត់ | LMs |
| **ចំណាត់ថ្នាក់រដ្ឋបាល** | ចំណាត់ថ្នាក់នេះចែកជា<br>-កម្រិតរដ្ឋបាលថ្នាក់ជាតិ ÷ ក្រសួង/ស្ថាប័ន (២ខ្ទង់), អគ្គនាយកដ្ឋានក្រោមក្រសួង (៤ខ្ទង់), មន្ទីររាជធានីខេត្ត (៣ | ចំណាត់ថ្នាក់នេះបានប្រើប្រាស់នៅកម្រិតក្រសួង/ស្ថាប័ន និងកម្រិតរាជធានី/ខេត្ត ប៉ុណ្ណោះ ។ ការប្រើប្រាស់ បានបង្ហាញនៅក្នុងតារាង "ខ១" "ខ២" "គ១" "គ២" នៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ។ | GDB | មិនទាន់កំណត់ | LMs |

| | | | | | |
|---|---|---|---|---|---|
| | ខ្ទង់), មន្ទីររាជធានី/ខេត្ត (៥ ខ្ទង់)<br>-កម្រិតថ្នាក់ក្រោមជាតិ ÷ រាជធានី/ខេត្ត (៣ខ្ទង់), ក្រុង/ស្រុក (៥ខ្ទង់), ឃុំ/សង្កាត់ (៧ ខ្ទង់) | | | | |
| **ចំណាត់ថ្នាក់ភូមិសាស្ត្រ** | ចំណាត់ថ្នាក់នេះចែកជា រាជធានីខេត្ត (២ខ្ទង់), ស្រុកខណ្ឌ (៤ខ្ទង់) និង ឃុំសង្កាត់ (៦ខ្ទង់) | ចំណាត់ថ្នាក់នេះបានប្រើប្រាស់នៅកម្រិតរាជធានី/ខេត្ត ។ ការប្រើប្រាស់បានបង្ហាញនៅក្នុងតារាងឧបសម្ព័ន្ធ "គ៥" នៃច្បាប់ស្តីពីការទូទាត់ថវិកា តែទិន្នន័យនៃចំណាត់ថ្នាក់មិនទាន់អាចប្រើប្រាស់បាន ។ | GDSNAF | មិនមានព័តមាន | LMs<br>SNAs |
| **ចំណាត់ថ្នាក់គម្រោង** | ចំណាត់ថ្នាក់នេះចែកជា ប្រភពហិរញ្ញវត្ថុ (១ខ្ទង់), លេខកូដ (៦ខ្ទង់) និង លេខគម្រោង (អក្សរកាត់) | ប្រើប្រាស់មិនទាន់ស្របតាមប្រកាសដែលបានចែង ។ ជាក់ស្តែងការប្រើប្រាស់ចំណាត់ថ្នាក់គម្រោងនៅក្នុងច្បាប់ថវិកា (គ១) និងច្បាប់ទូទាត់ថវិកា (គ៣) មិនបានបង្ហាញអំពីលេខកូដគម្រោង ឬ ឈ្មោះគម្រោងឡើយ ។ | GDB | មិនមានព័តមាន | LMs |
| **ចំណាត់ថ្នាក់កម្មវិធី** | ចំណាត់ថ្នាក់នេះចែកជា កម្មវិធី (៣ខ្ទង់), អនុកម្មវិធី (៥ខ្ទង់) និង ចង្កោមសកម្មភាព (៧ខ្ទង់) | បានប្រើប្រាស់កម្រិតកម្មវិធី អនុកម្មវិធីនិង ចង្កោមសកម្មភាពស្របតាមប្រកាស និង សៀវភៅថវិកាកម្មវិធី ។ ចំណាត់ថ្នាក់នេះបានប្រើប្រាស់នៅក្នុងអាណត្តិបើកប្រាក់ និងថវិកាកម្មវិធីប្រចាំឆ្នាំរបស់ក្រសួងស្ថាប័ននីមួយៗ ។ | GDB<br>GDNT | មិនមានព័តមាន | LMs |
| **ចំណាត់ថ្នាក់មូលនិធិ** | ចំណាត់ថ្នាក់នេះចែកជា ១ខ្ទង់ (ប្រភពហិរញ្ញប្បទាន ), ២ខ្ទង់ (ប្រភេទហិរញ្ញប្បទាន) ៣ ខ្ទង់ (ប្រភេទម្ចាស់ fund) និង ៥ ខ្ទង់ (ឈ្មោះម្ចាស់ Fund) ។ | បានប្រើប្រាស់នៅក្នុងអាណត្តិបើកប្រាក់ | GDICDM | មិនមានព័តមាន | LMs |
| **ការរៀបចំរបាយការណ៍របស់គ្រឹះស្ថាន** | គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំរបាយការណ៍ហិរញ្ញ- | - បានចេញប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ | GDNT | GDNT | EPAs |

| | | | | | |
|---|---|---|---|---|---|
| **សាធារណៈរដ្ឋបាល** | វត្ថុ ឱ្យស្របតាមគោលការណ៍ណែនាំដែលបានកំណត់ | គណនេយ្យរដ្ឋទេយ្យចំណូលរបស់គ្រឹស្ថានសាធារណៈរដ្ឋបាល<br>- បានចុះពិនិត្យវាយតម្លៃ និងតម្រង់ទិសការអនុវត្តគណនេយ្យគ្រឹះស្ថានសាធារណៈរដ្ឋបាល ចំនួន ៣ នៅឆ្នាំ២០១៩ | | | |
| **ស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល** (GFS) | តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ស្របតាមក្របខណ្ឌ GFSM2014 ត្រូវបានរៀបចំពេញលេញ | តារាងចំនួន ៥/៧ នៃ GFS ត្រូវបានរៀបចំ ឱ្យមានសង្គតិភាពជាមួយចំណាត់ថ្នាក់នៃមាតិកាថវិកា | GDP | GDP | GDP |

ជារួម ទោះបីជាគោលបំណង ២១ សម្រេចបាននូវវឌ្ឍនភាពល្អប្រសើរច្រើននៅក្នុងដំណាក់កាលទី ៣ នេះ ប៉ុន្តែនៅមានបញ្ហាមួយចំនួននៃគោលបំណងនេះដែលគួរដោះស្រាយ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំរបាយការណ៍សម្រេចទូទាត់ឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ ក្នុងនោះរួមមាន ÷ (១) ការកែលម្អចំណាត់ថ្នាក់ភូមិសាស្ត្រ និងចំណាត់ថ្នាក់មុខងារ និង (២) ការពង្រឹងការរៀបចំរបាយការណ៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមិនទាន់សមស្របតាមមាតិកាថវិការដ្ឋនៅឡើយ ។ ជាមួយគ្នានេះ ការរៀបចំអង្គភាពសម្របសម្រួល និង/ឬ ការពង្រឹងសកម្មភាពសវនករ លើដំណើរការអនុវត្តចំណាត់ថ្នាក់ទាំង ៧ គួរត្រូវបានគិតគូរ និងរៀបចំឱ្យបានច្បាស់លាស់ ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ២១ រួមមាន ÷*

- *ពង្រឹងការអនុវត្តចំណាត់ថ្នាក់ទាំង ៧ ដើម្បីមានរបាយការណ៍ដែលអាចវិភាគបាន មានភាពប្រទាក់ក្រឡាគ្នា និងសុក្រឹត្យភាព*
- *គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល មានរបាយការណ៍អនុវត្តថវិកាតាមមាតិកាថវិការដ្ឋពេញលេញ*
- *ពង្រីកវិសាលភាពនៃការរៀបចំស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ។*

### ៣.២.២. គោលបំណង ២២ ÷ ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី

គោលបំណងនេះ សំដៅធានាឱ្យបាននូវការកត់ត្រាគ្រប់ប្រតិបត្តិការចំណូល ចំណាយជាតិ, បិទបញ្ជីគណនេយ្យតាមប្រព័ន្ធ FMIS, និងផលិតរបាយការណ៍សម្រេចទូទាត់ ឬរបាយការណ៍ហិរញ្ញវត្ថុ ដែលទទួលបានតាមរយៈប្រព័ន្ធ FMIS, មានសុក្រឹតភាព និងទាន់ពេលវេលា ។ លើសពីនេះ, នីតិវិធីអនុវត្តការងារសម្រាប់ការអនុវត្តថវិកា លទ្ធកម្ម និងកិច្ចបញ្ជីកាគណនេយ្យ ត្រូវធ្វើតាមរយៈឌីជីថលនីយកម្មនៅក្នុងប្រព័ន្ធ FMIS ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ អង្គភាពទទួលខុសត្រូវលើរៀបចំយន្តការ និងលិខិតបទដ្ឋានគតិយុត្ត និងតាមដានការអនុវត្ត ព្រមទាំងចូលរួមអនុវត្ត រួមមាន ក្រុមការងារ FMIS, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានថវិកា នៃគសហវ, រីឯ ក្រសួង ស្ថាប័ន ជាអង្គភាពចូលរួមអនុវត្តការងារនេះ ។

ជាលទ្ធផល, ប្រព័ន្ធ FMIS ត្រូវបានប្រើប្រាស់ក្នុងការកត់ត្រាប្រតិបត្តិការចំណូល ចំណាយថវិកាជាតិ ជំនួសឱ្យប្រព័ន្ធកុំព្យូទ័រ (ប្រព័ន្ធព័ត៌មានខ្មែរ-KIT) របស់អគ្គនាយកដ្ឋានរតនាគារជាតិ ទាំងស្រុងនៅឆ្នាំ ២០១៧ ដែលអគ្គនាយក

ដ្ឋានរតនាគារជាតិ អាចទាញទិន្នន័យពីប្រព័ន្ធនេះ ក្នុងការរៀបចំរបាយការណ៍សម្រេចទូទាត់បាន ។ ប្រព័ន្ធ FMIS ត្រូវបានអនុវត្តនៅគ្រប់រតនាគាររាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងក្រសួង ស្ថាប័ន ជាមួយនឹងការរៀបចំឱ្យមានឯកសារនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS និងការបណ្តុះបណ្តាលមន្ត្រីជំនាញពាក់ព័ន្ធ ។ ទន្ទឹមនេះ, ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តជាមួយនឹង ៦ ម៉ូឌុលស្នូល (Budget Allocation, Accounts Payable, Accounts Receivable, General Ledger, Purchase Order, និង Cash Management), និងបាននិងកំពុងពង្រីកពីរម៉ូឌុលស្នូលបន្ថែម (Budget Planning និង Procurement) ។ រីឯការធ្វើឌីជីថលនីយកម្មនីតិវិធីអនុវត្តការងារសម្រាប់ការអនុវត្តថវិកា លទ្ធកម្ម និងកិច្ចបញ្ជីការគណនេយ្យនៅក្នុងប្រព័ន្ធ FMIS ក៏ត្រូវបានរៀបចំជាផែនទីបង្ហាញផ្លូវមួយច្បាស់លាស់ផងដែរ ។ បន្ថែមលើនេះ, ប្រព័ន្ធ FMIS ត្រូវបានធ្វើសន្ធានកម្មជាមួយនឹងប្រព័ន្ធគយនិងរដ្ឋាករកម្ពុជា (ASYCUDA), ប្រព័ន្ធពន្ធដារ, ប្រព័ន្ធគ្រប់គ្រងទិន្នន័យបំណុលសាធារណៈ (DMFAS) និងប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)។

ជាមួយនឹងលទ្ធផលល្អប្រសើរទាំងនេះ, គោលបំណង ២២ ក៏នៅមានបញ្ហាប្រឈមមួយចំនួន រួមមាន ÷ (១) របាយការណ៍ចេញពីប្រព័ន្ធ FMIS មិនទាន់អាចប្រើប្រាស់ជារបាយការណ៍សម្រេចទូទាត់តែម្តងបាន ដែលត្រូវតម្រូវឱ្យអគ្គនាយកដ្ឋានរតនាគារជាតិយករបាយការណ៍ទាំងនេះមករៀបចំឡើងវិញ, (២) របាយការណ៍ពីប្រព័ន្ធ FMIS នៅមិនទាន់អាចធ្វើការបង្ហាញព័ត៌មាននៃការធានាចំណាយ និងការទូទាត់ចំណាយទៅតាមដំណាក់កាល តាមតម្រូវការរបស់អគ្គនាយកដ្ឋានថវិកានៅឡើយ, និង (៣) ការបិទបញ្ជីគណនេយ្យសម្រាប់ថវិកាជាតិនៅមានភាពយឺតយ៉ាវ ពីព្រោះអាណត្តិកិច្ចនៅតែបើកឱ្យទូទាត់បន្ទាប់ពីឆ្នាំសារពើពន្ធបានបញ្ចប់ ព្រមទាំងមិនទាន់បានធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS ជាមួយនឹងប្រព័ន្ធគ្រប់គ្រងបុគ្គលិក ។

ជារួម ការអនុវត្តសូចនាករនៃគោលបំណងនេះ មានលក្ខណៈល្អប្រសើរទៅតាមដំណាក់កាលនីមួយៗ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់ ប៉ុន្តែក៏ត្រូវនៅតែបន្តការអនុវត្ត ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ២២ រួមមាន ÷*

- *អនុវត្តឱ្យពេញលេញការធ្វើឌីជីថលនីយកម្មនីតិវិធីអនុវត្តការងារសម្រាប់ការអនុវត្តថវិកា លទ្ធកម្ម និងកិច្ចបញ្ជីការគណនេយ្យនៅក្នុងប្រព័ន្ធ FMIS*
- *ពង្រឹងភាពទាន់ពេលវេលា និងភាពត្រឹមត្រូវនៃរបាយការណ៍សម្រេចទូទាត់ប្រចាំឆ្នាំ*
- *បញ្ចូលការកត់ត្រាការអនុវត្តថវិកាដៃគូអភិវឌ្ឍន៍នៅក្នុងប្រព័ន្ធ FMIS*
- *ធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS ជាមួយប្រព័ន្ធគ្រប់គ្រងបុគ្គលិក ។*

### ៣.២.៣. គោលបំណង ២៣ ÷ ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី និងប្រព័ន្ធរបាយការណ៍ថ្មី

គោលបំណង ២៣ មានគោលដៅចម្បងសម្រេចឱ្យបាននៃការរៀបចំឱ្យមានស្តង់ដារគណនេយ្យសាធារណៈកម្ពុជា ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ (IPSAS) និងធានាប្រសិទ្ធភាព និងតម្លៃនៃលុយលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ, សូចនាករគន្លឹះចំនួន ២ ត្រូវបានកំណត់ រួមមាន (១) ការរៀបចំ និងអនុវត្តពេញលេញនូវស្តង់គណនេយ្យសាធារណៈកម្ពុជា (ស្របតាមស្តង់ដារ IPSAS) ដែលទទួលខុសត្រូវរៀបចំដោយក្រុមប្រឹក្សា-

ជាតិគណនេយ្យ និងទទួលខុសត្រូវអនុវត្តដោយអគ្គនាយកដ្ឋានរតនាគារជាតិ, និង (២) ការរៀបចំនីតិវិធីច្បាស់លាស់ និងប្រព័ន្ធព័ត៌មានវិទ្យាក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ប្រកបដោយប្រសិទ្ធភាព ដែលមានអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ជាអ្នកដឹកមុខក្នុងការរៀបចំ និងសម្របសម្រួលការអនុវត្ត ហើយគ្រប់ក្រសួង ស្ថាប័នជាអ្នកអនុវត្ត ។

ជាលទ្ធផលនៃការអនុវត្តកន្លងមក, ស្តង់ដារគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ត្រូវបានរៀបចំរួចរាល់ និងដាក់ឱ្យអនុវត្តស្របតាមប្រកាសលេខ ៥៤៩ សហវប្រក ចុះថ្ងៃទី. ០៦ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យសាធារណៈ មូលដ្ឋានសាច់ប្រាក់ និងត្រូវបានផ្សព្វផ្សាយដល់ក្រសួងស្ថាប័នរដ្ឋដែលពាក់ព័ន្ធ, និងមានផែនទីបង្ហាញផ្លូវឆ្ពោះទៅការអនុវត្តគណនេយ្យបង្គរពេញលេញចាប់ពីឆ្នាំ ២០៣១ (IPSAS Accrual Basis) ស្របតាមផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ។ ទន្ទឹមនេះ, ផែនការយុទ្ធសាស្ត្រកែទម្រង់គណនេយ្យសាធារណៈកម្ពុជា និងក្របខណ្ឌទស្សនាទានសម្រាប់របាយការណ៍ហិរញ្ញវត្ថុសាធារណៈកម្ពុជា បានអនុម័តរួចរាល់ក្នុងឆ្នាំ ២០២០ នេះផងដែរ ។ អគ្គនាយកដ្ឋានរតនាគារជាតិ បានចាប់ផ្តើមរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដារ IPSAS Cash Basis ចាប់តាំងពីឆ្នាំ ២០១៦ ដោយយកមូលដ្ឋានតួលេខចេញពីប្រព័ន្ធ FMIS ប៉ុន្តែផ្អែកតាមការវាយតម្លៃរបស់ជំនាញការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០១៦ បានបង្ហាញថារបាយ-ការណ៍ ដែលបានរៀបចំនៅមិនទាន់បានអនុលោមតាមស្តង់ដារគណនេយ្យសាធារណៈ មូលដ្ឋានសាច់ប្រាក់បានទាំងស្រុងនោះទេ (អនុលោមតាមលក្ខណៈវិនិច្ឆ័យទាំងស្រុងបានចំនួន ៤៣ និងអនុលោមមិនទាំងស្រុងបានចំនួន ១២ នៃ ៦៣ ចំណុច គឺស្មើនឹង ២/៣) ។ របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានវាយតម្លៃដោយជំនាញការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិថាមានភាពល្អប្រសើរជារៀងរាល់ឆ្នាំ ។

តារាងខាងក្រោម គឺជាលទ្ធផលវាយតម្លៃរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០១៦ ចំនួន ២លើក ដែលលើកចុងក្រោយធ្វើឡើងក្នុងឆ្នាំ ២០១៩ ។

| Category | 2018 | 2019 |
|---|---|---|
| Compliant | 32 | 43 |
| Partial Compliance | | 12 |
| Non-Compliant | 9 | 7 |
| Unable to Assess | 24 | 1 |
| Not Applicable | 13 | 15 |
| **Total** | **78** | **78** |

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បាននិងកំពុងរៀបចំនីតិវិធីគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋជាបណ្តើរៗ តាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ ៦៦ ចុះថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, សារាចរលេខ ០៦ ចុះថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីវិធាន និងលក្ខណៈវិនិច្ឆ័យនៃការធ្វើប្រទានកម្មទ្រព្យសម្បត្តិរដ្ឋជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ, ប្រកាសលេខ ០០២ ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០២០ ស្តីពីវិធាន និងនីតិវិធីលម្អិតនៃការជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, និងការអនុម័តលើសេចក្តីព្រាង

ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ។ ជាមួយគ្នានេះ, ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរៀបចំដោយផ្សារភ្ជាប់ទៅអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋនៅទូទាំងប្រទេស (ក្រសួង ស្ថាប័ន, មន្ទីររាជធានី ខេត្ត, និងរដ្ឋបាលថ្នាក់ក្រោមជាតិ) និងគ្រោងដាក់ឱ្យអនុវត្តជា ២ ជំហាន ក្នុងនោះជំហានទី ១ ÷ ប្រព័ន្ធក្រៅបណ្តាញ (Offline System) ចាប់ពីឆ្នាំ ២០២០ និងជំហានទី ២ ÷ ប្រព័ន្ធអនឡាញ (Online System) ឆ្នាំ២០២៣ ។ ទន្ទឹមនឹងវឌ្ឍនភាព, គោលបំណងនេះ នៅមានបញ្ហាប្រឈមផងដែរ រួមមាន (១) ភាពយឺតយ៉ាវនូវការរៀបចំប្រកាសស្តីពីគំរូនៃសៀវភៅបញ្ជីសារពើភណ្ឌឆ្នាំគោល និងតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ, ២)-ភាពស្មុគស្មាញក្នុងការកំណត់ការវាយតម្លៃទ្រព្យសម្បត្តិឱ្យបានសមស្របតាមក្របខណ្ឌស្តង់ដារគណនេយ្យ IPSAS Cash Basic និងវិធីសាស្ត្រនៃការវាយតម្លៃទ្រព្យសម្បត្តិទៅតាមប្រភេទផ្សេងៗគ្នា, និង (៣) ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) មិនទាន់បានពេញលេញទៅកាន់គ្រប់អង្គភាពគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

ជារួម គោលបំណង ២៣ សម្រេចបានវឌ្ឍនភាពល្អ ប៉ុន្តែគោលបំណងនេះគួរបែងចែកជាពីរ គឺ (១) ការងាររៀបចំ និងអនុវត្តស្តង់ដារគណនេយ្យសាធារណៈ, និង (២) ការងារពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ២៣ រួមមាន ÷*

- *រៀបចំស្តង់ដារគណនេយ្យសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈ*
- *ពង្រឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារគណនេយ្យ IPSAS Cash Basic ឱ្យបានពេញលេញ និងបន្តអនុវត្តតាមផែនទីចង្អុលផ្លូវសម្រាប់ស្តង់ដារគណនេយ្យសាធារណៈនៅក្នុងប្រទេសកម្ពុជា*
- *បញ្ចប់ការរៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់គណនេយ្យសាធារណៈកម្ពុជា ២០១៩-២០៣១ និងរៀបចំស្តង់ដាគណនេយ្យសាធារណៈស្តីពីផលរបរពីប្រតិបត្តិការមិនដោះដូរ និងស្តង់ដាគណនេយ្យសាធារណៈសម្រាប់កត់ត្រា សន្និធិ និងស្តង់ដាគណនេយ្យសាធារណៈសម្រាប់កត់ត្រាពីការលាតត្រដាងព័ត៌មានរបស់ភាគីពាក់ព័ន្ធ*
- *រៀបចំនីតិវិធីគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋដោយត្រូវរៀបចំក្របខណ្ឌពេលវេលាឱ្យបានច្បាស់លាស់ក្នុងការបញ្ចប់ការរៀបចំអនុក្រឹត្យ/ប្រកាសពាក់ព័ន្ធដែលនៅសេសសល់*
- *ពង្រីកការប្រើប្រាស់ប្រព័ន្ធ SARMIS ទៅកាន់គ្រប់ក្រសួង ស្ថាប័ន, មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ទន្ទឹមនឹងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធ SARMIS ពីប្រព័ន្ធ Offline ទៅជាប្រព័ន្ធ Online Web-Based Application និងជំរុញការធ្វើសន្ទានកម្មជាមួយនឹងប្រព័ន្ធ FMIS ។*

### ៣.២.៤. គោលបំណង ២៤ ÷ ពង្រឹងការអនុវត្តឧបករណ៍ និង យន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព

គោលបំណងនេះ ផ្តោតលើការរៀបចំឱ្យមានឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព តាមរយៈការបង្កើនសិទ្ធអំណាច និងការទទួលខុសត្រូវជូនអង្គភាពថវិកាជាមួយនឹងការរៀបចំឱ្យមានក្របខណ្ឌគតិយុត្តលើទណ្ឌកម្មរដ្ឋបាលសមស្រប ចំពោះកំហុសឆ្គង ឬ ការគ្រប់គ្រងធនធានសាធារណៈ មិនសមស្រប និងគ្មានប្រសិទ្ធភាព ។ ដើម្បីសម្រេចបានជោគជ័យនូវគោលបំណងនេះ ចាំបាច់ត្រូវរៀបចំ (១) សិទ្ធិអំណាច និងការ

ទទួលខុសត្រូវពេញលេញរបស់អង្គភាពអនុវត្តធនធានសាធារណៈ, (២) ការធ្វើសវនកម្មលើការប្រើប្រាស់ធនធានសាធារណៈ និង (៣) ទណ្ឌកម្មរដ្ឋបាលសមស្រប ក្នុងករណីរកឃើញថាមានកំហុសឆ្គង ឬ ការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព ។

ជាលទ្ធផល, គោលបំណងនេះហាក់បីជារៀបចំនៅក្នុងផែនការ CAP3 ពុំទាន់ពេញលេញ និងពុំទាន់មានអង្គភាពទទួលខុសត្រូវក្នុងការរៀបចំនីតិវិធី និងយន្តការសម្រាប់ការងារបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាពនៅឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ, គោលបំណងនេះ ក៏មានវឌ្ឍនភាពគួរឱ្យកត់សំគាល់មួយចំនួនផងដែរ ដូចជា ÷(១) នៅក្នុងឆ្នាំ២០១៩ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធ មានចំនួន ៦៦៤ នៃអង្គភាពថវិកាសរុប ៩១២, (២) សៀវភៅកម្រងសម្រង់វិធានការរួមនៃការដាក់ទណ្ឌកម្មហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងទណ្ឌកម្មរដ្ឋបាលចំពោះកំហុសឆ្គង ឬគ្រប់គ្រងធនធានសាធារណៈមិនសមស្រប ត្រូវបានធ្វើបច្ចុប្បន្នភាព និង (៣) អង្គភាពក្រោមឱវាទ កសហវ ចំនួន ៦ និង អង្គភាពថវិកាចំនួន ៤ នៃក្រសួង ស្ថាប័នគោលដៅត្រូវបានធ្វើសវនកម្មលើប្រព័ន្ធ FMIS ។ ចំពោះការរៀបចំកែសម្រួលទម្រង់របាយការណ៍អនុវត្តថវិកា និងទម្រង់របាយការណ៍សមិទ្ធកម្មរបស់អង្គភាពថវិកាគួរធ្វើការផ្លាស់ប្តូរទៅផ្នែកទី ៣ នៅក្រោមគោលបំណង ៣១ វិញ ។ នៅក្នុងគោលបំណងនេះ បញ្ហាជាច្រើនបានលេចឡើងនៅក្នុងដំណាក់កាលទី ៣ ដែលពុំទាន់មានអង្គភាពទទួលខុសត្រូវសម្រាប់រៀបចំផ្តល់សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញជូនអង្គភាពថវិកា និងអង្គភាពទទួលខុសត្រូវសម្រាប់រៀបចំឱ្យមានទណ្ឌកម្មរដ្ឋបាលសមស្រប ។ នៅក្នុងគោលបំណងនេះ, ការរៀបចំធ្វើសវនកម្មមានតែលើប្រព័ន្ធ FMIS ដោយពុំទាន់បានបញ្ជាក់អំពីការធ្វើសវនកម្មលើការប្រើប្រាស់ធនធានសាធារណៈនៅឡើយ ជាហេតុធ្វើឱ្យវឌ្ឍនភាពសម្រាប់គោលបំណងនេះ មិនទាន់អាចបញ្ជាក់អំពីការសម្រេចបានពេញលេញបាន ។ ជាទិសដៅទៅមុខសម្រាប់គោលបំណងនេះ គួររៀបចំរចនាសម្ព័ន្ធឡើងវិញទៅតាមគោលដៅនៃគោលបំណង និងកំណត់ឱ្យជាក់លាក់នូវការងារ និងការទទួលខុសត្រូវ ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ២៤ រួមមាន ÷*

- *រៀបចំឱ្យមានយន្តការច្បាស់លាស់ ក្នុងផ្តល់ភាពទន់ភ្លន់ សិទ្ធិអំណាច និងការទទួលខុសត្រូវពេញលេញជូនអង្គភាពថវិកា ដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព*
- *គួររៀបចំឱ្យមានការធ្វើសវនកម្មលើការប្រើប្រាស់ធនធានសាធារណៈ ដើម្បីបញ្ជាក់អំពីភាពសមស្រប និងប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានសាធារណៈ*
- *កែលម្អ និងអនុវត្តទណ្ឌកម្មរដ្ឋបាលសមស្រប ចំពោះកំហុសឆ្គង ឬ ការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព ។*

### ៣.២.៥. គោលបំណង ២៥ ÷ បង្កើនតម្លាភាពថវិកា

គោលបំណង ២៥ សំដៅវាយតម្លៃលើប្រភេទឯកសារ និងភាពទាន់ពេលវេលានៃការផ្សព្វផ្សាយឯកសារពាក់ព័ន្ធនឹងថវិកា ដោយផ្តោតជាសំខាន់លើការបើកចំហព័ត៌មានថវិកាក្នុងបរិការណ៍កម្ពុជា ។ ការផ្សព្វផ្សាយឯកសារថវិកាអាចត្រូវបានធ្វើឡើងតាមទម្រង់ជាការរៀបចំវេទិកាសាធារណៈ, សិក្ខាសាលាពិគ្រោះយោបល់ និងផ្សព្វផ្សាយនៅលើគេហទំព័ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ចាប់តាំងពីឆ្នាំ ២០១៧-២០១៩, ឯកសារពាក់ព័ន្ធនឹងថវិកា និងរបាយការណ៍ថវិកាជាច្រើនត្រូវបានធ្វើការផ្សព្វផ្សាយនៅលើគេហទំព័រ ជាពិសេស ឯកសារទាំង ៨ ប្រភេទ រួមមាន (១) សារាចរណែនាំស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ, (២) សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល, (៣) ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលបានអនុម័ត, (៤) របាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ, (៥) របាយការណ៍ក្នុងឆ្នាំ, (៦) របាយ-ការណ៍ពាក់កណ្តាលឆ្នាំ, (៧) របាយការណ៍ដំណាច់ឆ្នាំ, និង (៨) របាយការណ៍សវនកម្ម ដែលត្រូវបានប្រើប្រាស់ សម្រាប់ធ្វើការអង្កេតលើការបើកចំហព័ត៌មានថវិកា ។ វេទិកាសាធារណៈស្តីពីការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌគ្រប់គ្រងថវិកាប្រចាំឆ្នាំត្រូវបានរៀបចំជាប្រចាំឆ្នាំ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ។ ទោះបីជាយ៉ាងនេះ វេទិកានេះមិនទាន់មានលក្ខណៈជាសាធារណៈនៅឡើយ ។ សិក្ខាសាលាពិគ្រោះយោបល់លើវិស័យអាទិភាពពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល និងសហគ្រិនភាពត្រូវបានរៀបចំនៅឆ្នាំ ២០១៨ ។

ជាលទ្ធផលដោយផ្អែកលើការអង្កេតថវិកាបើកចំហ (Open Budget Survey–OBS) បង្ហាញថា កម្ពុជាមានវឌ្ឍនភាពល្អ ក្នុងនោះឆ្នាំ ២០០៨ ទទួលបាន ១១ ពិន្ទុ, ឆ្នាំ ២០១០ ទទួលបាន ១៥ ពិន្ទុ, ឆ្នាំ ២០១២ ទទួលបាន ១៥ ពិន្ទុ, ឆ្នាំ ២០១៥ ទទួលបាន ៨ ពិន្ទុ, ឆ្នាំ ២០១៧ ទទួលបាន ២០ ពិន្ទុ, និងឆ្នាំ ២០១៩ កម្ពុជាទទួលបានពិន្ទុ ៣២ ក្នុងការបើកចំហរព័ត៌មានថវិកា ។ ប្រសិនបើប្រៀបធៀបនឹងប្រទេសនានាលើសាកលលោក, កម្ពុជាទទួលបានចំណាត់ថ្នាក់ ៨៦/១១៧ សម្រាប់ការបើកចំហរព័ត៌មានថវិកា ។

| ឯកសារ | ២០០៨ | ២០១០ | ២០១២ | ២០១៥ | ២០១៧ | ២០១៩ |
|---|---|---|---|---|---|---|
| សារាចរណែនាំស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងប្រចាំឆ្នាំ | 🟡 | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល | 🟡 | 🟡 | 🟡 | 🟡 | 🟡 | 🟢 |
| ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលបានអនុម័ត | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| របាយការណ៍ថវិកាសម្រាប់ប្រជាពលរដ្ឋ | 🚫 | 🚫 | 🚫 | 🟡 | 🟢 | 🟢 |
| របាយការណ៍ក្នុងឆ្នាំ | 🟢 | 🟢 | 🟢 | 🟡 | 🟢 | 🟢 |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | 🟡 | 🟡 | 🟡 | 🟡 | 🟢 | 🟢 |
| របាយការណ៍ដំណាច់ឆ្នាំ | 🟢 | 🟢 | 🟢 | 🚫 | 🟡 | 🟢 |
| របាយការណ៍សវនកម្ម | 🟡 | 🟡 | 🟡 | 🚫 | 🟢 | 🟢 |

🟢 ផ្សព្វផ្សាយជាសាធារណៈ 🟡 ផ្សព្វផ្សាយយឺត ឬ សម្រាប់ប្រើប្រាស់ផ្ទៃក្នុង 🚫 មិនបានផលិត

គួរបញ្ជាក់ថា សម្រាប់ការអង្កេតថវិកាបើកចំហ កម្ពុជានៅទទួលបានពិន្ទុទាបនៅឡើយ ក្នុងការចូលរួមរបស់សាធារណជនលើការរៀបចំថវិកា ។ ម្យ៉ាងវិញទៀត, ឯកសារដែលបានផ្សព្វផ្សាយនោះនៅពុំទាន់បានផ្សព្វផ្សាយឱ្យមានភាពទូលំទូលាយ លើកលែងតែឯកសារថវិកាដែលបានអនុម័តរួចប៉ុណ្ណោះ និងមិនទាន់ធ្វើក្នុងទម្រង់ទន់ នៅឡើយ ។ ដោយឡែក, សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល និងរបាយការណ៍ថវិកាប្រចាំឆ្នាំ បានផ្សព្វផ្សាយយឺតជាងពេលវេលានៃការបិទបញ្ចប់ការអង្កេត ដែលការផ្សព្វផ្សាយនេះ ត្រូវចាត់ទុកថាពុំបានធ្វើការផ្សព្វផ្សាយឡើយ ។

ជារួម សម្រាប់គោលបំណង ២៥ មានវឌ្ឍនភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ គោលបំណងនេះ គួរបន្តរក្សាការអនុវត្តសម្រាប់ផែនការសកម្មភាពរួម ដំណាក់កាលទី ៤ ដើម្បីរក្សា និងបង្កើនពិន្ទុនៃការអង្កេតថវិកាបើកចំហរបស់កម្ពុជាតាមរយៈការគ្រោងសកម្មភាពជាក់ស្តែង ស្របតាមលក្ខខណ្ឌនៃ OBS ដែលរៀបចំដោយ IBP និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ២៤ រួមមាន ÷*

- *ផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ជាឯកសារទន់ មុននឹងផ្ញើជូនរដ្ឋសភាពិនិត្យ*
- *បង្កើតយន្តការទូលំទូលាយសម្រាប់សាធារណជនចូលរួមនៅគ្រប់វដ្តថវិកា ទាំងការរៀបចំថវិកា, ការអនុម័តថវិកា, ការអនុវត្តថវិកា និងការធ្វើសវនកម្ម ។*

### ៣.២.៦. សេចក្តីសន្និដ្ឋានផ្នែកទី ២

វឌ្ឍនភាពជារួម ផ្នែកទី ២ មានភាពល្អប្រសើរលើការងារដាក់ឱ្យដំណើរការប្រព័ន្ធ FMIS នៅគ្រប់រតនាគាររាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ច និងហិរញ្ញរាជធានី ខេត្ត និងគ្រប់ក្រសួង ស្ថាប័ន ។ ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ត្រូវបានអនុម័តដាក់ឱ្យអនុវត្ត និងមានគោលដៅទៅអនុវត្តការងារដោយស្វ័យប្រវត្តិនៅក្នុងប្រព័ន្ធនេះ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នចំនួន[6] ៧ ត្រូវបានអនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមរយៈប្រព័ន្ធ FMIS សម្រាប់ការបើកផ្តល់បៀវត្ស, ការចំណាយលើបន្ទុកបុគ្គលិកផ្សេងៗក្រៅពីបៀវត្សដែលមានគោលរបបកំណត់ច្បាស់លាស់ និងការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបផ្សេងទៀតជាផ្លូវការ ។ លើសពីនេះ, អគ្គនាយកដ្ឋានរតនាគារជាតិ ប្រើប្រាស់ប្រព័ន្ធ FMIS តែមួយគត់ក្នុងការកត់ត្រាបិទបញ្ជីគណនេយ្យ និងរៀបចំរបាយ-ការណ៍សម្រេចទូទាត់ ។ ស្តង់ដារគណនេយ្យសាធារណៈកម្ពុជា ក៏ត្រូវបានរៀបចំដាក់ឱ្យអនុវត្តជាមួយនឹងផែនទីបង្ហាញផ្លូវសម្រាប់ឆ្ពោះទៅគណនេយ្យបង្គរ ។ ចំពោះរបាយការណ៍នៅក្នុងប្រព័ន្ធ FMIS ត្រូវបានកត់ត្រាទៅតាមចំណាត់ថ្នាក់ថវិកាទាំង ៧ ប៉ុន្តែអនុវត្តពេញលេញបានតែ ៥ ចំណាត់ថ្នាក់ប៉ុណ្ណោះ លើកលែងតែចំណាត់ថ្នាក់ភូមិសាស្ត្រ និងចំណាត់ថ្នាក់មុខងារកំពុងបន្តជំរុញការអនុវត្ត ។ ជាមួយគ្នានេះ, ការរៀបចំវេទិកាសាធារណៈ និងការបើកចំហព័ត៌មានថវិកាដល់សាធារណជនក៏បានពង្រឹងពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាហេតុធ្វើឱ្យសន្ទស្សន៍នៃការបើកចំហថវិការបស់កម្ពុជាបានកើនឡើងជាលំដាប់នៅក្នុងការអង្កេតលើការបើកចំហព័ត៌មានថវិកាជាសកលរៀងរាល់ ២ ឆ្នាំម្តង ។

ទន្ទឹមនឹងវឌ្ឍនភាពដ៏ល្អប្រសើរ, ក៏នៅមានការងារមួយចំនួន មិនទាន់សម្រេចបានតាមការគ្រោងទុកផងដែរ ។ ការរៀបចំប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ហាក់នូវមានវឌ្ឍនភាពយឺតជាងផែនការ ដែលរហូតមកដល់ពេលនេះប្រព័ន្ធត្រូវបានរៀបចំរួចរាល់ ប៉ុន្តែមិនទាន់ត្រូវបានដាក់ឱ្យអនុវត្តពេញលេញនៅតាមក្រសួង ស្ថាប័ន នៅឡើយ ដោយសារធនធានភាគច្រើនត្រូវបានប្រើប្រាស់ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។ ទោះបីជាប្រព័ន្ធ FMIS មានដំណើរការរលូនទៅតាមផែនការក្តី ក៏ការផលិតរបាយការណ៍សម្រេចទូទាត់ថវិកាជាតិមិនទាន់អាច

[6] ក្រសួង-ស្ថាប័នចំនួន ៧ ÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ,ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា

ទាញពីប្រព័ន្ធបាននៅឡើយ ហើយការធ្វើសមាហរណកម្មប្រព័ន្ធ FMIS ជាមួយប្រព័ន្ធផ្សេងទៀតនៅមានវឌ្ឍនភាពតិចតួច ដូចជាប្រព័ន្ធគ្រប់គ្រងបុគ្គលិក ប្រព័ន្ធពន្ធដារ ជាដើម ។

*ទិសដៅទៅមុខសម្រាប់ផែនការសកម្មភាពរួម ដំណាក់កាលទី ៤ គណនេយ្យភាពសមិទ្ធកម្ម គួរផ្តោតលើការងារមួយចំនួន ដូចខាងក្រោម ៖*

- *ពង្រឹងលើការអនុវត្តស្វ័យប្រវត្តិកម្មនៃប្រព័ន្ធ FMIS*
- *ពង្រឹងការអនុវត្តចំណាត់ថ្នាក់ថវិកាទាំង ៧ ឱ្យបានពេញលេញ និងពង្រីកការអនុវត្តចំណាត់ថ្នាក់ទាំងនេះទៅដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល*
- *ពង្រឹងប្រព័ន្ធគណនេយ្យសាធារណៈកម្ពុជា ឆ្ពោះទៅប្រព័ន្ធមូលដ្ឋានសាច់ប្រាក់កែសម្រួល (Modified Cash Basis)*
- *រៀបចំការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋប្រកបដោយប្រសិទ្ធភាព*
- *បន្តបង្កើនសន្ទស្សន៍នៃការបើកចំហថវិកាតាមបរិការណ៍ជាក់ស្តែងកម្ពុជា ។*

## ៣.៣. ផ្នែកទី ៣ ៖ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ផ្នែកទី ៣ នេះ ផ្តោតលើគោលបំណងចម្បង ៣ គឺ(១) ក្របខណ្ឌថវិការយៈពេលមធ្យម(ដែលរួមមានក្របខណ្ឌចំណូលរយៈពេលមធ្យម, ក្របខណ្ឌចំណាយរយៈពេលមធ្យម, និងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម) ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុម័តដោយគណៈរដ្ឋមន្ត្រីនិងអនុវត្តប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព, (២) ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំ និងអនុវត្តប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព, និង (៣) ថវិកាកម្មវិធី និងអង្គភាពថវិកាត្រូវបានអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ។ ជាលទ្ធផល ឯកសារទស្សនទានក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ត្រូវបានអនុម័តក្នុងឆ្នាំ ២០១៩ និងបានអនុវត្តសាកល្បងក្នុងឆ្នាំ ២០២០ សម្រាប់ការវិភាគថវិកាទៅតាមវិស័យ និងកម្រិតនូវពិតានចំណាយរបស់ក្រសួង ស្ថាប័ន នីមួយៗ ។ ការរៀបចំ MTBF និងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) ដោយឡែក និងគ្រប់ជ្រុងជ្រោយជំរុញឱ្យការរៀបចំផែនការថវិកាឈានទៅរកសុក្រឹត្យភាពទាំងក្នុងទិដ្ឋភាពនៃការព្យាករណ៍, តម្រូវការអាទិភាពចំណាយ និងការឆ្លើយតបទៅនឹងកម្មវិធីគោលនយោបាយរបស់ក្រសួង ស្ថាប័ន និងរាជរដ្ឋាភិបាល ។ ការរៀបចំផែនការថវិកា ត្រូវអនុលោមតាមគោលការណ៍ដែលមានចែងក្នុងសារាចររៀបចំណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល ដែលក្នុងនោះមានរំលេចពីក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។ យ៉ាងណាមិញ គម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងកញ្ចប់ថវិកា គឺជាបញ្ហាបង្កឱ្យផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិលមិនមានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងថវិការយៈពេលមធ្យម ។ គិតត្រឹមឆ្នាំ២០១៨ គ្រប់ក្រសួង ស្ថាប័ន បានអនុវត្តថវិកាកម្មវិធី និងឆ្នាំ២០២០ រដ្ឋបាលខេត្តចំនួន ២៤ បានអនុវត្តថវិកាកម្មវិធី ហើយរដ្ឋបាលរាជធានីភ្នំពេញនឹងអនុវត្តចុងក្រោយគេនៅឆ្នាំ២០២១ ។ សរុបត្រឹមដំណាក់កាលទី ៣ អង្គភាពថវិកាមានចំនួន ៩៦២ ក្នុងនោះថ្នាក់កណ្តាលមានចំនួន ៣៩៩ និងថ្នាក់មូលដ្ឋានមានចំនួន ៦៦៤ ។ ការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី តាមគោលរបបជាប្រចាំ និងការត្រួតពិនិត្យលើគុណភាពនៃការអនុវត្ត

របស់អង្គភាពថវិកា គឺជាកត្តាដ៏សំខាន់ក្នុងការធានានូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។ ក្នុងន័យនេះ ការតាមដានការអនុវត្តថវិកាកម្មវិធីតាមគោលរបបប្រជុំច្បាស់លាស់ និងទៀងទាត់ នឹងជំរុញប្រសិទ្ធភាពនៃការអនុវត្តថវិកាផ្សារភ្ជាប់នឹងថវិកាកម្មវិធីដែលកិច្ចការនេះនៅបន្តជំរុញបន្ថែមនៅជំហានបន្ទាប់ ។

នៅក្នុងផ្នែកទី ៣នេះ មានគោលបំណងចំនួន ៤ រួមមាន ÷ (១) ការពង្រឹងនិងការពង្រីកការអនុវត្តថវិកាកម្មវិធី, (២) ការរៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា, (៣) រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព, និង (៤) ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ។

### ៣.៣.១. គោលបំណង ៣១ ÷ ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកា

គោលបំណង ៣១ ផ្តោតលើការអនុវត្តថវិកាកម្មវិធីក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ចំនួន ២៥ ប្រកបដោយប្រសិទ្ធភាព ។ លទ្ធផលសម្រេចបានពីការអនុវត្ត គឺឆ្លើយតបនឹងសូចនាករគោលបំណងដែលបានកំណត់ដោយការគ្រោងសកម្មភាពសម្រាប់អនុវត្តរបស់អគ្គនាយកដ្ឋានពាក់ព័ន្ធនៅក្នុងឆ្នាំនីមួយៗ មានសង្គតិភាពជាមួយចង្កោមសកម្មភាពដែលបានគ្រោងនៅក្នុងផែនការសកម្មភាពរួម ។ ការអនុវត្តថវិកាកម្មវិធី ត្រូវបានគាំទ្រតាមរយៈការរៀបចំនូវយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ (BSRS) និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ ដោយបានរៀបចំជាផែនការសកម្មភាពច្បាស់លាស់សម្រាប់អនុវត្ត ។ ជាក់ស្តែង, នៅត្រឹមឆ្នាំ ២០១៨ គ្រប់ក្រសួង ស្ថាប័ន បានអនុវត្តថវិកាកម្មវិធី ។ ទន្ទឹមនឹងនេះ យោងតាមផែនការសកម្មភាពសម្រាប់អនុវត្ត BSRS រដ្ឋបាលថ្នាក់ក្រោមជាតិ, នៅឆ្នាំ២០១៩ រដ្ឋបាលខេត្តចំនួន ១៨ បានអនុវត្តថវិកាកម្មវិធី និងទទួលបានការបណ្តុះបណ្តាលអំពីនីតិវិធីស្តីពីការរៀបចំ និងអនុវត្តថវិកាកម្មវិធី ។ រដ្ឋបាលរាជធានី ខេត្ត ទាំង២៥ នឹងត្រូវអនុវត្តថវិកាកម្មវិធីត្រឹមឆ្នាំ ២០២១ ។

*ផែនការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលរាជធានីខេត្ត-*

| ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| កំពង់ស្ពឺ | កំពង់ឆ្នាំង | កណ្តាល | កំពង់ចាម | រាជធានីភ្នំពេញ[7] |
| កែប | ពោធិ៍សាត់ | បាត់ដំបង | កំពង់ធំ | |
| កោះកុង | តាកែវ | បន្ទាយមានជ័យ | ព្រះវិហារ | |
| ប៉ៃលិន | កំពត | ស្វាយរៀង | ឧត្តរមានជ័យ | |
| ក្រចេះ | ព្រៃវែង | ត្បូងឃ្មុំ | សៀមរាប | |
| ស្ទឹងត្រែង | រតនគិរី | មណ្ឌលគិរី | ព្រះសីហនុ | |

ទោះបីជាយ៉ាងនេះក្តី, ការតាមដានលើការអនុវត្តថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័ន និងការផ្ទេរសិទ្ធអំណាចឱ្យអង្គភាពថវិកា គួរត្រូវបានបន្តពង្រឹង ។ គិតត្រឹមឆ្នាំ ២០១៩, អង្គភាពថវិកាថ្នាក់មូលដ្ឋានចំនួន ៦០៤ ត្រូវបានផ្ទេរសិទ្ធិ

[7] *ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី បានឯកភាពលើសំណើរបស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយពន្យារពេលការដាក់ រដ្ឋបាលរាជធានីភ្នំពេញ អនុវត្តថវិកាកម្មវិធី រហូតដល់ឆ្នាំ២០២១ ។*

ទាំងអស់ ក៏ប៉ុន្តែអង្គភាពថវិកាថ្នាក់កណ្តាលចំនួន ៣០៨ ក្នុងនោះអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមានចំនួន ៦០ និងមិនទាន់ផ្ទេរសិទ្ធិចំនួន ២៤៨ ។

ជារួម សម្រាប់គោលបំណង ៣១ សម្រេចបានវឌ្ឍនភាពល្អ ។ សូចនាករសមិទ្ធកម្មគន្លឹះនៃគោលបំណងនេះគួរកែសម្រួលទៅជាចង្កោមសកម្មភាពសម្រាប់ការរៀបចំផែនការសកម្មភាពនៅដំណាក់កាលបន្ទាប់ ដោយផ្តោតលើការតាមដានការអនុវត្ត និងការផ្ទេរសិទ្ធិអំណាច ។ គួរបង្កើតគោលបំណងថ្មីសម្រាប់ដំណាក់កាលបន្ទាប់ ដោយផ្តោតលើការអនុវត្តថវិកាសមិទ្ធកម្ម ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៣១ រួមមាន ÷*

- *កែសម្រួលគោលបំណងនេះ ទៅជាចង្កោមសកម្មភាព ដោយផ្តោតលើការតាមដានការអនុវត្ត និងការផ្ទេរសិទ្ធិអំណាច ។*

### ៣.៣.២. គោលបំណង ៣២ ÷ រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា

គោលបំណង ៣២ ផ្តោតលើប្រតិបត្តិការទាំងអស់ត្រូវស្ថិតនៅក្នុងប្រព័ន្ធថវិកា និងការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ។ គ្រប់ក្រសួង ស្ថាប័ន បានរៀបចំផែនការយុទ្ធសាស្ត្រថវិកា តាមគោលបំណងគោលនយោបាយ និងកម្មវិធី ដោយកំណត់សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ការអនុវត្ត និងត្រួតពិនិត្យតាមដានលទ្ធផល ។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ត្រូវផ្អែកលើពិតានចំណាយ ដែលបានកំណត់នៅក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខណ្ឌថវិការយៈពេលមធ្យម ។ ការបញ្ចូលចំណូល ចំណាយដែលនៅក្រៅបរិបទថវិកាទៅក្នុងថវិកាប្រចាំឆ្នាំ និងថវិកាដៃគូអភិវឌ្ឍន៍ ត្រូវបានកត់ត្រាតាមមាតិកាគណនីនៃប្លង់គណនេយ្យថវិកា (Chart of Accounts-COA) ថ្មី សម្រាប់គម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដោយចាប់ផ្តើមអនុវត្តនៅក្រសួងសុខាភិបាល, អ.ហ.គ., និងក្រសួងអភិវឌ្ឍន៍ជនបទ រីឯក្រសួង ស្ថាប័នផ្សេងទៀតនឹងត្រូវបានគិតគូរដាក់ឱ្យអនុវត្តជាបណ្តើរៗ ។ ដោយឡែកការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន កំពុងត្រូវបានរៀបចំជាសេចក្តីព្រាងឯកសារទស្សនាទាន ។

ទោះបីជាយ៉ាងនេះក្តី, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង ស្ថាប័ន នៅមានកម្រិតនៅឡើយ ជាពិសេសបញ្ហាប្រឈមទាក់ទងនឹងការកំណត់គោលបំណងគោលនយោបាយ ។ រចនាសម្ព័ន្ធកម្មវិធី និងស្ថាប័ន និងសូចនាករគន្លឹះទាំងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅពុំទាន់មានការណែនាំជាក់លាក់ដើម្បីពន្យល់ពីផលប៉ះពាល់នៃសកម្មភាពកម្មវិធីជាក់លាក់ណាមួយលើគោលនយោបាយរបស់រដ្ឋាភិបាល សម្រាប់ការកាត់បន្ថយភាពក្រីក្រ ឬសមភាពយេនឌ័រ ។ ការធ្វើសមាហរណកម្មរវាងចំណាយចរន្ត និងវិនិយោគតាមកម្មវិធី នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាដែលបានរៀបចំ និងអនុវត្តសាកល្បង ។

ជារួមគោលបំណងនេះ មានវឌ្ឍនភាពល្អ តែគួរយកចិត្តបន្ថែមលើសមាហរណកម្មរវាងចំណាយមូលធន និងថវិកាចរន្តនៅកម្រិតវិស័យ និងក្រសួង តាមរយៈការគ្រោងថវិកាផ្អែកលើក្របខណ្ឌ MTFF និង MTBF និងផែនការសកម្មភាព BSRS ។ សកម្មភាពនៃ BSP និង PB គួររួមបញ្ចូលជាសកម្មភាពរយៈពេលមធ្យមតែមួយសម្រាប់ការអនុវត្ត

ចៀសវាងការត្រោងសកម្មភាពទ្វេដង ។ ធនធានមនុស្ស និងការសម្របសម្រួលស្ថាប័ន ត្រូវបន្តពង្រឹង និងអភិវឌ្ឍន៍បន្ថែម ដើម្បីឱ្យការប្រមូល និងត្រួតពិនិត្យទិន្នន័យ ឬ ការរៀបចំរបាយការណ៍ឱ្យបានទូលំទូលាយ និងទាន់ពេលវេលា ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៣២ រួមមាន ៖*

- *ត្រូវបន្តពង្រឹងធនធានមនុស្ស និងការសម្របសម្រួលស្ថាប័ន*
- *បន្តពិនិត្យលើសមាហរណកម្មថវិការវាងចំណាយមូលធន និងថវិកាចរន្តនៅកម្រិតវិស័យ និងក្រសួង ។*

### ៣.៣.៣. គោលបំណង ៣៣ ៖ រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ, រវាង គសហវ និង ក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង ស្ថាប័ន)

គោលបំណង ៣៣ ផ្តោតលើការកំណត់ និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាពស្របតាមថវិកាកម្មវិធី ។ យុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងវិនិយោគសាធារណៈ ២០១៩-២០២៥ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីពង្រឹងប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាពលើការគ្រប់គ្រងការវិនិយោគសាធារណៈ ។ អនុក្រឹត្យនេះមានសារៈសំខាន់ក្នុងការបញ្ជាក់ពីការរៀបចំបន្ទាត់គណនេយ្យភាពក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈរវាងតួអង្គពាក់ព័ន្ធ រួមមាន គោលការណ៍ និងលក្ខខណ្ឌតម្រូវ, ដំណាក់កាលរួមនៃវដ្តគម្រោងវិនិយោគសាធារណៈ, តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន, អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ, ការផ្សារភ្ជាប់រវាងផែនការវិនិយោគជាមួយនឹងថវិកានីយកម្ម, នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងការគ្រប់គ្រង, និង កាតព្វកិច្ចរបាយការណ៍ ។

ទោះបីជាយ៉ាងនេះក្តី, ការអនុវត្តនៅពុំទាន់មានយន្តការកំណត់ និងការដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាពស្របតាមថវិកាកម្មវិធី (រវាងនីតិប្បញ្ញត្តិ និង នីតិប្រតិបត្តិ, រវាងគសហវ និងក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង ស្ថាប័ន) មុនពេលយុទ្ធសាស្ត្រ និងអនុក្រឹត្យស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ ត្រូវបានរៀបចំ ។ ប្រកាសស្តីពីការកំណត់កម្រិត និងអ្នកទទួលខុសត្រូវតាមកម្មវិធីគោលនយោបាយ/កម្មវិធី/អនុកម្មវិធីរបស់ក្រសួង មិនទាន់បានរៀបចំពេញលេញ ។ ទន្ទឹមនឹងនេះ ការពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងក្របខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងបរិបទនៃការអនុវត្តថវិកាកម្មវិធី មិនទាន់ត្រូវបានរៀបចំការតាមដាន និងយន្តការវាយតម្លៃ ។

ជារួម គោលបំណងនេះ មានវឌ្ឍនភាពទៅតាមគោលដៅរំពឹងទុក ប៉ុន្តែត្រូវបន្តតាមដានលើការអនុវត្តឯកសារ និងក្របខណ្ឌគតិយុត្តិពាក់ព័ន្ធនានាដើម្បីពង្រឹងលើការកំណត់ និងបង្កើនប្រសិទ្ធភាពនៃបន្ទាត់គណនេយ្យភាព ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៣៣ រួមមាន ៖*

- *ពង្រឹងយន្តការកំណត់ និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាពស្របតាមថវិកាកម្មវិធី (រវាងនីតិប្បញ្ញត្តិ និង នីតិប្រតិបត្តិ, រវាងគសហវ និងក្រសួង ស្ថាប័ន និងនៅក្នុងក្រសួង-ស្ថាប័ន)*
- *បន្តរៀបចំពេញលេញនូវប្រកាសកំណត់កម្រិត និងអ្នកទទួលខុសត្រូវតាមកម្មវិធីគោលនយោបាយ/កម្មវិធី/អនុកម្មវិធីរបស់ក្រសួង*
- *រៀបចំយន្តការតាមដាន និងវាយតម្លៃ ។*

### ៣.៣.៤. គោលបំណង ៣៤ ÷ ពង្រឹងការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយ និងផែនការចំណូល និងចំណាយរយៈពេលមធ្យម)

ក្នុងឆ្នាំ ២០១៦ ឯកសារទស្សនាទាននៃក្របខណ្ឌចំណាយរយៈពេលមធ្យម (Medium-Term Expenditure Framework-MTEF) ត្រូវបានរៀបចំដោយបង្ហាញពីការផ្សារភ្ជាប់គ្នារវាងគោលនយោបាយជាតិនានា និង BSP របស់ក្រសួង ស្ថាប័ន ដោយមានបែងចែកចេញជា ២ គឺក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ (MTFF) និងក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ។ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី និងសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ (ឆ្នាំ២០១៧-២០២១) ។ ផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងការផ្ទុះនូវជំងឺកូវីដ-១៩, ការរៀបចំ MTFF ត្រូវបានពន្យារទៅឆ្នាំបន្ទាប់ (ឆ្នាំ២០២៣-២០២៥) ។ MTFF ជាមូលដ្ឋានក្នុងការរៀបចំ MTBF ។ ដោយសារ MTFF មិនទាន់ត្រូវបានអនុម័ត, ឯកសារទស្សនទាន MTBF ត្រូវបានរៀបចំផ្អែកលើធាតុចូលពីក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ។ MTBF ត្រូវបានអនុម័តក្នុងឆ្នាំ ២០១៩ និងបានអនុវត្តសាកល្បងក្នុងឆ្នាំ ២០២០ សម្រាប់ការវិភាជថវិកាទៅតាមវិស័យ និងកម្រិតនូវពិតានចំណាយរបស់ក្រសួង ស្ថាប័ននីមួយៗ ។ ផលប៉ះពាល់នៃដំណើររៀបចំ MTBF អាស្រ័យលើគុណភាពនៃសមត្ថភាព និងការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធផ្អែកលើការវិភាគគោលនយោបាយឱ្យមានសមាហរណកម្ម រវាងព័ត៌មានហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ និងពិតានចំណាយវិនិយោគដែលត្រូវរង់ចាំ PIM ។ កង្វះការវិភាគហានីភ័យគោលនយោបាយហិរញ្ញវត្ថុ (Policy Risk) និងយន្តការ, ក្របខណ្ឌ ឬ នីតិវិធីនៃការវិភាគហានិភ័យហិរញ្ញវត្ថុ អាចជាបញ្ហាប្រឈមសម្រាប់ការរៀបចំ MTFF ឱ្យមានប្រសិទ្ធភាព ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៣៤ រួមមាន ÷*

- *ការរៀបចំ MTFF គួរផ្តោតលើវិស័យសំខាន់ៗជាមុនសិន រួមមាន វិស័យអប់រំ, សុខភាព, កសិកម្ម និងការដឹកជញ្ជូន និងគួរមាន Gatekeeper*
- *គួរបង្កើតក្របខណ្ឌយន្តការ/ នីតិវិធី/ ដើម្បីគាំទ្រដល់ការធ្វើរបាយការណ៍ MTFF ស្តីពីហានិភ័យសារពើពន្ធ មានដូចជា ការវាយតម្លៃអំពីសេណារីយ៉ូហានិភ័យដែលអាចកើតមាន, បំណុលយថាភាពជាក់ស្តែង និងហានិភ័យគោលនយោបាយ និងសម្រាប់អនុវត្ត MTBF, BSP, និង PB*
- *វិធានការណ៍អាទិភាពរបស់ BSRS គួរត្រូវបានប្រើប្រាស់ដើម្បីពង្រឹងការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច, ម៉ាក្រូសារពើពន្ធ និងការព្យាករតាមវិស័យ និងអនុវិស័យ ។*

### ៣.៣.៥. គោលបំណង ៣៥ ÷ ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ

លទ្ធផលជាមធ្យមនៃការអនុវត្តគោលបំណង ៣៥ នៅក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយនេះ គឺទទួលបានលទ្ធផលល្អប្រសើរ តាមផែនការសកម្មភាពកែទម្រង់ក្នុងក្របខណ្ឌការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុសាធារណៈធ្វើឡើង ដោយផ្អែកតាមកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) ។ នៅក្នុងដំណាក់កាលបច្ចុប្បន្ន យុទ្ធសាស្ត្រនៃកែទម្រង់ប្រព័ន្ធថវិការដ្ឋបាល

ថ្នាក់ក្រោមជាតិ ២០១៩-២០២៥ រួមទាំងផែនការសកម្មភាពលម្អិតដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ គឺជាផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់នៃការពង្រឹងគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ។ ក្នុងពេលជាមួយគ្នានេះ ការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ត្រូវបានគិតគូរជាយុទ្ធសាស្ត្រនៅក្នុងការរៀបចំចក្ខុវិស័យ[8] និងយុទ្ធសាស្ត្រនៃការងារកែទម្រង់ទាំង ៣ របស់រាជរដ្ឋាភិបាល គឺការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និងការកែទម្រង់រដ្ឋបាលសាធារណៈ ។

ជាមួយគ្នានេះ សមិទ្ធផលដ៏សំខាន់ និងចាត់ទុកថាមានលក្ខណៈជាប្រវត្តិសាស្ត្រនោះ គឺការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការប្រគល់មុខងារ និងធនធានពាក់ព័ន្ធវិស័យជាច្រើនទៅឱ្យរដ្ឋបាលទាំងនោះ និងការផ្ទេរមុខងារសុខាភិបាលនិងធនធាន ឱ្យស្ថិតក្រោមការគ្រប់គ្រងចាត់ចែងរបស់រដ្ឋបាលរាជធានី ខេត្ត ។ លទ្ធផលជាគន្លឹះមួយទៀតពាក់ព័ន្ធទៅនឹងការបង្កើនមូលនិធិឃុំ សង្កាត់ ជាបណ្តើរៗ រៀងរាល់ឆ្នាំ ដើម្បីបង្កលក្ខណៈឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កាន់តែមានលទ្ធភាពអាចចូលរួមដោះស្រាយតម្រូវការជាអាទិភាពនានារបស់មូលដ្ឋាននីមួយៗ ។ តាមរយៈការបង្កើនមូលនិធិនេះ, តាមការប៉ាន់ស្មានរហូតដល់ឆ្នាំ២០២៣, រដ្ឋបាលឃុំ សង្កាត់នីមួយៗនឹងទទួលបានថវិកា ផ្នែកអភិវឌ្ឍន៍មូលដ្ឋាន ជាមធ្យមសម្រាប់ឃុំ សង្កាត់នីមួយៗមានប្រមាណ ដប់ម៉ឺនដុល្លារអាមេរិក ខណៈដែលឆ្នាំ២០១៩ មានត្រឹមតែ ជាងបីម៉ឺនដុល្លារអាមេរិក ។ នៅក្នុងឆ្នាំ ២០២០ រដ្ឋបាលស្រុកចំនួន ៦០ នៃខេត្តចំនួន ០៩ បានអនុវត្តមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ការដាក់ឱ្យអនុវត្តយន្តការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ គឺបង្ហាញពីការលើកកម្ពស់នូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៅថ្នាក់ក្រោមជាតិ ដោយផ្តល់ហិរញ្ញប្បទានបន្ថែមទៅដល់គម្រោងវិនិយោគសាធារណៈ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់ការបំពេញភារកិច្ច និងការគ្រប់គ្រងវិនិយោគសាធារណៈឱ្យកាន់តែប្រសើរ ។ ចាប់ពីឆ្នាំ២០១៧មក ធនធានអនុវត្តយន្តការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើន, គិតត្រឹមឆ្នាំ២០២០ រាជរដ្ឋាភិបាលបានផ្តល់ថវិកាចំនួន ៧,៤ លានដុល្លារអាមេរិក និងធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ហិរញ្ញប្បទានថវិកាចំនួន ២០ លានដុល្លារអាមេរិក សម្រាប់ពង្រីកវិសាលភាពមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅដល់រដ្ឋបាលក្រុង ស្រុក និងខណ្ឌទាំង ១៨៩ ។

[8] ការរៀបចំឯកសារទស្សនាទានសម្រាប់រៀបចំឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ គ្រោងនឹងបញ្ចប់ត្រឹមឆ្នាំ២០២១ និងគ្រោងទៅរៀបចំនិងបញ្ចប់ឯកសារចក្ខុវិស័យនិងយុទ្ធសាស្ត្រ មុនឆ្នាំ២០២៣ ។




ជារួម ការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុក្នុងពេលខាងមុខ នឹងត្រូវដោះស្រាយជារចនាសម្ព័ន្ធផង និងដោយផ្នែកផង រីឯការរៀបចំផែនការសកម្មភាពនិងសូចនាករសមិទ្ធកម្ម គួរត្រូវយកធាតុចូលនិងផ្អែកជាចម្បងលើទស្សនាទាននិងផែនការសកម្មភាពលម្អិតនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩-២០២៥ តែម្តង ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៣៥ រួមមាន ÷*

- *បន្តកែលម្អទាំងរចនាសម្ព័ន្ធផង និងដោយផ្នែកផង ដើម្បីពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ*
- *ការរៀបចំផែនការសកម្មភាពនិងសូចនាករសមិទ្ធកម្ម គួរត្រូវយកធាតុចូលនិងផ្អែកជាចម្បងលើទស្សនាទាននិងផែនការសកម្មភាពលម្អិតនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩-២០២៥ តែម្តង*
- *ការរៀបចំផែនការសកម្មភាពនិងសូចនាករសមិទ្ធកម្ម គួរត្រូវយកធាតុចូលនិងផ្អែកជាចម្បងលើទស្សនាទាននិងផែនការសកម្មភាពលម្អិតនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៩-២០២៥ តែម្តង*

- *រៀបចំយុទ្ធសាស្ត្រនិងការកំណត់ទិសដៅរយៈពេលមធ្យម និងវែង សម្រាប់ការអនុវត្តគោលនយោបាយ វិមជ្ឈការហិរញ្ញវត្ថុនេះ ។*

### ៣.៣.៦. សេចក្តីសន្និដ្ឋានផ្នែកទី ៣

ជារួម លិខិតបទដ្ឋានគតិយុត្ត និងយុទ្ធសាស្ត្រ ជាច្រើនត្រូវបានបង្កើតឡើងដើម្បីពង្រឹងការអនុវត្តសកម្មភាព ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។ ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី ដែលកំពុងត្រួតពិនិត្យ និងរៀបចំ និង អនុក្រឹត្យពាក់ព័ន្ធ គឺជាគតិយុត្តដ៏សំខាន់ក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធី ។ ថវិកាកម្មវិធីត្រូវបានអនុវត្ត ពេញលេញនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលខេត្តមួយចំនួន ប៉ុន្តែយន្តការតាមដានវាយតម្លៃលើការអនុវត្ត នៅមិនទាន់ បានពង្រឹង ។

ជាទិសដៅសម្រាប់ដំណាក់កាលបន្ទាប់, គួរបន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដោយផ្តោត លើគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់គ្រប់អង្គភាពថវិកា ។ ការណែនាំ និង តម្រង់ទិសនៃការរៀបចំ គួរត្រូវបានរំលេចឱ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសលើវិស័យអាទិភាពដែលឆ្លើយតបទៅនឹង កម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល តាមរយៈការពង្រឹងគុណភាពនៃក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ រយៈពេលមធ្យម (MTFF) និងក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ។ ការត្រួតពិនិត្យលើសង្គតិភាពនៃការអនុវត្ត ថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ផ្អែកលើយុទ្ធសាស្ត្រដែលបានដាក់ចេញ ។

*ជារួម សកម្មភាពបន្តក្នុងជំហានបន្ទាប់សម្រាប់ផ្នែកទី ២ រួមមាន ÷*

- *បន្តការរៀបចំបញ្ចប់ MTFF និង MTBF*
- *ពង្រឹងការវាយតម្លៃផែនការយុទ្ធសាស្ត្រថវិកា និងកាត់បន្ថយគម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ*
- *ពង្រឹងយន្តការអនុវត្តតាមដានការអនុវត្តថវិកាកម្មវិធីនៅតាមក្រសួង ស្ថាប័ន ។*

## ៣.៤. ផ្នែកទី ៤ ÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់

ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ត្រូវបានគិតគូររៀបចំនូវមូលដ្ឋានគន្លឹះសំខាន់ៗ នៅក្នុងដំណាក់កាលទី ៣ ដើម្បីឈានឆ្ពោះទៅដំណាក់កាលទី ៤ «គណនេយ្យភាពសមិទ្ធកម្ម» ដែលមានទិសដៅទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម (Performance-Informed Budgeting) ។

នៅក្នុងដំណាក់កាលនៃការបង្កើតមូលដ្ឋានគន្លឹះ ផ្នែកទី ៤ នេះ មានគោលបំណងចំនួន ៤ រួមមាន ÷ (១) ក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម, (២) ក្របខណ្ឌតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម, (៣) ក្របខណ្ឌសវនកម្ម ពេញលេញ (សមិទ្ធកម្ម, ព័ត៌មានវិទ្យា, អនុលោមភាព និងហិរញ្ញវត្ថុ), និង (៤) ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍ សមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ។

### ៣.៤.១. គោលបំណង ៤១ ÷ បង្កើតក្របខណ្ឌថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម

គោលបំណងនេះ សំដៅរៀបចំគោលការណ៍ណែនាំ និងបទដ្ឋានគតិយុត្តច្បាស់លាស់ សម្រាប់អនុវត្តថវិកា សមិទ្ធកម្ម ។ ដើម្បីឈានទៅអនុវត្តថវិកាសមិទ្ធកម្ម ចាំបាច់ត្រូវបង្កើតក្របខណ្ឌថវិកាសមិទ្ធកម្ម និងដើម្បីឱ្យប្រព័ន្ធថវិកា

សមិទ្ធកម្មអាចអនុវត្តបានដោយផ្អែកលើបទដ្ឋានគតិយុត្តច្បាស់លាស់ ពេញលេញ និងគ្រប់ជ្រុងជ្រោយ, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ និងអនុក្រឹត្យលេខ ៨១ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និងអង្គភាពសាធារណៈ និងអនុក្រឹត្យលេខ ៨២ ស្តីពីបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ ចាំបាច់ត្រូវធ្វើវិសោធនកម្ម និងកែសម្រួល ។ ជាការសម្រេចក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនឹងត្រូវរៀបចំថ្មី ។ អគ្គនាយកដ្ឋានថវិកាជាមួយនឹងអគ្គនាយកដ្ឋានរតនាគារជាតិ ជាអង្គភាពដឹកមុខក្នុងការរៀបចំកិច្ចការទាំងអស់នេះ ។

ក្រោយពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ត្រូវបានអនុម័ត, សូចនាករសមិទ្ធកម្មគន្លឹះ មានការប្រែប្រួលចាប់ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២០ ពោលគឺបានលុបចោលសូចនាករសមិទ្ធកម្មគន្លឹះដើម និងបានប្តូរមកវិញនូវសូចនាករសមិទ្ធកម្មគន្លឹះចំនួន ៨ ដូចបង្ហាញនៅក្នុងតារាងខាងក្រោម ជាមួយនឹងវឌ្ឍនភាព ÷

| ល.រ. | សូចនាករសមិទ្ធកម្មគន្លឹះ | ពេលវេលាបញ្ចប់ | គោលដៅ | វឌ្ឍនភាព |
|---|---|---|---|---|
| ១ | គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម | ២០១៨ | សេចក្តីព្រាង | បានប្រកាសដាក់ឱ្យអនុវត្តនៅដើមឆ្នាំ ២០២០ |
| ២ | ទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម | ២០២០ | សាកល្បងអនុវត្ត | បានរៀបចំកម្រិតអគ្គនាយក-ដ្ឋាន |
| ៣ | គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម | ២០២០ | រៀបចំ | បានសិក្សា |
| ៤ | ទម្រង់របាយការណ៍ព័ត៌មានសមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំឆ្នាំ | ២០២០ | រៀបចំ | បានរៀបចំ, កែលម្អ, និងបានផ្ញើទៅក្រសួង ស្ថាប័នសម្រាប់រៀបចំ |
| ៥ | ក្របខណ្ឌទស្សនាទាននៃការតាមដាននិងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម | ២០២០ | រៀបចំ | ក្របខណ្ឌតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម ត្រូវបានរៀបចំជាសេចក្តីព្រាង |
| ៦ | រៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី | ២០២០ | បញ្ជូនទៅគណៈរដ្ឋមន្ត្រី | បានរៀបចំជាសេចក្តីព្រាង (បញ្ចប់ ២ នៃ៩ ជំពូក) |
| ៧ | វិសោធកម្មអនុក្រឹត្យលេខ ៨១ និង អនុក្រឹត្យលេខ | ២០២០ | អនុម័តនិងដាក់ឱ្យអនុវត្ត | បានពិភាក្សាជាមួយជំនាញការបារាំង និងបានបញ្ចប់កម្រិតអគ្គនាយកដ្ឋាន |
| ៨ | ចំណាត់ថ្នាក់សេដ្ឋកិច្ចបំពេញត្រូវបានរៀបចំសម្រាប់ភ្ជាប់ច្បាប់ថវិកាប្រចាំឆ្នាំ | ២០២០ | រៀបចំ | បានរៀបចំកម្រិតអគ្គនាយក-ដ្ឋាន |

សូចនាករចំនួន ៨ ខាងលើ មានតែគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម និងទម្រង់របាយការណ៍ព័ត៌មានសមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ។ រីឯសូចនាករមួយចំនួនកំពុងមានវឌ្ឍនភាព ។ ការពន្យារពេលក្នុងការចាប់ផ្តើមអនុវត្តសម្រាប់សូចនាករមួយចំនួនដោយសារត្រូវរង់ចាំការអនុម័តយុទ្ធសាស្ត្រ

នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ។ សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០២០ សូចនាករដែលគាំទ្រដោយជំនាញការបរទេសអាចនឹងជួបប្រទះនូវបញ្ហាប្រឈម ដោយសារការរឹតត្បិតការធ្វើដំណើរឆ្លងប្រទេស (ការរីករាលដាលជំងឺកូវីដ-១៩) ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៤១ រួមមាន ៖*

- *បញ្ចប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី*
- *បញ្ចប់ការរៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម*
- *បញ្ចប់ការរៀបចំទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម*
- *បញ្ចប់ការរៀបចំក្របខណ្ឌទស្សនាទាននៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម*
- *បញ្ចប់ការរៀបចំចំណាត់ថ្នាក់សេដ្ឋកិច្ចបំពេញត្រូវបានរៀបចំសម្រាប់ភ្ជាប់ច្បាប់ថវិកាប្រចាំឆ្នាំ*
- *បញ្ចប់ការកែសម្រួលអនុក្រឹត្យលេខ ៨១ និងអនុក្រឹត្យលេខ ៨២*

### ៣.៤.២. គោលបំណង ៤២ ៖ រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគណនេយ្យសមិទ្ធកម្ម

គោលបំណង ៤២ សំដៅរៀបចំក្របខណ្ឌគណនេយ្យភាពសមិទ្ធកម្ម ដើម្បីលើកកម្ពស់អភិបាលកិច្ចប្រកបដោយភាពសន្សំសំចៃ ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ចាំបាច់ត្រូវរៀបចំឱ្យមានគោលការណ៍ណែនាំសវនកម្មសមិទ្ធកម្មច្បាស់លាស់ និងមានសវនករដែលមានសមត្ថភាព ដើម្បីធានាការចុះធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព ។ អាជ្ញាធរសវនកម្មជាតិ ជាអង្គភាពស្នូលក្នុងការរៀបចំ និងអនុវត្តកិច្ចការទាំងនេះ ។

ការអនុវត្តសម្រាប់ឆ្នាំ ២០១៦ និង ២០១៧ គឺមិនមានវឌ្ឍនភាពនោះទេ ដោយសារត្រូវរង់ចាំឱ្យមានយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ជាមុនសិន ។ បន្ទាប់ពីយុទ្ធសាស្ត្រនេះត្រូវបានអនុម័ត សូចនាករសមិទ្ធកម្មគន្លឹះមានការប្រែប្រួលដោយប្តូរមកវិញនូវសូចនាករសមិទ្ធកម្មគន្លឹះចំនួន ២ ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ ២០២០ រួមមាន គោលការណ៍ណែនាំស្តីពីការធ្វើសវនកម្ម ប្រតិបត្តិការ (ផ្ទៃក្រៅ) (Performance Audit) ត្រូវបានអនុវត្តនៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៩, និងចំនួនរបាយការណ៍សវនកម្មសមិទ្ធកម្មត្រូវបានដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ ។

ចាប់តាំងពីឆ្នាំ ២០១៨ មក អាជ្ញាធរសវនកម្មជាតិបានរៀបចំរបាយការណ៍សវនកម្មកិច្ចប្រតិបត្តិការ និងបានដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ ដោយក្នុងឆ្នាំ ២០១៨ មាន ៣ របាយការណ៍ និង ២០១៩ មាន ៤ របាយការណ៍ ។ ដោយឡែក, សម្រាប់ចំនួនរបាយការណ៍សវនកម្មសមិទ្ធកម្ម ដែលត្រូវដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ អាចនឹងមិនសម្រេចបានក្នុងឆ្នាំ ២០២០[9] ដោយសារបញ្ហារីករាលដាលនៃជំងឺកូវីដ-១៩ ។ ការរៀបចំគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មប្រតិបត្តិការ (Performance Audit) ដោយអាជ្ញាធរសវនកម្មជាតិ (ផ្ទៃក្រៅ) និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (ផ្ទៃក្នុង) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺអាចនឹងមិនមានសង្គតិភាព ដោយសារក្នុងដំណើរការនៃការរៀបចំអង្គភាពទាំង ២ មិនបានជួបពិភាក្សាគ្នា ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៤២ គឺ៖*

- *រៀបចំ និងដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិនូវរបាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៥ សម្រាប់ឆ្នាំ២០២០ ។*

---

[9] *អាជ្ញាធរសវនកម្មជាតិត្រូវចុះបេសកកម្មធ្វើសវនកម្ម*

### ៣.៤.៣. គោលបំណង ៤៣ ÷ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ

ជាសារវតារ គោលបំណង ៤៣ ត្រូវបានរៀបចំបញ្ចូលរវាងគោលបំណង ៣៥ "រៀបចំប្រព័ន្ធត្រួតពិនិត្យ" និង គោលបំណង ៤៣ "បង្កើតក្របខណ្ឌសវនកម្មលើសមិទ្ធកម្ម" ប្រែឈ្មោះទៅជា "ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ" ចាប់ពីឆ្នាំ ២០១៨ រហូតដល់បច្ចុប្បន្ន ។ គោលបំណងនេះ សំដៅធានាបាននូវប្រសិទ្ធភាពនៃមុខងារ វិសាលភាព រចនាសម្ព័ន្ធ ក្របខណ្ឌ និងយន្តការ សវនកម្មផ្ទៃក្នុង និងអធិការកិច្ចហិរញ្ញវត្ថុ ដើម្បីឈានទៅអនុវត្តថវិកាព័ត៌មាន សមិទ្ធកម្ម ក្នុងគោលបំណងបង្កើតគណនេយ្យភាពលើសមិទ្ធកម្មក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ។

សូចនាករចម្បងនៃគោលបំណងនេះ រួមមាន ÷ ការត្រួតពិនិត្យលើយន្តការ និងមុខងារ នៃសវនកម្មផ្ទៃក្នុង និង អធិការកិច្ចនៅតាមក្រសួង ស្ថាប័ន, ការបង្កើតគោលការណ៍ណែនាំ និងក្របខណ្ឌជុំវិញការអនុវត្តសវនកម្មសមិទ្ធកម្ម និង ប្រព័ន្ធព័ត៌មានវិទ្យា, ការពង្រឹងលើយន្តការនៃការរៀបចំផែនការអនុវត្ត និងការតាមដានអនុសាសន៍នៃមុខងារសវនកម្ម ផ្ទៃក្នុង និងអធិការកិច្ច, ការបង្កើតក្របខណ្ឌអធិការកិច្ចហិរញ្ញវត្ថុ ។ ក្នុងនោះ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង អគារធិការដ្ឋាននៃ កសហវ ជាអង្គភាពទទួលបន្ទុករៀបចំក្របខណ្ឌ គោលការណ៍ និងយន្តការ ព្រមទាំងចូលរួមអនុវត្ត ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័ន គឺជាអង្គភាពអនុវត្តនូវគោលការណ៍ និងយន្តការទាំងនេះ ។

ក្នុងដំណាក់កាលទី ៣ វឌ្ឍនភាពស្នូលដែលសម្រេចបានរួមមាន ÷ គោលការណ៍ណែនាំសវនកម្មលើប្រព័ន្ធ ព័ត៌មានវិទ្យា, គោលការណ៍ណែនាំស្តីពីសវនកម្មសមិទ្ធកម្ម, និងអនុក្រឹត្យស្តីពី ក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្ម ផ្ទៃក្នុង និងអធិការកិច្ច។

គួរំលេចថា អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពី ក្របខ័ណ្ឌមុខងារ ភារកិច្ច របស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច គឺជាជំហានដំបូងនៃការធ្វើសុខុដុមនីយកម្មមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៃដែនសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការ និងក្រសួងមុខងារ សាធារណៈ ដែលជាតួអង្គអធិការកិច្ចនៃរាជរដ្ឋាភិបាលលើមុខងារនីមួយៗ ។ ដោយឡែក កម្រិតក្រសួង ស្ថាប័ន អនុក្រឹត្យ បានចង្អុលទៅឱ្យប្រធានស្ថាប័នរៀបចំបែកចែកភារកិច្ចរៀងៗខ្លួន ខណៈដែលមុខងារអធិការកិច្ចនៅតាមក្រសួង ស្ថាប័ន ភាគច្រើនមានទាំងអធិការកិច្ចតាមវិស័យ និងអធិការកិច្ចការហិរញ្ញវត្ថុ ។ ដូច្នេះ ដើម្បីធានានូវសុខុដុមនីយកម្ម និង ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង នៅតាមក្រសួង ស្ថាប័ន លើមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចទស្សនាទាននៃ គំរូក្នុងការរៀបចំស្ថាប័ន និងការបែងចែកមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច គួរត្រូវបានកំណត់ដោយលិខិតបទដ្ឋាន គតិយុត្តផងដែរ។

ទោះបីជាយ៉ាងនេះក្តី, បញ្ហាប្រឈមដែលកំពុងជួបប្រទះ រួមមាន ÷ (១) ការត្រួតគ្នានៃមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៅតាមក្រសួង ស្ថាប័ន ដោយសារកង្វះទស្សនាទានកំណត់ឱ្យដាច់ស្រេចនៃសមត្ថកិច្ចការងារ, (២) សមត្ថភាពនៃការអនុវត្តមុខងារសវនកម្មផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន, និង (៣) កង្វះយន្តការជាក់លាក់ក្នុងការតាមដាន អនុសាសន៍សវនកម្ម និងអធិការកិច្ច ។

ជារួម វឌ្ឍនភាពនៃការអនុវត្តការងារក្នុងគោលបំណង ៤៣ សម្រេចបានមួយចំនួន និងមួយចំនួនទៀតបន្ត អនុវត្តទៀត ។ នៅក្នុងបរិបទកម្ពុជា មុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ស្ថិតនៅក្នុងប្រព័ន្ធត្រួតពិនិត្យតែមួយ ដូចនេះ

ក្របខណ្ឌគំរូនៃការបែងចែកតួនាទីភារកិច្ចនិងការកំណត់រចនាសម្ព័ន្ធស្ថាប័នឱ្យបានច្បាស់លាស់ គឺជាកត្តាកំណត់នូវមូលដ្ឋានប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៤៣ រួមមាន ÷*

- *រៀបចំក្របខណ្ឌសុខដុមនីយកម្ម មុខងារ សវនកម្មផ្ទៃក្នុង និងអធិការកិច្ច*
- *រៀបចំក្របខណ្ឌអធិការកិច្ចហិរញ្ញវត្ថុ ។*

### ៣.៤.៤. គោលបំណង ៤៤ ÷ រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ន នីតិប្បញ្ញត្តិ និង អាជ្ញាធរ សវនកម្មជាតិ)

គោលបំណង ៤៤ ផ្តោតការរៀបចំឱ្យមានយន្តការរួមនៃការគាំទ្រដល់ការកសាងសមត្ថភាពសម្រាប់គ្រប់ភាគីពាក់ព័ន្ធ (រួមទាំងស្ថាប័ននីតិប្បញ្ញត្តិ) ដើម្បីធានានូវសង្គតិភាពនៃធនធានសមត្ថភាព និងចំណាត់ការនៃការងារកែទម្រង់ដែលបន្តនិងកំពុងអនុវត្ត ។ សូចនាករសំខាន់ៗនៃគោលបំណងនេះ រួមមាន ÷ ការអនុវត្តការរៀបចំ និងអនុវត្តប្រកបដោយប្រសិទ្ធនូវផែនការយុទ្ធសាស្ត្រកសាងសមត្ថភាព ដំណាក់កាលទី ៣, ការរៀបចំផែនការយុទ្ធសាស្ត្រកសាងសមត្ថភាព ដំណាក់កាលទី ៤ ។ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃ កសហវ គឺជាអង្គភាពស្នូលទាំងការសម្របសម្រួលរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រកសាងសមត្ថភាពនេះ ។ ជាក់ស្តែង, ផែនការយុទ្ធសាស្ត្រកសាងសមត្ថភាព ដំណាក់កាលទី ៣ ត្រូវបានរៀបចំ និងអនុវត្តដោយមានវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាតួអង្គស្នូលក្នុងការសម្របសម្រួលរៀបចំគ្រប់ដំណាក់កាលនៃការបណ្តុះបណ្តាល ។ សិក្ខាសាលា វគ្គបណ្តុះបណ្តាលខ្លី ត្រូវបានអនុវត្តយ៉ាងច្រើនក្នុងពេលកន្លងមក ខណៈដែលវគ្គបណ្តុះបណ្តាលមធ្យម និងកម្រិតជំនាញជាក់លាក់ នៅពុំទាន់មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅឡើយ ។ មន្ត្រីរាជការចំនួន ១៥,០៩២ នាក់ និងវគ្គបណ្តុះបណ្តាលចំនួន ២១០វគ្គ ត្រូវបានអនុវត្តចាប់ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ។ បន្ថែមពីលើនេះ ផែនការយុទ្ធសាស្ត្រកសាងសមត្ថភាព ដំណាក់កាលទី ៤ បាននិងកំពុងរៀបចំ និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២០ នេះ ។

ទោះបីជាយ៉ាងនេះក្តី, ក្នុងការអនុវត្តកន្លងមក ក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនផងដែរ ដូចជា ÷ កង្វះយន្តការតាមដាន និងវាយតម្លៃលើដំណាក់កាលនីមួយៗនៃការប្រព្រឹត្តទៅនៃវគ្គបណ្តុះបណ្តាល ។ កង្វះយន្តការនៃការប្រើប្រាស់ធនធានបច្ចេកទេសនៅតាមអគ្គនាយកដ្ឋានជំនាញនៅក្រោមឱវាទ កសហវ ។ ការកសាងសមត្ថភាពសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ មិនបានអនុវត្តតាមផែនការ ។ ការបន្ស៊ីទៅនឹងតម្រូវការការកសាងសមត្ថភាពគាំទ្រដល់យុទ្ធសាស្ត្រកែទម្រង់ថ្មីៗ របស់រាជរដ្ឋាភិបាល មិនទាន់បានរៀបចំ ។

ជារួម គោលបំណងនេះ សម្រេចបានវឌ្ឍនភាពល្អប្រសើរធៀបនឹងផែនការដែលបានដាក់ចេញ ក៏ប៉ុន្តែផែនការយុទ្ធសាស្ត្រកសាងសមត្ថភាព ដំណាក់កាលទី ៤ គួរត្រូវរៀបចំឱ្យបានជាក់លាក់ ដោយផ្អែកលើយុទ្ធសាស្ត្រកែទម្រង់ថ្មីៗរបស់រាជរដ្ឋាភិបាល និងពិចារណាលើអភិក្រមទាំង ២ប្រភេទគឺ ÷ ផ្អែកលើគោលដៅ (Objective Oriented) និងផ្អែកលើតម្រូវការ (Demand Oriented) ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងប្រសិទ្ធភាពនៃការកសាងសមត្ថភាព ។

*សកម្មភាពបន្តអនុវត្តក្នុងជំហានបន្ទាប់សម្រាប់គោលបំណង ៤៤ គឺ ÷*

- *រៀបចំក្របខណ្ឌកសាងសមត្ថភាពសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ ក្នុងបរិបទថវិកាព័ត៌មានសមិទ្ធកម្ម នៅក្នុងផែនការយុទ្ធសាស្ត្រកសាងសមត្ថភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ។*

### ៣.៤.៥. សេចក្តីសន្និដ្ឋានផ្នែកទី ៤

ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ត្រូវបានគិតគូររៀបចំនូវមូលដ្ឋានគន្លឹះសំខាន់ៗ នៅក្នុងដំណាក់កាលទី ៣ ដើម្បីឈានឆ្ពោះទៅដំណាក់កាលទី ៤«គណនេយ្យភាពសមិទ្ធកម្ម» ដែលមានទិសដៅទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម (Performance-Informed Budgeting) ។ នៅក្នុងដំណាក់កាលនៃការបង្កើតមូលដ្ឋានគន្លឹះនេះ, ផ្នែកទី ៤ បានផ្តោតជាសំខាន់លើការរៀបចំក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម, ក្របខណ្ឌតាមដាន និង ត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម, និងក្របខណ្ឌសវនកម្មពេញលេញ (សមិទ្ធកម្ម, ព័ត៌មានវិទ្យា, អនុលោមភាព និងហិរញ្ញវត្ថុ) ព្រមទាំងការរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រកសាងសមត្ថភាព ដើម្បីត្រៀមខ្លួនគាំទ្រ និងជំរុញការអនុវត្តគណនេយ្យភាពសមិទ្ធកម្ម ។

វឌ្ឍនភាពជារួមសម្រាប់ផ្នែកទី ៤ មានភាពមិនទាន់ច្បាស់លាស់នៅរយៈពេលពីរឆ្នាំដំបូង ក៏ប៉ុន្តែវឌ្ឍនភាពបានបង្ហាញយ៉ាងច្បាស់បន្ទាប់ពី «យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥» ត្រូវបានរៀបចំ និងជ្រើសរើសយកប្រព័ន្ធ «ថវិកាព័ត៌មានសមិទ្ធកម្ម» ជាទិសដៅជាក់លាក់នៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ។ រយៈពេលជាងពីរឆ្នាំចុងក្រោយនេះ, ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ផ្នែកទី ៤ ត្រូវបានរៀបចំ និងកំណត់ការទទួលខុសត្រូវច្បាស់លាស់ និងមានសង្គតិភាពជាមួយនឹងផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ។ វឌ្ឍនភាពដែលសម្រេចបាន រួមមាន ÷ ការរៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មសមិទ្ធកម្ម (ផ្ទៃក្រៅ) និងសម្រាប់សវនកម្មផ្ទៃក្នុង, គោលការណ៍ណែនាំសវនកម្មលើប្រព័ន្ធព័ត៌មានវិទ្យា និងគោលការណ៍ណែនាំស្តីពីសវនកម្មសមិទ្ធកម្ម ។ រីឯការងារពាក់ព័ន្ធការរៀបចំក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម ត្រូវបានរៀបចំជាគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម ។ ទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម, គោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម និងក្របខណ្ឌទស្សនាទាននៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម ត្រូវបានរៀបចំជាសេចក្តីព្រាង ។ បន្ថែមលើនេះ, ផែនការយុទ្ធសាស្ត្រកសាងសមត្ថភាព ក៏បានរៀបចំ និងដាក់ឱ្យអនុវត្តសម្រាប់ដំណាក់កាលទី ៣ ដើម្បីរៀបចំធនធានមនុស្ស និងស្ថាប័ន ក្នុងការគាំទ្រដល់ការប្រែប្រួលនូវការអនុវត្តការងារពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

សម្រាប់ផ្នែកទី ៤ មានវឌ្ឍនភាពយឺតជាងផែនការដែលបានគ្រោងទុក ពីព្រោះតែធនធានមួយចំនួនត្រូវបានប្រើប្រាស់ក្នុងការរៀបចំសេចក្តីព្រាង ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី និងអនុក្រឹត្យលេខ ៨១ និង ៨២ ដែលនឹងត្រូវបើកផ្លូវក្នុងការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មនាពេលខាងមុខ ។ ការរៀបចំក្របខណ្ឌសម្រាប់អនុវត្ត និងត្រួតពិនិត្យថវិកាព័ត៌មានសមិទ្ធកម្ម នៅពុំទាន់មានវឌ្ឍនភាពតាមផែនការដែលបានដាក់ចេញ ប៉ុន្តែកំពុងត្រូវបានជំរុញ ។ ផែនការកសាងសមត្ថភាពដែលបានរៀបចំ និងអនុវត្តកន្លងមក នៅពុំទាន់មានភាពគ្រប់ជ្រុងជ្រោយ និងលម្អិតតាមតម្រូវការជាក់ស្តែងរបស់អ្នកពាក់ព័ន្ធនៅឡើយ ។

*ជារួម សកម្មភាពបន្តក្នុងដំហានបន្ទាប់សម្រាប់ផ្នែកទី ៤ រួមមាន ÷*

- *បញ្ចប់ការរៀបចំសេចក្តីព្រាង ច្បាប់ប្រព័ន្ធស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការកែសម្រួលអនុក្រឹត្យលេខ ៨១ និង ៨២*
- *រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម*
- *រៀបចំឱ្យមានការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម*
- *យន្តការនៃការធ្វើសវនកម្ម និងអធិការកិច្ចមួយច្បាស់លាស់*
- *រៀបចំផែនការយុទ្ធសាស្ត្រកសាងសមត្ថភាពមួយដែលមានភាពឆ្លើយតបពេញលេញ ។*

### ៣.៥. ផ្នែកទី ៥ ÷ ការគាំទ្រដល់ការអនុវត្តប្រកបដោយចីរភាព

តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤, កំណែទម្រង់អភិបាលកិច្ច នៅបន្តជាធាតុស្នូលដ៏សំខាន់ និងជាទិសដៅមុតស្រួចរបស់រាជរដ្ឋាភិបាល ។ ក្នុងអភិក្រមនៃការអនុវត្តការងារកែទម្រង់, ភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង សមត្ថភាពបច្ចេកទេស ភាពជាម្ចាស់ ការទទួលខុសត្រូវ ការរៀបចំនិងគ្រប់គ្រងយន្តការស្ថាប័នរបស់គ្រប់ស្ថាប័នពាក់ព័ន្ធ និងយន្តការលើកទឹកចិត្ត គឺជាកត្តាកំណត់ភាពជោគជ័យ និងចីរភាពនៃកំណែទម្រង់របស់រាជរដ្ឋាភិបាលទាំងមូល ។ ក្នុងដំណាក់កាលទី ៣ ផ្នែកទី៥ កំណត់នូវសូចនាករសមិទ្ធកម្មគន្លឹះ ដូចជា ÷

- ភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រង, ឆន្ទៈ, ភាពជាម្ចាស់ និងការទទួលខុសត្រូវ សមស្របនឹងកម្មវិធីកែទម្រង់
- ការបណ្តុះបណ្តាល សមស្រប និងប្រកបដោយស័ក្តិសិទ្ធិភាព និង ប្រសិទ្ធភាព
- ការផ្តល់ការលើកទឹកចិត្ត សមស្រប និងប្រកបដោយផលិតភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព
- គ្រប់ក្រសួង ស្ថាប័ន មានសមត្ថភាពសមស្របសម្រាប់ចូលរួមក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព
- យន្តការ នីតិវិធី នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមក្រសួង ស្ថាប័នត្រូវបានអនុវត្ត ។

ជាក់ស្តែង ការកំណត់នូវសូចនាករគន្លឹះ ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ផ្នែកនេះ គឺជាបញ្ហាប្រឈមដោយសារធាតុនៃសូចនាករសមិទ្ធគន្លឹះ គឺជាមូលដ្ឋានគាំទ្រដល់ការអនុវត្តដែលពុំទាន់អាចវាស់វែងបាន ។ ដូច្នេះ ការត្រួតពិនិត្យលើវឌ្ឍនភាពនៃផ្នែកទី ៥ នឹងផ្តោតលើវឌ្ឍនភាពនៃធាតុជាមូលដ្ឋានសម្រាប់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ៣ រួមមាន ÷ (១) ការគ្រប់គ្រងយន្តការការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) យន្តការលើកទឹកចិត្ត, និង (៣) យន្តការអន្តរការដ្ឋានកែទម្រង់ ។

<u>**ការគ្រប់គ្រងយន្តការការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**</u> ÷ តាមរយៈសារាចរលេខ ០៩ សរ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំការអនុវត្ត ការត្រួតពិនិត្យតាមដាន និង ការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ក.ហ.ស.) ត្រូវបានបង្កើតឡើង នៅតាមក្រសួង ស្ថាប័ន និងអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការរៀបចំផែនការសកម្មភាព និងការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ របស់ ក.ហ.ស អនុវត្តក្រោមការសម្របសម្រួលរបស់ អ.គ.ហ ដែលមានផែនការសកម្មភាពប្រចាំឆ្នាំ MAP និង GDAP ស្របតាមផែនការសកម្មភាពរួមប្រចាំឆ្នាំ CAP ។ ជារៀងរាល់ត្រីមាសនិងប្រចាំឆ្នាំ, ក.ហ.ស នៃ កសហវ និងក្រសួង ស្ថាប័ន ត្រូវផ្ញើនូវរបាយការណ៍វឌ្ឍនភាព និងសមិទ្ធកម្ម មក អ.គ.ហ. ដើម្បីត្រួតពិនិត្យ និងរៀបចំរបាយការណ៍វាយតម្លៃ ដោយប្រើប្រាស់វិធីសាស្ត្រទម្ងន់មធ្យម (Weighting Average) ។ ទោះបីជាយ៉ាងនេះក្តី ការរៀបចំរបាយការណ៍វឌ្ឍនភាពនៅយឺតជាងពេលវេលាកំណត់ ប៉ុន្តែត្រូវបានធ្វើជាទៀងទាត់ ។

កិច្ចប្រជុំត្រួតពិនិត្យ តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទ ក.ស.ហ.វ. និងក្រសួង ស្ថាប័នលើសូចនាករសមិទ្ធកម្មគន្លឹះ ត្រូវបានអនុវត្តប្រចាំត្រីមាស និងប្រចាំឆ្នាំ ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយភាគីពាក់ព័ន្ធ ៣ កម្រិត ÷ (១) កម្រិតគណៈកម្មការការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃ ក.ស.ហ.វ, (២) កម្រិតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលមានវត្តមានពីគ្រប់ក្រសួង ស្ថាប័ន), និង (៣) កម្រិតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រុមការងារបច្ចេកទេស និងដៃគូអភិវឌ្ឍ ។

បញ្ហាប្រឈមជុំវិញយន្តការបច្ចុប្បន្នដែលគួរដោះស្រាយ រួមមាន ÷ (១) ការសម្របសម្រួលឱ្យមានផែនការសកម្មភាពប្រចាំឆ្នាំឱ្យទាន់ពេលវេលា, (២) ភាពឆ្លើយតបគ្នារវាងសូចនាករសមិទ្ធកម្មគន្លឹះនៃផែនការសកម្មភាពប្រចាំឆ្នាំរបស់ ក.ហ.ស. និងសូចនាករសមិទ្ធកម្មគន្លឹះនៃផែនការសកម្មភាពរួមប្រចាំឆ្នាំ, និង (៣) វឌ្ឍនភាព និងវិធីសាស្ត្រវាយតម្លៃគួរកែសម្រួល ដើម្បីឱ្យមានភាពប្រាកដនិយម ។

ដើម្បីឆ្លើយតប អ.គ.ហ. បាននិងកំពុងរៀបចំនូវគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្មដោយផ្អែកលើលទ្ធផល ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព នៃការរៀបចំលើផែនការសកម្មភាព និងលទ្ធផលក្នុងឆ្នាំ និងការវាយតម្លៃការអនុវត្តប្រចាំ នៃអគ្គនាយកដ្ឋាន កសហវ និងក្រសួង ស្ថាប័ន ដើម្បីជាមូលដ្ឋានគ្រប់ជ្រុងជ្រោយក្នុងការឆ្លុះបញ្ចាំងនឹងផែនការសកម្មភាពរួម ព្រមទាំងការកសាងប្រព័ន្ធជាក់ស្តែង ។

**<u>យន្តការនៃការលើកទឹកចិត្តសម្រាប់ការងារកែទម្រង់</u>** ÷ យោងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ១១៩ សសរ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៧ លើការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័នប្រមូលចំណូលសម្រាប់ផ្តល់ការលើកទឹកចិត្តលើការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានបង្កើតឡើងដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អ.គ.ហ. ក្នុងការប្រើប្រាស់សម្រាប់គាំទ្រកម្មវិធី ។

ការអនុវត្តមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកំណត់បែងចែកជា ២ ដំណាក់កាល ដោយផ្អែកលើអត្រាកាត់ចំណូលមិនមែនសារពើពន្ធ ១ក្នុងដំណាក់កាលទី % ១ និង ៤ក្នុងដំណាក់កាលអនុវត្តមូលនិធិ % គ្រប់ជ្រុងជ្រោយ ។ បច្ចុប្បន្ននេះ ការអនុវត្តមូលនិធិ កំពុងអនុវត្តក្នុងដំណាក់កាលទី ១ ដែលមានអត្រា ១នៃចំណូល % មិនមែនសារពើពន្ធ ។ យោងតាមប្រកាសលេខ ៣៥១ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៨ ស្តីពីវិធាន និងនីតិវិធីការផ្តល់ការលើកទឹកចិត្តជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន, ក.ហ.ស.

នៅតាមក្រសួង ស្ថាប័ន ត្រូវកំណត់សមាសភាពនៃក្រុមការងារដែលត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត រីឯចំនួនសមាសភាព ត្រូវមានសង្គតិភាពនឹងផែនការសកម្មភាពប្រចាំឆ្នាំ និងសូចនាករសមិទ្ធកម្មគន្លឹះ ដែលសម្របសម្រួលដោយ អ.គ.ហ. ដើម្បីគោរពជូន គ.ហ.ស. ពិនិត្យនិងសម្រេច ។ ប្រាក់ឧបត្ថម្ភលើកទឹកចិត្តនេះ ត្រូវបើកផ្តល់ប្រចាំខែដោយសមាមាត្រជាមួយនឹងវឌ្ឍនភាពប្រចាំត្រីមាសនៃផែនការសកម្មភាពប្រចាំឆ្នាំ ។ យ៉ាងណាមិញ ចំណុចខ្សោយនៃការងារនេះ គឺក្រសួង ស្ថាប័ន ទទួលបានការលើកទឹកចិត្ត ទោះបីជាសកម្មភាពដែលបានគ្រោងមួយចំនួន មិនឆ្លុះបញ្ចាំងនឹងកិច្ចខិតខំប្រឹងប្រែងក៏ដោយ ។

បញ្ហាប្រឈមជុំវិញយន្តការនេះ ដែលគួរដោះស្រាយ រួមមាន ÷ (១) គុណាធិបតេយ្យនៃការកំណត់សមាសភាព ក.ហ.ស. នៅតាមក្រសួង ស្ថាប័ន ដើម្បីទទួលបានប្រាក់ឧបត្ថម្ភ ដែលសំដៅទៅលើវឌ្ឍនភាពនៃការងារកែទម្រង់នៅក្នុងស្ថាប័ន, និង (២)សមាគតិភាពនៃការបែងចែកសមាសភាពទទួលប្រាក់ឧបត្ថម្ភ ធៀបនឹងការកំណត់ផែនការសកម្មភាព និងសូចនាករសមិទ្ធកម្មគន្លឹះរវាងក្រសួង ស្ថាប័ន ។

ដើម្បីឆ្លើយតប អ.គ.ហ. នឹងរៀបចំវាយតម្លៃលើការអនុវត្តមូលនិធិកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងឆ្នាំ២០២១ លើទិដ្ឋភាពហិរញ្ញវត្ថុ ការដឹកនាំគ្រប់គ្រង និងការចូលរួមលើការងារកែទម្រង់ មុននឹងការសម្រេចឈានទៅដំណាក់កាលគ្រប់ជ្រុងជ្រោយ។

<u>**យន្តការអន្តរការដ្ឋានកែទម្រង់ផ្សេងទៀត**</u> ÷ កម្មវិធីកែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ គឺជាកំណែទម្រង់ស្នូលអភិបាលកិច្ចនៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានបច្ច័យលើគ្រប់ក្រសួង ស្ថាប័ន និងទាមទារឱ្យមានឆ្លើយតបគ្នា បំពេញគ្នា និងគួរស្ថិតក្នុងល្បឿនប្រហាក់ប្រហែលគ្នា ។ យន្តការអន្តរការដ្ឋានកម្មវិធីកែទម្រង់ ៣ របស់រាជរដ្ឋាភិបាលត្រូវបានបង្កើតឡើងចាប់ពីឆ្នាំ ២០១៦ មក ដោយអគ្គ/លេខាធិការដ្ឋានទាំងបីកំណត់នូវយន្តការនៃការដឹកនាំកិច្ចប្រជុំផ្លាស់ប្តូរ វេន ១ដង/ត្រីមាសជាបន្តបន្ទាប់ ។ កិច្ចប្រជុំផ្តោតការពិភាក្សាលើបញ្ហានានា និងវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួមប្រចាំឆ្នាំនៃយន្តការអន្តរការដ្ឋាននេះ ។ មកដល់ឆ្នាំ ២០១៧ កម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ត្រូវបានបញ្ចូលក្នុងយន្តការកម្មវិធីកែទម្រង់ ៣ តាមរយៈការឯកភាពរវាង ប្រធានគណៈកម្មាធិការនៃកម្មវិធីកែទម្រង់ទាំង ៤ ។

យន្តការនៃការដឹកនាំកិច្ចប្រជុំផ្លាស់វេន ត្រូវបានអនុវត្តជាទៀងទាត់ ជាមួយនឹងផែនការសកម្មភាពប្រចាំឆ្នាំ ។ ដើម្បីពង្រឹងលើយន្តការអន្តរការដ្ឋាននេះ, ការសម្របសម្រួលកម្រិតបច្ចេកទេស ត្រូវបានពង្រឹងតាមរយៈការបង្កើតក្រុមមន្ត្រីបង្គោលបច្ចេកទេសនៅតាមអគ្គ/លេខាធិការដ្ឋានកែទម្រង់នីមួយៗ ។

យន្តការស្ថាប័នដឹកនាំការងារកែទម្រង់នីមួយៗ បានកំណត់នូវបញ្ហាប្រឈមដែលមិនអាចចៀសរួច គឺរបៀបនៃការដឹកនាំនិងគ្រប់គ្រងការងារកែទម្រង់ទៅតាមការដ្ឋាននីមួយៗ ដែលធ្វើឱ្យល្បឿននៃកំណែទម្រង់នីមួយៗ ស្ថិតក្នុងភាពដោយឡែកៗពីគ្នា និងជួនកាលពុំបានបំពេញឱ្យគ្នាទៅវិញទៅមក ដែលបង្កជាកិច្ចប្រឈមត្រូវដោះស្រាយ ។

ដើម្បីឆ្លើយតបនឹងការរៀបចំឯកសារយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ ៣ បូក ១ រយៈពេល ១០ឆ្នាំ របស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានទទួលការឯកភាពពីប្រធានគណៈកម្មាធិការនីមួយៗ ដើម្បីកំណត់ទិសដៅរួមនៃការកែទម្រង់អភិបាលកិច្ច ។ អ.គ.ហ. ត្រូវបានចាត់តាំងជាតួអង្គស្នូល ដើម្បីសម្របសម្រួលរៀបចំឯកសារនេះ ។ ជាទិសដៅ អ.គ.ហ នឹងបញ្ចប់ឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល ក្នុងឆ្នាំ ២០២១ ។

### ៣.៥.១. សេចក្តីសន្និដ្ឋានផ្នែកទី ៥

ជារួម ការកសាងសមត្ថភាព, យន្តការគ្រប់គ្រងតាមដានការអនុវត្តកម្មវិធីកែទម្រង់ និងយន្តការលើទឹកចិត្ត ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត តាមរយៈ ÷ (១) ការអនុវត្តផែនការយុទ្ធសាស្រ្តកសាងសមត្ថភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣, (២) ការដាក់ឱ្យអនុវត្តសារាចរារាជរដ្ឋាភិបាលកម្ពុជាលេខ ០៩ សរ ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និង (៣) ការដាក់ឱ្យអនុវត្តមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ជាមួយគ្នានេះ ដើម្បីធានាឱ្យបាននូវចីរភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យន្តការសម្របសម្រួលអន្តរការដ្ឋានកម្មវិធីកែទម្រង់ (កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និងកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ) ត្រូវបានបង្កើត និងអនុវត្តចាប់តាំងពីឆ្នាំ ២០១៦ ក្នុងគោលបំណងបង្កើតភាពប្រទាក់ក្រឡា និងបំពេញគ្នាទៅវិញទៅមករវាងកម្មវិធីនីមួយៗ ។

*ជារួម សកម្មភាពបន្តក្នុងជំហានបន្ទាប់សម្រាប់ផ្នែកទី ៥ រួមមាន ÷*

- *រៀបចំផែនការយុទ្ធសាស្រ្តកសាងសមត្ថភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤*
- *រៀបចំនិងអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្មដោយផ្អែកលើលទ្ធផល*
- *វាយតម្លៃការអនុវត្តមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី១ និងការឈានទៅកាន់ដំណាក់កាលគ្រប់ជ្រុងជ្រោយ*
- *រៀបចំឯកសារចក្ខុវិស័យ និងយុទ្ធសាស្រ្តកម្មវិធីកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាលកម្ពុជា ។*

### ៣.៦. ចំណុចកង្វះចន្លោះនៃក្របខណ្ឌផែនការសកម្មភាពរួម-ដំណាក់កាលទី ៣

ផ្អែកតាមការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣, ការរៀបចំនូវសកម្មភាពការងារកែទម្រង់នៅក្នុងដំណាក់កាលនេះ នៅមានចំណុចខ្វះចន្លោះមួយចំនួន ដូចខាងក្រោម ÷

- ពុំទាន់ផ្តោតលើកម្រិតលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយឱ្យបានច្បាស់លាស់ ដែលធ្វើឱ្យការវាយតម្លៃបញ្ចប់ដំណាក់កាលនីមួយៗ មិនមានភាពច្បាស់លាស់ ។
- ពុំផ្តោតកិច្ចការអាទិភាពច្បាស់លាស់ ហើយផ្តោតលើសកម្មភាពមានក្នុង GDAP និង MAP ។
- មានការយល់ច្រលំអំពី KPIs និងគោលដៅ ព្រមទាំងការកំណត់គោលបំណងនិងចង្កោមសកម្មភាពពុំទាន់មានភាពច្បាស់លាស់ ។
- តួនាទីរបស់ក្រសួង ស្ថាប័ន ពុំទាន់ត្រូវបានកំណត់ឱ្យច្បាស់លាស់ ពោលគឺពុំទាន់បានគិតគូរមុខងាររបស់ក្រសួង ស្ថាប័ន ដោយផ្សារភ្ជាប់នឹងការកែទម្រង់បច្ចុប្បន្ន (ការត្រួតពិនិត្យលើបៀវត្ស, ការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ) ។ បន្ថែមពីលើនេះ ការរៀបចំ MAP ពុំទាន់គិតគូរតាមវិស័យនៅឡើយ ដែលក្រសួង ស្ថាប័នគួរតម្រូវឱ្យធ្វើការរៀបចំតាមវិស័យ និងអាទិភាព ដូចជា ÷ វិស័យសេដ្ឋកិច្ច ផ្តោតលើ (១) ចំណូល, (២)

ការគ្រប់គ្រងវិនិយោគសាធារណៈ, (៣) ប្រព័ន្ធ FMIS និង (៤) ថវិកាកម្មវិធី (អង្គភាពថវិកា និងការត្រួតពិនិត្យ និងវាយតម្លៃ) ។ រីឯ វិស័យរដ្ឋបាលអនុវត្ត FMIS និងថវិកាកម្មវិធី ផ្ដោតលើ អង្គភាពថវិកា និងការត្រួតពិនិត្យ និងវាយតម្លៃ ។

- ការលើកទឹកចិត្តលើកិច្ចការ PFM មិនទាន់ផ្សារភ្ជាប់ទៅនឹងសមិទ្ធកម្មនៅឡើយ ។
- វិសាលភាពក្របខណ្ឌ CAP3 មិនទាន់បញ្ចូលការតាមដានការអនុវត្តសហគ្រាសសាធារណៈ (ស្ថិតក្នុងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) និងគ្រឹះស្ថានសាធារណៈរដ្ឋបាល (នាយកដ្ឋានហិរញ្ញកិច្ចនៃអគ្គនាយកដ្ឋានថវិកា) និងតួនាទីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្ត ។
- រចនាសម្ព័ន្ធនៃផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ នៅមានភាពត្រួតស៊ីគ្នា មិនទាន់រៀបចំ និងបែងចែកបានច្បាស់លាស់ទៅតាមខឿននីមួយៗ ។
- កម្មវិធីកែទម្រង់ត្រូវបានរៀបចំតាម "អភិក្រមជាខឿន" ដែលពិបាកនឹងកំណត់ថាដំណាក់កាលនីមួយៗត្រូវបញ្ចប់នៅពេលណា ដោយសារគ្រប់ដំណាក់កាលទាំងអស់សុទ្ធតែមានសកម្មភាពខឿននីមួយៗ ។

## ៤. ការពិនិត្យមើលលទ្ធផលសង្ខេប PEFA

ការវាយតម្លៃ PEFA ឆ្នាំ២០២០ ត្រូវបានបញ្ចូលការតាមដានសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងការវាយតម្លៃ PEFA ឆ្នាំ២០១៥ និងកំណត់វឌ្ឍនភាពនៃការអនុវត្តដោយប្រើប្រាស់ក្របខណ្ឌវាយតម្លៃ PEFA ឆ្នាំ២០១១ ដែលមានស្រាប់ ដើម្បីអាចធ្វើការប្រៀបធៀបពីវឌ្ឍនភាពពិន្ទុរវាងឆ្នាំ ២០១៥ និងឆ្នាំ ២០២០ ។ ជាលទ្ធផលនៃការប្រៀបធៀបបង្ហាញថា សូចនាករនៃចំនួន ១០ ទទួលបានពិន្ទុខ្ពស់ជាងការវាយម្លៃលើកមុន រួមមាន PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI-19, PI-21, PI-23 និង PI-25 ***(ឧបសម្ព័ន្ធទី ៣)*** ។ សូចនាករចំនួន ១១ ត្រូវបានកែលម្ អដែលក្នុងនោះសូចនាករចំនួន ៧ បានកើនយ៉ាងហោចមួយចំណាត់ថ្នាក់ ។ ការកត់សម្គាល់នៃការប្រៀបធៀបវឌ្ឍនភាពឆ្នាំ ២០១៥ និងឆ្នាំ ២០២០ ត្រូវបានបង្ហាញដូចខាងក្រោម ÷

**វិន័យថវិកា** ÷ ទទួលបានវឌ្ឍនភាពល្អលើ "ភាពជឿទុកចិត្តនៃថវិកា" ទាំងការអនុវត្តចំណូល និងចំណាយ, ការតាមដានចំណូលពីគ្រឹះស្ថានសាធារណៈរដ្ឋបាល, និងតម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ ។ ចំណាត់ថ្នាក់ថវិកាត្រូវបានដាក់ឱ្យអនុវត្ត និងបន្តកែលម្អជាប្រចាំ ។ ឯកសារក្របខណ្ឌថវិការយៈពេលមធ្យមត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តសាកល្បង និងព័ត៌មានស្តីពីធនធានដែលទទួលដោយសាលាមានវឌ្ឍនភាពល្អ ។ ទោះបីជាយ៉ាងនេះក្តី, កង្វះព័ត៌មាននៃបំណុលយថាហេតុនៅតែជាបញ្ហា និងហានិភ័យសារពើពន្ធនៅតែមិនទាន់អាចវាយការណ៍បាន ។ ប្រព័ន្ធរដ្ឋបាលប្រមូលចំណូលនៅមិនទាន់អាចធានាពីប្រសិទ្ធភាពនៃការចុះបញ្ជីរបស់អ្នកបង់ពន្ធ ឬគ្រប់គ្រងបំណុលអ្នកជាប់ពន្ធ (PI-14) និងកម្រិតនៃបំណុលពន្ធកកស្ទះនៅតែបន្តមាន និងដោះស្រាយបានតិចតួច (PI-15 សមាសធាតុ 15.1) ។ កង្វះប្រសិទ្ធភាពប្រព័ន្ធកត់ត្រាវិក្កយបត្រលើទំនិញ និងការផ្តល់សេវានៅតែជាបញ្ហា (PI-4 សមាសធាតុ 4.2) ។ កង្វះខាតទាំងនេះ នឹងបង្កឱ្យមានសមិទ្ធកម្មល្អលើវិន័យថវិកានឹងប្រឈមហានិភ័យនៅក្នុងរយៈពេលខ្លីលើការប្រមូលចំណូលរបស់រាជរដ្ឋាភិបាល ឬអាចធ្វើឱ្យមានការថមថយនៃកំណើនសេដ្ឋកិច្ចនៅក្នុងរយៈពេលមធ្យម ។

**យុទ្ធសាស្ត្រវិភាជន៍ធនធាន** ÷ យុទ្ធសាស្ត្រវិភាជន៍ធនធានបង្ហាញនូវវឌ្ឍនភាពល្អ និងកម្រិតនៃការប្រែប្រួលក្នុងសមាសភាពចំណាយ ត្រូវបានកាត់បន្ថយ ដែលបញ្ជាក់ពីអភិក្រមនៃការរៀបចំធ្វើឡើងតាមលំដាប់លំដោយ និងមានការចូលរួមក្នុងការរៀបចំថវិកាប្រចាំឆ្នាំ ។ ការត្រួតពិនិត្យដោយអង្គនីតិប្បញ្ញត្តិបានទាន់ពេលវេលា និងតាមនីតិវិធីត្រឹមត្រូវក៏ដូចជាភាពទាន់ពេលវេលា និងភាពអាចជឿជាក់បាននៃព័ត៌មានអំពីការផ្ទេរធនធានទៅឱ្យ ឃុំ-សង្កាត់ ។ ទោះបីជាយ៉ាងនេះក្តី ផែនការយុទ្ធសាស្ត្រតាមវិស័យនៅតែមានភាពខ្សោយ លើកលែងតែវិស័យសុខាភិបាល និងអប់រំ ។ ទន្ទឹមនឹងនេះក្របខណ្ឌចំណាយរយៈពេលមធ្យមមិនត្រូវបានរៀបចំពេញលេញ និងសមាហរណកម្មទៅក្នុងដំណើរការរៀបចំថវិកាជាមួយការផ្សារភ្ជាប់ច្បាស់លាស់ពីវដ្តថវិកាមួយទៅវដ្តថវិកាមួយទៀត លើកលែងតែថវិកាសរុប ។

**ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ** ÷ ព័ត៌មានពាក់ព័ន្ធនឹងធនធាន ដែលទទួលដោយសាលារៀននានាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ និងប្រព័ន្ធលទ្ធកម្មមានតម្លាភាព និងការទទួលបានព័ត៌មានថវិកាជាសាធារណៈមានភាពល្អប្រសើរ ។ ទោះបីជាយ៉ាងនេះក្តី, នៅមានភាពខ្សោយដទៃទៀតស្ថិតនៅក្នុងការតាមដាន និងការវាយតម្លៃសមិទ្ធកម្មនៃស្ថាប័នការផ្តល់សេវាសាធារណៈ និងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។

## *ក្រាហ្វិចលទ្ធផលសង្ខេបនៃការវាយតម្លៃ PEFA ឆ្នាំ២០១៥ និងឆ្នាំ ២០២០*






## ៥. ទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ផ្អែកលើលទ្ធផលវាយតម្លៃការអនុវត្ត CAP3 បង្ហាញថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ សម្រេចបាននូវភាពជឿទុកចិត្តនៃថវិកាដែលរឹងមាំគ្រប់គ្រាន់, ឆ្អឹងខ្នងនៃគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានដាក់ឱ្យអនុវត្ត, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយសម្រេចបានជាសារវ័ន្ត និងមូលដ្ឋានសំខាន់នៃគណនេយ្យភាពសមិទ្ធកម្ម ត្រូវបានលេចចេញជារូបរាងជាបណ្តើរៗ ។

ផ្អែកតាមលទ្ធផលវាយតម្លៃ PEFA ថ្នាក់ជាតិឆ្នាំ ២០២០ បង្ហាញថា ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមានគ្រប់មុខងារទាំងអស់ ដោយគ្រាន់តែត្រូវបន្តពង្រឹងគុណភាពបន្ថែមទៀត, ចំណែកថ្នាក់ក្រោមជាតិនៅមានលក្ខណៈមជ្ឈការហិរញ្ញវត្ថុនៅឡើយ និងចាំបាច់ពង្រឹងយន្តការប្រតិគុល្យភាពរវាងអភិបាលនៃគណៈអភិបាល និងក្រុមប្រឹក្សា ។ លទ្ធផលនៃការវាយតម្លៃ PEFA ដោយវាស់វែងលើសូចនាករគន្លឹះចំនួន ២៧ នៅឆ្នាំ ២០១៥ និងឆ្នាំ ២០២០ បង្ហាញថា សូចនាករចំនួន ១០ ត្រូវបានកែលម្អ, ដែលក្នុងនោះ ចំនួន ៧ កើនយ៉ាងហោចមួយកម្រិត ដែលរួមមាន ការទទួលបានព័ត៌មានពីធនធានរបស់អង្គភាពអនុវត្ត, ចំណាត់ថ្នាក់ថវិកា, ប្រព័ន្ធលទ្ធកម្មមានភាពប្រកួតប្រជែង ធានាតម្លៃនៃលុយ និងត្រួតពិនិត្យ, សំណុំឯកសារថវិកាមានព័ត៌មានកាន់តែពេញលេញ, ការទទួលបានព័ត៌មានពីថវិការបស់សាធារណជន និងការផលិតរបាយការណ៍ហិរញ្ញវត្ថុទាន់ពេល និងមានគុណភាព ។ ដោយឡែកសូចនាករគន្លឹះមួយធ្លាក់ចុះ ដោយសារប្រមូលចំណូលត្រូវបានគ្រោងទាបខ្លាំងពេកធៀបទៅនឹងការអនុវត្តជាក់ស្តែង ។ ទោះបីជាលទ្ធផលបង្ហាញអំពីវឌ្ឍនភាពនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ, ប៉ុន្តែវឌ្ឍនភាពត្រូវការកែលម្អបន្ថែមទៀត នៅគ្រប់ខឿនទាំងអស់ដែលបន្តអនុវត្តថែមទៀត ។

នៅក្នុងន័យនេះ ការបោះជំហានទៅមុខនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានពិចារណាក្នុងជម្រើសពីរ ÷ ទី១).ការពន្យាពេលផែនការរួមដំណាក់កាលទី ៣ ដោយមានការកែសម្រួលអាទិភាពមួយចំនួនឡើងវិញ និងខិតខំសម្រេចឱ្យបាននូវកិច្ចការដែលនៅសេសសល់ឱ្យបានជាអតិបរមា និង ទី២).ការឈានទៅអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី ៤ ដោយកែសម្រួលអាទិភាពឡើងវិញ និងបញ្ចូលការងារសេសសល់នៅក្នុងដំណាក់កាលទី ៤ តែម្តង ។

សម្រាប់ជម្រើសទី ១, ការពន្យារពេលនឹងអនុញ្ញាតឱ្យកម្ពុជាបញ្ចប់នូវកិច្ចការទាំងឡាយដែលបានគ្រោងបានពេញលេញល្អ ដែលនឹងក្លាយជាមូលដ្ឋានគ្រប់គ្រាន់ និងរឹងមាំ សម្រាប់គណនេយ្យភាពសមិទ្ធកម្ម ។ បទពិសោធន៍នៅបណ្តាប្រទេសជាច្រើនបានបង្ហាញថា គណនេយ្យភាពសមិទ្ធកម្មនឹងពិបាកសម្រេចបាន បើមូលដ្ឋាននៃខឿនបីខាងដើមមិនមានលក្ខណៈរឹងមាំគ្រប់គ្រាន់ ។ លើសពីនេះ ការសម្រេចនូវគណនេយ្យសមិទ្ធកម្មមិនមែនជាការងាយស្រួលទេ សូម្បីតែនៅក្នុងប្រទេសអភិវឌ្ឍន៍ក៏ដោយ ។ ក្នុងន័យនេះ កម្ពុជាមិនត្រូវប្រញ៉ាប់ប្រញាល់ខ្លាំងក្នុងការឆ្ពោះទៅរកខឿនទី ៤ ពេកទេ ។ ទោះបីជាយ៉ាងនេះក្តី សម្រាប់ជម្រើសទី ១ នេះ អាចនឹងបង្កើតនូវផលអវិជ្ជមានមួយចំនួន ពីព្រោះការពន្យាររយៈពេល ១ ទៅ ២ ឆ្នាំ ឬច្រើនជាងនេះ នឹងមិនអាចផ្លាស់ប្រព័ន្ធអ្វីគួរឱ្យកត់សម្គាល់នូវលទ្ធផលដែលសម្រេចបានសព្វថ្ងៃទេ ពោលគឺគ្រាន់តែពង្រឹងនូវវឌ្ឍនភាពដែលមានស្រាប់តែប៉ុណ្ណោះ ។ ប្រការនេះអាចនាំឱ្យបាត់បង់នូវជវភាពនៃការងារកែទម្រង់ដែលខិតខំរក្សាក្នុងរយៈពេល ១៥ ឆ្នាំកន្លងមក ។ លើសពីនេះទៅទៀត, ផែនការសកម្មភាពរួមដំណាក់កាលទី ៣ មានចន្លោះប្រហោងមួយចំនួនដែលកែតម្រូវ និងផ្លាស់កម្រិតអាទិភាព ។ ដូចនេះ ការកែសម្រួលផែនការសកម្មភាពរួម នឹងត្រូវធ្វើជាចាំបាច់ ដើម្បីតម្រង់ទៅរកគណនេយ្យភាពសមិទ្ធកម្ម ។

សម្រាប់ជម្រើសទី ២ គឺការបោះជំហានទៅខឿនទី ៤ ជាជម្រើសល្អមួយសម្រាប់បូកសរុបការងារកែទម្រង់រយៈពេល ២១ ឆ្នាំ ដែលជាពេលវេលាដ៏វែងមួយក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ នៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមដំណាក់កាលនីមួយៗ គឺរៀបចំឡើងដើម្បីផ្តោតការយកចិត្តទុកដាក់លើខឿននីមួយៗប៉ុណ្ណោះ ។ តាមការអនុវត្តកន្លងមក, សកម្មភាពកែទម្រង់មិនបានបញ្ចប់ខឿនមួយទាំងស្រុង ទើបឆ្ពោះទៅរកការរៀបចំការងារកែទម្រង់លើខឿនថ្មីនោះទេ ។ ជាក់ស្តែង ការបោះជំហានទៅកាន់ដំណាក់កាលទី ៣ ត្រូវបានធ្វើឡើង ទន្ទឹមនឹងពង្រឹងខឿនទី ១ និងខឿនទី ២ ដែលត្រូវកែលម្អជាប្រចាំ ដោយមិនរង់ចាំការសម្រេចបាននូវខឿនទាំង ២ ទាំងស្រុងឡើយ ។ ដូចគ្នាដែរ ការបោះជំហានទៅកាន់ដំណាក់កាលទី ៤ "គណនេយ្យភាពសមិទ្ធកម្ម" អាចធ្វើបានដោយមិនចាំបាច់រង់ចាំខឿនទាំងបីបញ្ចប់ដែរ ពីព្រោះថាសម្រាប់ខឿនទី ២ ការអនុវត្ត FMIS សម្រេចបានជាសារវ័ន្ត ចំណែកខឿនទី ៣ ការអនុវត្តថវិកាកម្មវិធីក៏ត្រូវបានអនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន រួចហើយដែរ ។ ម៉្យាងវិញទៀត, ការបោះជំហានឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម ក៏អាចធ្វើឡើងក្នុងរបៀបចាប់ផ្តើមដំបូងនៃការកសាងធាតុផ្សំចាំបាច់នានា សំដៅដាក់ឱ្យអនុវត្តគណនេយ្យភាពសមិទ្ធកម្មជាបណ្តើរៗ ។ ក្នុងន័យនេះ ការបញ្ចប់ដំណាក់កាលទី ៤ មិនមានន័យថាជាការសម្រេចបាននូវគណនេយ្យភាពសមិទ្ធកម្មពេញលេញនោះទេ ដែលនេះមិនមែនជាការត្រឹមត្រូវក្នុងការសម្រេចបានតែក្នុងរយៈពេល ៥ ឆ្នាំដែរ ។ គោលបំណងដែលមានភាពប្រាកដនិយមសម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ គឺជាការរៀបចំខ្លួនសព្វគ្រប់សម្រាប់ការកសាងនូវ "វប្បធម៌គណនេយ្យភាពសមិទ្ធកម្ម" ពីព្រោះផលប៉ះពាល់ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឱ្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានភាពមិនច្បាស់លាស់ ដែលធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវរក្សានូវភាពទន់ភ្លន់ក្នុងការឆ្លើយតបទៅនឹងសភាពការណ៍ដែលប្រែប្រួល ។ ក្នុងការកសាងសមិទ្ធកម្ម បរិយាកាសស្ថិរភាពក្នុងរយៈពេលបង្គួរទើបមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការបង្កើតពត៌មានគ្រប់ជ្រុងជ្រោយ និងគុណភាពល្អ សម្រាប់វាយតម្លៃសមិទ្ធកម្ម ។

ជារួម ការបោះជំហានទៅដំណាក់កាលទី ៤ ដែលផ្តោតលើខឿនទី ៤ "គណនេយ្យភាពសមិទ្ធកម្ម" មានមូលដ្ឋានគ្រប់គ្រាន់ ទោះបីជាអាចធានាបានចលនានៃការកែទម្រង់ឱ្យបន្តរស់រវើក និងមានសន្ទុះខ្លាំងទៅមុខទៀតក្តី ប៉ុន្តែមូលដ្ឋានទាំងនោះមិនទាន់រឹងមាំនៅឡើយ ។ តាមទិសដៅនេះ ការឈានទៅដំណាក់កាលទី ៤ អាចសម្រេចបានត្រឹមតែការដាក់ឱ្យអនុវត្ត "ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម" ដែលប្រព័ន្ធនេះនឹងត្រូវការកែលម្អជាច្រើនបន្តបន្ទាប់ថែមទៀតឆ្ពោះទៅកសាងប្រព័ន្ធសមិទ្ធកម្មមួយ ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ ។ ដោយសារដំណាក់កាលទី ៤ គឺជាដំណាក់កាលការប្រែក្លាយ "ប្រព័ន្ធ ក្របខណ្ឌគតិយុត្តិ យន្តការ និង ធនធានមនុស្ស" ដែលបានកសាងទាំងបួនដំណាក់កាល ទៅជាការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ និងការរំពឹងទុកថ្មីៗរបស់ប្រជាជន, ការប្រែប្រួលបរិការណ៍ក្នុង និងក្រៅប្រទេស និង ការសម្រេចបាននូវចក្ខុវិស័យកម្ពុជា, ការពង្រឹងគណនេយ្យសមិទ្ធកម្មឱ្យបានរឹងមាំត្រូវការជាចាំបាច់ ។ គណនេយ្យភាពសមិទ្ធកម្មមានវិសាលភាពធំទូលាយជាងការកែទម្រង់ប្រព័ន្ធថវិកានិយាយជារួម ឬ ការកែទម្រង់ការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈនិយាយដោយឡែក ពីព្រោះនៅមានការដ្ឋានកែទម្រង់ផ្សេងៗ ដែលត្រូវមានលក្ខណៈប្រទាក់ក្រឡាគ្នា ។ ក្នុងន័យនេះ ការបោះជំហានទៅកាន់ដំណាក់កាលទី ៤ ត្រូវបោះជំហានស្រប និងស៊ីច្រវ៉ាក់គ្នាជាមួយនឹងការដ្ឋានកែទម្រង់ផ្សេងៗ ដើម្បីអាចផ្តល់ប្រែក្លាយកិច្ចខិតខំប្រឹងប្រែងទាំងអស់ទៅជាប្រព័ន្ធអភិបាលកិច្ចសមិទ្ធកម្មមួយ ក្នុងខណៈដែលកម្ពុជាអាចនឹងឈានទៅដល់ការបញ្ចប់ក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ។ នៅពេលដែលកំណែទម្រង់ពីរទៀត

កំពុងមានវឌ្ឍនភាពសន្សឹមៗ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគួរផ្តោតការយកចិត្តទុកដាក់លើជម្រៅ និងមូលដ្ឋានគ្រឹះឱ្យបានរឹងមាំសិន ជាជាងការផ្តោតលើការបោះជំហានទៅមុខ និងបង្ខំសម្រេចឱ្យបាននូវជំហានទី ៤ ។

សរុបមក ដើម្បីធានាការបោះជំហានទៅកាន់ដំណាក់កាលទី ៤, ជម្រើសទី ១ មានលក្ខណៈសមស្រប ពោលគឺពន្យារពេលអនុវត្តក្នុងរយៈពេល ២ ឆ្នាំ ។ រយៈពេលនេះគឺសមល្មម ដោយសារតែវិបត្តិនៃជំងឺកូវីដ-១៩ អាចនឹងបញ្ចប់ព្រមទាំងការងារទាំងឡាយដែលបានពន្យារនឹងមានពេលគ្រប់គ្រាន់នឹងសម្រេចបាន ។ ពេលវេលានេះក៏អាចប្រើប្រាស់បានសម្រាប់សម្រួចការងារដែលនៅសេសសល់ផ្សេងៗ ទៀតផងដែរ ។

## ៦. Implication សម្រាប់រៀបចំផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២

### ៦.១. សុពលភាពនៃខឿន

ការរៀបចំផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២, ក្រុមការងារបច្ចេកទេស អ.គ.ហ. នឹងមិនរក្សាទម្រង់ផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ ទៀតទេ គឺរៀបចំកែសម្រួលជាថ្មីឡើងវិញ ដោយបែកចែកគោលបំណងច្បាស់លាស់តាមផ្នែក/ខឿននីមួយៗ ។ ការប្តូរទម្រង់នេះ គឺដើម្បីត្រៀម និងធានាការបោះជំហានទៅកាន់ដំណាក់កាលទី ៤ ។ ទន្ទឹមនឹងនេះ ផ្នែកទី១ ឬ ខឿនទី១ **ភាពជឿទុកចិត្តនៃថវិកា** ត្រូវបានរៀបចំឱ្យមានជាលក្ខណៈរួម/កម្រិតរួម (Aggregate level) ឆ្លុះបញ្ចាំងប្រព័ន្ធទាំងមូល តាមរយៈការពិនិត្យនិងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការប្រមូលចំណូល និងអនុវត្តចំណាយ ។ ចំពោះផ្នែកផ្សេងទៀតនឹងត្រូវរៀបចំ និងអនុវត្តជាដំណាក់កាលៗ ក្នុងនោះផ្នែកទី ២ ដោយបញ្ចប់ការងារក្នុងដំណាក់កាលទី២ ដើម្បីពង្រឹងខឿនទី ២, ផ្នែកទី ៣ នឹងបន្តការអនុវត្តការងារសេសសល់ក្នុងដំណាក់កាលទី៣ ដើម្បីពង្រឹងខឿនទី៣, ផ្នែកទី ៤ នឹងផ្តោតលើការឈានឆ្ពោះទៅកាន់គណនេយ្យភាពសមិទ្ធកម្ម, និងផ្នែកទី ៥ នឹងផ្តោតលើការងាររក្សាឱ្យបាននូវចលនានៃការកែទម្រង់ និងភាពប្រទាក់ក្រឡាគ្នារវាងការដ្ឋានកែទម្រង់ផ្សេងៗទៀត ។

| ក្របខណ្ឌ CAP3 | ក្របខណ្ឌ CAP3 បូក ២ |
|---|---|
| ផ្នែកទី១ “បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា” | ខឿន/ផ្នែកទី១ “ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា” |
| ផ្នែកទី២ “ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ” | ខឿន/ផ្នែកទី២ “ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ” |
| ផ្នែកទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” | ខឿន/ផ្នែកទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” |
| ផ្នែកទី៤ “ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់” | ខឿន/ផ្នែកទី៤ “ការឈានឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម” |
| ផ្នែកទី៥ “ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយជោគជ័យ និងចីរភាព” | ផ្នែកទី៥ “ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត” |

### ៦.២. ផ្លាស់ប្តូរកម្រិតគោលបំណង

ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត CAP3 និង PEFA, ក្រុមការងារ អ.គ.ហ. នឹងធ្វើបច្ចុប្បន្នភាព ឬ ផ្លាស់ប្តូរគោលបំណងមួយចំនួនដោយបង្រួមគោលបំណងមួយចំនួនដែលស្រដៀងគ្នា និងបង្កើតថ្មី និងពង្រឹងការអនុវត្តការងារនៅសេសសល់តាមខឿននីមួយៗ ។ បង្កើតគោលបំណង ឬ ចង្កោមសកម្មភាពថ្មី ដោយផ្អែកលើយុទ្ធសាស្ត្រ ដែលបានដាក់ឱ្យអនុវត្តនៅក្នុងដំណាក់កាលទី ៣ រួមមាន ÷ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រ

ស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២៥, និងយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ព្រមទាំងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ។

ការរៀបចំផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២ ឆ្នាំ ២០២១-២០២២, **អ.គ.ហ** នឹងធ្វើកែសម្រួលដោយបង្រួមពីចំនួន ២១ គោលបំណង ដែលបានកំណត់សម្រាប់អនុវត្ត CAP3 មកនៅត្រឹមចំនួន ១៩ គោលបំណងវិញសម្រាប់ផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២ ឆ្នាំ២០២១-២០២២ រួមមាន ខឿន/ផ្នែកទី ១ មានចំនួន ៣ គោលបំណង (CAP3 មានចំនួន ៤ គោលបំណង), ខឿន/ផ្នែកទី ២ មានចំនួន ៥ គោលបំណង (CAP3 មានចំនួន ៥ គោលបំណង), ខឿន/ផ្នែកទី ៣ មានចំនួន ៤ គោលបំណង (CAP3 មានចំនួន ៥ គោលបំណង), ខឿន/ផ្នែកទី ៤ មានចំនួន ៤ គោលបំណង (CAP3 មានចំនួន ៤ គោលបំណង), និងផ្នែកទី ៥ មានចំនួន ៣ គោលបំណង (CAP3 មានចំនួន ៣ គោលបំណង) ។ *(សូមមើល ឧបសម្ព័ន្ធទី ៤)*

## ៧. សេចក្តីសន្និដ្ឋាន

ការអនុវត្តកម្មវិធីកែទម្រង់កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ សម្រេចបាននូវភាពជឿទុកចិត្តនៃថវិកាដែលរឹងមាំគ្រប់គ្រាន់ និងឆ្អឹងខ្នងនៃគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានដាក់ឱ្យអនុវត្ត ។ ការវាយតម្លៃអំពីការអនុវត្តនៃដំណាក់កាលទី ៣ នេះ បានបង្ហាញថា ខឿនទី ១ ស្តីពីការបង្កើនភាពជឿទុកចិត្តនៃថវិកា រក្សាបាននូវភាពរឹងមាំ, ខឿនទី ២ ស្តីពីការពង្រឹង និងពង្រីកគណនេយ្យភាពហិរញ្ញវត្ថុ បន្តមានវឌ្ឍនភាពល្អ, ខឿនទី ៣ ស្តីពីការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ បានសម្រេចជាសារវ័ន្ត និងមូលដ្ឋានសំខាន់នៃគណនេយ្យភាពសមិទ្ធកម្មត្រូវបានលេចចេញជារូបរាងជាបណ្តើរៗ, និង ខឿនទី ៤ ស្តីពីការត្រៀមខ្លួនឆ្ពោះទៅកាន់គណនេយ្យភាពសមិទ្ធកម្ម នៅមិនទាន់សម្រេចបានតាមការគ្រោងទុកនៅឡើយ ។ ផ្អែកលើមូលដ្ឋាននៃការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ ឆ្នាំ២០១៦-២០២០ រាជរដ្ឋាភិបាលសម្រេចបន្តអនុវត្ត CAP3 រយៈពេល ២ ឆ្នាំទៀត ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿនទាំងបីខាងដើម មុននឹងឈានទៅខឿនទី ៤ "គណនេយ្យភាពសមិទ្ធកម្ម" ។

ការរៀបចំក្របខណ្ឌផែនការសកម្មភាពរួម-ដំណាក់កាលទី ៣ បូក ២ និងដំណាក់កាលទី ៤ នៅតែរក្សារចនាសម្ព័ន្ធជា ៥ ផ្នែក និងផ្តល់អាទិភាព ។ ផ្នែកទី ១ "**ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា**" ដោយផ្តោតលើការអនុវត្តគោលនយោបាយ និងការគ្រប់គ្រងចំណូលសារពើពន្ធនិងមិនមែនពន្ធ និងការអនុវត្តផែនការចំណាយថវិកា ។ ផ្នែកទី ២ "**ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ**" ដោយពង្រឹងនិងពង្រីកការប្រើប្រាស់ FMIS ។ ផ្នែកទី ៣ "**ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ផ្តោតលើថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា, ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មថវិកា, ការកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នសាមី និងស្ថាប័ននីតិប្បញ្ញត្តិ, ការរៀបចំឱ្យមានក្របខណ្ឌចំណាយសាធារណៈរយៈពេលមធ្យម, ការបង្កើតប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ, និងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ។ ផ្នែកទី ៤ "**ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម**" ផ្តោតលើក្របខណ្ឌថវិកាសមិទ្ធកម្ម, ការកំណត់បន្ទាត់គណនេយ្យភាពថវិកាសមិទ្ធកម្ម, ការដាក់ឱ្យអនុវត្តក្របខណ្ឌសវនកម្មសមិទ្ធកម្ម និងផែនការអភិវឌ្ឍន៍សមត្ថភាព ។ ផ្នែកទី ៥ "**ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត**" ផ្តោតលើការលើកកម្ពស់ភាពជាអ្នកដឹកនាំក្នុងការងារកែទម្រង់, ការកសាងសមត្ថភាព និងការផ្តល់ការលើកទឹកចិត្តដល់ការងារកែទម្រង់ និងការពង្រឹងសមត្ថភាពសម្រាប់ការអនុវត្តដំណាក់កាលទី ៣ ។

# ឧបសម្ព័ន្ធ

*សូមមេត្តា Scan QR Code ខាងក្រោម សម្រាប់ទាញយកឯកសារឧបសម្ព័ន្ធ ។*

**ឧបសម្ព័ន្ធទី ១. របាយការណ៍ត្រួតពិនិត្យ CAP3 របស់ធនាគារអភិវឌ្ឍន៍អាស៊ី**

**ឧបសម្ព័ន្ធទី ២. របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៦-២០២០ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣**

**ឧបសម្ព័ន្ធទី ៣. តារាងសង្ខេបការប្រៀបធៀបបម្រែបម្រួលពិន្ទុនៃការវាយតម្លៃ PEFA ឆ្នាំ ២០១៥ និងឆ្នាំ ២០២០ ដោយប្រើប្រាស់ក្របខណ្ឌវាយតម្លៃឆ្នាំ ២០១១**

| ឈ្មោះសូចនាករ/ សមាសធាតុ នៃ PEFA | | ពិន្ទុឆ្នាំ២០១៥ | ពិន្ទុឆ្នាំ ២០២០ |
|---|---|---|---|
| *សសរស្តម្ភ ១ ÷ ភាពជឿទុកចិត្តនៃថវិកា* | | | |
| **PI-1** | **ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | A | A |
| **PI-2** | **សមាសធាតុចំណាយធៀបនឹងច្បាប់ដែលបានអនុម័ត** | D+ | B+ |
| 2.1 | កម្រិតនៃការប្រែប្រួលក្នុងសមាសភាពចំណាយដោយមិនគិតបញ្ចូលនូវចំណាយមិនបានគ្រោងទុក | D | B |
| 2.2 | ចំនួនជាមធ្យមនៃការចំណាយដែលបានកើតឡើងជាក់ស្តែងក្នុងខ្ទង់ចំណាយដែលមិនបានគ្រោងទុក | B | A |
| **PI-3** | **ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត** | A | D |
| **PI-4** | **សន្និធិបំណុលកកសន្ទះ និងការត្រួតពិនិត្យតាមដានបំណុលកកស្ទះ** | D+ | D+ |
| 4.1 | កម្រិតស្តុកនៃចំណាយដែលនៅជំពាក់ (គិតជាភាគរយនៃចំណាយសរុបជាក់ស្តែងសម្រាប់ឆ្នាំថវិកាដែលពាក់ព័ន្ធ) និងការប្រែប្រួលថ្មីៗនៅក្នុងស្តុកចំណាយដែលនៅជំពាក់ | D | D |
| 4.2 | ទិន្នន័យដែលអាចស្វែងរកបានសម្រាប់ការត្រួតពិនិត្យតាមដាននៃនៃចំណាយដែលនៅជំពាក់ | C | C |
| *សសរស្តម្ភ ២ ÷ ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា* | | | |
| **PI-5** | **ចំណាត់ថ្នាក់ថវិកា** | C | C |
| **PI-6** | **ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា** | C | B |
| **PI-7** | **ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍** | C | B |
| 7.1 | ចំណាយថវិកាបន្ថែមដែលមិនត្រូវបានរាយការណ៍ | C | B |
| 7.2 | ព័ត៌មានស្តីពីចំណូល-ចំណាយសម្រាប់គម្រោងដែលគាំទ្រដោយហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ | C | B |
| **PI-8** | **តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់រដ្ឋបាល (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)** | B | B |
| 8.1 | តម្លាភាព និងភាពមិនលម្អៀងក្នុងការបែងចែកធនធានក្នុងចំណោមរដ្ឋបាលថ្នាក់ក្រោមជាតិ | A | A |

| | | | |
|---|---|---|---|
| 8.2 | ភាពទាន់ពេលវេលានៃព័ត៌មានដែលអាចជឿទុកចិត្តបានស្តីពីការវិភាគថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A |
| 8.3 | កម្រិតនៃការប្រមូលសរុបទិន្នន័យសារពើពន្ធរបស់រដ្ឋាភិបាលដោយអនុលោមតាមយុទ្ធសាស្ត្រតាមវិស័យ | D | D |
| **PI-9** | **លទ្ធភាពសាធារណជនទទួលបានព័ត៌មានហិរញ្ញវត្ថុសាធារណៈ** | **C+** | **C+** |
| 9.1 | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់កណ្តាលទៅលើអង្គភាពស្វយ័ត និងសហគ្រាសរដ្ឋ | C | C |
| 9.2 | កម្រិតនៃការតាមដានរបស់រដ្ឋបាលថ្នាក់ជាតិទៅលើស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | A | A |
| **PI-10** | **ការកត់ត្រាហានិភ័យហិរញ្ញវត្ថុសាធារណៈ** | **D** | **B** |
| ***សសរស្តម្ភ ៣ ÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*** | | | |
| **PI-11** | **កាលានុក្រម និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ** | **A** | **A** |
| 11.1 | អត្ថិភាព និងការប្រកាន់ខ្ជាប់កាលវិភាគថវិកា | A | A |
| 11.2 | ភាពច្បាស់លាស់/ភាពគ្រប់ជ្រុងជ្រោយ និងការចូលរួមផ្នែកនយោបាយក្នុងការណែនាំអំពីការរៀបចំដាក់សំណើថវិកា | A | A |
| 11.3 | ការអនុម័តថវិកាទាន់ពេលវេលាដោយអង្គនីតិបញ្ញត្តិ ឬ ស្ថាប័នមានសមត្ថកិច្ចប្រហាក់ប្រហែល | A | A |
| **PI-12** | **ទស្សនវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកាគោលនយោបាយចំណាយ និងការរៀបចំថវិកា** | **C+** | **C+** |
| 12.1 | ការរៀបចំនូវការព្យាករថវិកាពហុឆ្នាំ និងការវិភាជតាមមុខងារ | C | C |
| 12.2 | វិសាលភាព និងភាពញឹកញាប់នៃការវិភាគនិរន្តរភាពបំណុល | A | A |
| 12.3 | យុទ្ធសាស្ត្រតាមវិស័យដែលមានការគណនាចំណាយចរន្ត និងចំណាយវិនិយោគសម្រាប់រយៈពេលច្រើនឆ្នាំ | C | C |
| 12.4 | ការផ្សារភ្ជាប់គ្នារវាងថវិកាវិនិយោគ និងការព្យាករចំណាយរំកិល | C | C |
| ***សសរស្តម្ភ ៤ ÷ ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា*** | | | |
| **PI-13** | **តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ** | **C+** | **B** |
| 13.1 | ភាពច្បាស់លាស់ និងភាពគ្រប់ជ្រុងជ្រោយនៃគោលការណ៍ច្បាប់ និងនីតិវិធីរដ្ឋបាលស្តីពីបំណុលពន្ធ | C | C |
| 13.2 | លទ្ធភាពរបស់អ្នកជាប់ពន្ធក្នុងការទទួលបាននូវព័ត៌មានស្តីពីកាតព្វកិច្ចបង់ពន្ធ បំណុលពន្ធ និងនីតិវិធីរដ្ឋបាល | B | B |
| 13.3 | ដំណើរការនៃយន្តការតវ៉ាពន្ធ | C | B |

| | | | |
|---|---|---|---|
| **PI-14** | **ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ** | D+ | C+ |
| 14.1 | ការត្រួតពិនិត្យប្រព័ន្ធចុះបញ្ជីអ្នកជាប់ពន្ធ | D | C |
| 14.2 | ប្រសិទ្ធភាពនៃការដាក់ទោសទណ្ឌសម្រាប់ការមិនអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីពន្ធ និងការប្រកាសពន្ធ | C | C |
| 14.3 | ការធ្វើផែនការ និងការត្រួតពិនិត្យតាមដានកម្មវិធីសវនកម្មពន្ធ និងកម្មវិធីស៊ើបអង្កេតការគេចវេសពន្ធ | C | B |
| **PI-15** | **ប្រសិទ្ធភាពនៃការប្រមូលពន្ធ** | D+ | NR |
| 15.1 | អនុបាតប្រមូលពន្ធចំពោះបំណុលពន្ធដុល ដែលជាភាគរយនៃបំណុលពន្ធនៅដើមឆ្នាំសារពើពន្ធ និងដែលត្រូវបានប្រមូលក្នុងឆ្នាំសារពើពន្ធ | D | D |
| 15.2 | ប្រសិទ្ធភាពនៃការផ្ទេរប្រាក់ពន្ធដែលប្រមូលបានទៅរតនាគារដោយរដ្ឋបាលចំណូល | B | A |
| 15.3 | ពេលវេលានៃការផ្ទៀងផ្ទាត់គណនីពេញលេញដោយរតនាគាររវាងការវាយតម្លៃពន្ធ, ការប្រមូលពន្ធ, កំណត់ត្រាបំណុលពន្ធ និងវិក្កយបត្រ | C | C |
| **PI-16** | **ភាពអាចប៉ាន់ប្រមាណបាននូវអស្ថិរភាពថវិកាសម្រាប់ធានាចំណាយ** | C+ | C+ |
| 16.1 | វិសាលភាពដែលលំហូរសាច់ប្រាក់អាចព្យាករណ៍បាន និងត្រូវបានត្រួតពិនិត្យ | B | B |
| 16.2 | សុក្រឹត្យភាព និងការផ្តល់ថវិកាគ្រប់គ្រាន់ទាន់ពេលវេលាសម្រាប់ការគ្រោងចំណាយដោយក្រសួង ស្ថាប័ន | B | B |
| 16.3 | អត្រានៃការកើតឡើង (Frequency) និងតម្លាភាពនៃការផ្ទេរថវិកាដែលត្រូវបានសម្រេចលើសពីសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន | C | C |
| **PI-17** | **ការកត់ត្រា និងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា** | C+ | C+ |
| 17.1 | គុណភាពនៃកំណត់ត្រា និងការរាយការណ៍ទិន្នន័យបំណុល | C | C |
| 17.2 | វិសាលភាពនៃការប្រមូលសរុបសមតុល្យសាច់ប្រាក់របស់រាជរដ្ឋាភិបាល | B | B |
| 17.3 | ប្រព័ន្ធនៃការចុះកិច្ចសន្យាខ្ចី និងការចេញផ្សាយធានា | C | C |
| **PI-18** | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស** | D+ | D+ |

| | | | |
|---|---|---|---|
| 18.1 | ការធ្វើសមាហរណកម្ម និងការផ្ទៀងផ្ទាត់រវាងទិន្នន័យចំនួនបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B |
| 18.2 | ភាពទាន់ពេលវេលានៃការកែសម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | C | C |
| 18.3 | ការត្រួតពិនិត្យផ្ទៃក្នុងលើបម្រែបម្រួលព័ត៌មានបុគ្គលិក និងបញ្ជីប្រាក់បៀវត្ស | B | B |
| 18.4 | ការធ្វើសវនកម្មលើបញ្ជីប្រាក់បៀវត្សដែលបង្ហាញពីចំណុចខ្សោយនៃការត្រួតពិនិត្យ និង/ ឬ ចំនួនមន្ត្រីខ្មោច | D | D |
| **PI-19** | **តម្លាភាពការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម** | **D+** | **C+** |
| 19.1 | មានក្របខណ្ឌគតិយុត្តសម្រាប់ធានាតម្លាភាព ភាពគ្រប់ជ្រុងជ្រោយ និងការប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | B | B |
| 19.2 | ការប្រើប្រាស់នីតិវិធីប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្ម | D | D |
| 19.3 | សាធារណជនអាចទទួលបានព័ត៌មានស្តីពីកិច្ចលទ្ធកម្មបានគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងអាចទុកចិត្តបាន | D | A |
| 19.4 | មានយន្តការឯករាជ្យសម្រាប់ដោះស្រាយបណ្តឹងតវ៉ាកិច្ចលទ្ធកម្ម | D | D |
| **PI-20** | **ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស** | **C** | **C** |
| 20.1 | ប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យការធានាចំណាយ | C | C |
| 20.2 | ភាពគ្រប់ជ្រុងជ្រោយ ភាពសមស្រប និងការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនៃការត្រួតពិនិត្យផ្ទៃក្នុង | C | C |
| 20.3 | កម្រិតនៃអនុលោមភាពទៅនឹងវិធាននៃកិច្ចដំណើរការ និងការកត់ត្រាកិច្ចប្រតិបត្តិការ (Transaction) | C | C |
| **PI-21** | **ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង** | **C** | **C+** |
| 21.1 | វិសាលភាព និងគុណភាពនៃមុខងាររបស់សវនកម្មផ្ទៃក្នុង | C | C |
| 21.2 | ភាពទៀងទាត់ និងការចែកចាយនៃរបាយការណ៍សវនកម្មផ្ទៃក្នុង | C | B |
| 21.3 | ការអនុវត្តទៅតាមអនុសាសន៍សវនកម្មផ្ទៃក្នុងបានលើកឡើង | C | C |
| *សសរស្តម្ភ ៥ ÷ គណនេយ្យ ការកត់ត្រា និងរបាយការណ៍* | | | |
| **PI-22** | **ភាពទាន់ពេល និងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី** | **C** | **C** |
| 22.1 | ភាពទៀងទាត់នៃការផ្ទៀងផ្ទាត់ធនាគារ | B | B |
| 22.2 | ភាពទៀងទាត់នការផ្ទៀងផ្ទាត់ និងការទូទាត់គណនីរង់ចាំ និងគណនីបុរេប្រទាន | D | D |

| | | | |
|---|---|---|---|
| PI-23 | **អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា** | D | B |
| PI-24 | **គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ថវិកាក្នុងឆ្នាំ** | C | C+ |
| 24.1 | វិសាលភាពនៃរបាយការណ៍ថវិកាក្នុងឆ្នាំ ក្នុងន័យវិសាលភាព និងសមត្ថភាពជាមួយនឹងការព្យាករថវិកា | C | C |
| 24.2 | ភាពទាន់ពេលវេលានៃការចេញផ្សាយរបាយការណ៍ | A | A |
| 24.3 | គុណភាពនៃព័ត៌មាន | C | C |
| PI-25 | **គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ** | D+ | C+ |
| 25.1 | ភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ | D | B |
| 25.2 | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ | B | B |
| 25.3 | បទដ្ឋានគណនេយ្យដែលត្រូវបានប្រើប្រាស់ | C | C |
| *សសរស្តម្ភ ៦ ÷ ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ* | | | |
| PI-26 | **វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តសវនកម្មពីខាងក្រៅ** | NR | NA |
| 26.1 | វិសាលភាព/ចរិតលក្ខណៈរបស់សនវកម្មដែលត្រូវបានធ្វើឡើង (រួមទាំងការគោរពទៅតាមបទដ្ឋានសវនកម្ម) | NR | NA |
| 26.2 | ភាពទាន់ពេលវេលានៃការបញ្ជូនរបាយការណ៍សវនកម្មទៅកាន់រដ្ឋសភា | A | NA |
| 26.3 | ភស្តុតាងនៃការតាមដានបន្តទៅលើអនុសាសន៍សវនកម្ម | C | NA |
| PI-27 | **ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិប្បញ្ញត្តិ** | C+ | C+ |
| 27.1 | វិសាលភាពនៃការត្រួតពិនិត្យរបស់អង្គភាពនីតិប្បញ្ញត្តិ | C | C |
| 27.2 | កម្រិតនៃការរៀបចំនីតិវិធីបានល្អ និងការអនុវត្តកម្មវិធីបានត្រឹមត្រូវក្នុងអង្គនីតិប្បញ្ញត្តិ | B | B |
| 27.3 | ពេលវេលាគ្រប់គ្រាន់សម្រាប់អង្គនីតិប្បញ្ញត្តិក្នុងការឆ្លើយតបទៅនឹងសំណើថវិកា | C | C |
| 27.4 | វិធានការស្តីពីការកែតម្រូវថវិកាក្នុងឆ្នាំដោយពុំចាំបាច់មានការយល់ព្រមជាមុនឬក្រោយពីអង្គនីតិប្បញ្ញត្តិ | B | B |
| PI-28 | **ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅដោយអង្គនីតិប្បញ្ញត្តិ** | B | B |
| 28.1 | ភាពទាន់ពេលវេលានៃការពិនិត្យលើរបាយការណ៍សវនកម្មដោយអង្គនីតិប្បញ្ញត្តិ | B | B |
| 28.2 | ការរៀបចំសវនាការដោយអង្គនីតិប្បញ្ញត្តិលើរបកគំហើញគន្លឹះ | B | B |

| | | | |
|---|---|---|---|
| 28.3 | អនុសាសន៍របស់អង្គនីតិប្បញ្ញត្តិ និងការអនុវត្តសកម្មភាព អនុលោមតាមអនុសាសន៍ដោយអង្គប្រតិបត្តិ | B | B |
| *ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍* | | | |
| **D-1** | **ការប៉ាន់ប្រមាណ Budget Support** | **D** | **NR** |
| D1.1 | គម្លាតការអនុវត្ត Budget Support ប្រចាំឆ្នាំពីការព្យាករដែលបានផ្តល់ដោយដៃគូអភិវឌ្ឍន៍យ៉ាងហោចណាស់ ៦ សប្តាហ៍មុនពេលរដ្ឋាភិបាលបញ្ជូនសំណើថវិការបស់ខ្លួនទៅស្ថាប័ននីតិប្បញ្ញត្តិ | D | NR |
| D1.2 | ភាពទាន់ពេលវេលានៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (អនុលោមភាពជាមួយការប៉ាន់ស្មានប្រចាំត្រីមាស) | D | NR |
| **D-2** | **ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកា និងការរាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោង និងកម្មវិធី** | **D+** | **NR** |
| D2.1 | ភាពពេញលេញ និងភាពទាន់ពេលវេលានៃការប៉ាន់ប្រមាណថវិការបស់ម្ចាស់ជំនួយសម្រាប់គាំទ្រគម្រោង | C | NR |
| D2.2 | អត្រានៃការកើតឡើង និងវិសាលភាពនៃការរាយការណ៍ដោយម្ចាស់ជំនួយអំពីលំហូរជំនួយជាក់ស្តែងសម្រាប់ការគាំទ្រគម្រោង | D | NR |
| **D-3** | **ទំហំនៃហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ** | **D** | **NR** |

**ឧបសម្ព័ន្ធទី ៤. តារាងសង្ខេបការផ្លាស់ប្តូរកម្រិតគោលបំណង**

| ក្របខណ្ឌ CAP3 | ក្របខណ្ឌ CAP3 បូក ២ |
|---|---|
| *ផ្នែកទី១ "បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"* | *ខឿន/ផ្នែកទី១ "ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"* |
| ១១. បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | ១១. បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល |
| ១២. បន្តពង្រឹងការគ្រប់គ្រងបំណុល | ១២. ពង្រឹងការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ |
| ១៣. ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី | ១៣. ពង្រឹងដំណើរការអនុវត្តថវិកា |
| ១៤. កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ | |
| *ផ្នែកទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"* | *ខឿន/ផ្នែកទី២ "ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"* |
| ២១. ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី | ២១. ពង្រឹងការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) |
| ២២. ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី | ២២. ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី |
| ២៣. ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី | ២៣. ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋទាំងការគ្រប់គ្រងទ្រព្យហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ (Financial Asset Management and Non Financial Asset) |
| ២៤. ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និង គណនេយ្យភាព (ប្រព័ន្ធត្រួតពិនិត្យ) | ២៤. ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ ដោយរួមទាំងហានិភ័យបំណុលពាក់ព័ន្ធ ជាពិសេស ហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ |
| ២៥. បង្កើនតម្លាភាពថវិកា | ២៥. ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ |
| *ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"* | *ខឿន/ផ្នែកទី៣ "ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"* |
| ៣១. ពង្រឹង និងពង្រីកការអនុត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកា | ៣១. រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈនិងថវិការយៈពេលមធ្យម |

| | |
|---|---|
| ៣២. រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា | ៣២. ពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ |
| ៣៣. រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និង នីតិប្រតិបត្តិ, រវាង គសហវ និងក្រសួង-ស្ថាប័ន និងនៅក្នុងក្រសួង-ស្ថាប័ន) | ៣៣. ពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា |
| ៣៤. ពង្រឹងការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយ និងផែនការចំណូលនិងចំណាយរយៈពេលមធ្យម) | ៣៤. ជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ៣៥. ពង្រឹងការរអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ | |
| ***ផែនកទី៤ "គណនេយ្យភាពសមិទ្ធកម្ម"*** | ***ខឿន/ផែនកទី៤ "ការកសាងគណនេយ្យភាពសមិទ្ធកម្ម/ស្ថាប័ននីយកម្មថវិកាសមិទ្ធកម្ម"*** |
| ៤១. បង្កើតក្របខណ្ឌថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម | ៤១. ដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម |
| ៤២. រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគណនេយ្យភាពសមិទ្ធកម្ម | ៤២. ដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងពិនិត្យសមិទ្ធកម្មតាមក្រសួង ស្ថាប័ន |
| ៤៣. ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ | ៤៣. ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ (សវនកម្មផ្ទៃក្នុង អធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មឯករាជ្យ) |
| ៤៤. រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាព (រួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ) | ៤៤. លើកកម្ពស់តម្លាភាពថវិកា (ប្ដូរពីគោលបំណង ២៥ នៃ CAP3) |
| ***ផែនកទី៥ "ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព (សមត្ថភាពជំនាញ សមត្ថភាពអនុវត្តកំណែទម្រង់លើកទឹកចិត្ត)*** | ***ផែនកទី៥ "ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត"*** |
| ៥១. បង្កើនភាពជាអ្នកដឹកនាំ, សមត្ថភាព គ្រប់គ្រង, និងបណ្ដុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ | ៥១. ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាព ក្នុងការគ្រប់គ្រង ភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងការកែទម្រង់ |
| ៥២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត | ៥២. ធានាចលនាការនៃកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ៥៣. ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ | ៥៣. ពង្រឹងភាពប្រទាក់ក្រឡាគ្នារវាងការដ្ឋាននៃកម្មវិធីកែទម្រង់ផ្សេងៗទៀត |